# វាក្យសំសយទីបនី

*(បំភ្លឺនូវសេចក្តីសង្ស័យក្នុងប្រយោគ)*

## ភាគទី ១

## A PALI GRAMMAR

*រៀបរៀងដោយ*

## អ៊ាន់ ចាន់សារ៉ែន

*កាលនៅជាក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*


*ការផ្សាយឡើងវិញរបស់ពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*ព.ស.២៥៥៧*

*គ.ស.២០១៣*

# វាក្យសំសយទីបនី

( បំភ្លឺនូវសេចក្ដីសង្ស័យក្នុងប្រយោគ )

**ភាគទី ១**


**រៀបរៀងដោយ**

**អ៊ាន់ ចាន់សាន៉ែ**

ក្រុមជំនុំព្រះត្រៃបិដកនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ



ការផ្សាយឡើងវិញរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៧

 គ.ស.២០១៣

**ឈ្មោះសៀវភៅ** វាក្យសំសយទីបនី

**អ្នករៀបរៀង** វ៉ាន់ ចាន់សារ៉ែន

**អ្នកត្រួតពិនិត្យ** ព្រះភិក្ខុ ឧទ្ទេសាចារ្យ ធម្មានន្ទោ សូង សឿ
ព្រះភិក្ខុ វជិរប្បញ្ញោ គូ សុភាព , សាស្ត្រាចារ្យ
រស់ សាវេន , លោក លឹម លឿម , លោក
វ៉ាយ វិបុល ,

**វាយអត្ថបទកុំព្យូទ័រ** វ៉ាន់ ចាន់សារ៉ែន

**ស្ថានទីធ្វើ** ការិយាល័យក្រុមជំនុំព្រះត្រៃបិដក វិទ្យាស្ថាន
ពុទ្ធសាសនបណ្ឌិត្យ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌ
ចំការមន រាជធានីភ្នំពេញ ,

**បោះពុម្ពទី ១** ព.ស. ២៥៤៧ គ.ស. ២០០៤
ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

**បោះពុម្ពទី ២** ដោយពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

បោះពុម្ពលើកទី ២ នេះ ដោយរក្សាឯកសារបោះពុម្ពដើមទាំង
ស្រុងរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ព

ខ្ញុំព្រះករុណា ខ្ញុំនឹងខិតខំស្វែងរកឯកសារចាស់ ៗ និង ឯកសារថ្មី ៗ ដែលអ្នកប្រាជ្ញបានរៀបរៀងឡើង ហើយនឹងបោះពុម្ពជាប្រយោជន៍ដល់ សាធារណជនទូទៅ ដើម្បីថែរក្សា វប្បធម៌ អក្សរសាស្ត្រឱ្យគង់វង្ស និង រីកចំរើនជាភិយ្យោភាព ។ នៅក្នុងពេលនេះក្នុងនាមខ្ញុំជានាយក ពុទ្ធសាសនបណ្ឌិត្យ បានចេញបោះពុម្ពសៀវភៅ **ធាតុសំសយនីបនី** ដែលរៀបរៀងដោយ លោក **ម៉ាន់ ចាន់សារ៉េន** ជាសមាជិកក្រុមជំនុំព្រះត្រៃបិដក ដែលបានពន្យល់នូវរបៀបប្រយោគនិងសម្ពន្ធផ្សេង ៗ ដែលជាជំនួយដល់ការសិក្សារបស់ សមណសិស្ស ទាំងបឋមសិក្សានិងពុទ្ធិកវិទ្យាល័យ ហើយជាសៀវភៅមួយធ្វើឱ្យអ្នកសិក្សាភាសាបាលីឆាប់ងាយយល់ អាចប្រែគម្ពីរដោយខ្លួនឯងមិនចាំបាច់គ្រូប្រាប់ឡើយ ។

ម្យ៉ាងទៀត ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យកំពុងដំណើរការធ្វើគម្ពីរផ្សេង ៗ រួមទាំងគម្ពីរវេយ្យាករណ៍ផ្នែកភាសាបាលី ដើម្បីជំនួយដល់ការសិក្សារបស់ព្រះភិក្ខុសង្ឃនិងសាធារណជនទូទៅ ។

ខ្ញុំសូមកោតសរសើរនូវស្នាដៃដ៏ល្អឯករបស់ លោក **ម៉ាន់ ចាន់សារ៉េន** ដែលខិតខំស្រាវជ្រាវក្នុងគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា បករណវិសេស និងគម្ពីរវេយ្យាករណ៍ដទៃ ៗ ទៀត ឱ្យកើតជារូបរាងសៀវភៅនេះឡើង ។

ខ

សូមជនានុជនក្នុងកម្ពុជរដ្ឋបានចំរើនលូតលាស់ដុះដាល ដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និង លើកស្ទួយអក្សរសាស្ត្រនិងព្រះពុទ្ធសាសនាឱ្យបានរីកចំរើនជាភិយ្យោភាពតរៀងទៅ ។

**ភ្នំពេញ**

**ថ្ងៃ ១៣ កើត ខែ អស្សុជ ព.ស. ២៥៤៧**

**ត្រូវនឹងថ្ងៃ ពុធ ទី ០៨ ខែ តុលា ឆ្នាំ ២០០៣**

**នាយក**

**ពុទ្ធសាសនបណ្ឌិត្យ**

# អានិសង្សកថា

ការសិក្សាឱ្យយល់ជាក់ច្បាស់នូវគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា ត្រូវអាស្រ័យនូវការសិក្សាវេយ្យាករណ៍ជាដំបូងសិន ទើបអាចឈានដល់ការយល់អត្ថនិងព្យញ្ជនៈដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងបានយ៉ាងល្អ សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏ព្រះអង្គទ្រង់ឱ្យតម្លៃនូវការសិក្សាវេយ្យាករណ៍នេះផងដែរ ដូចព្រះអង្គទ្រង់ត្រាស់ថា ៖

**ឥធ ភិក្ខវេ ភិក្ខូ ទុគ្គហិតំ សុត្តន្តំ បរិយាបុណន្តិ ទុន្និក្ខិត្តេហិ បទព្យញ្ជនេហិ ទុន្និក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ** ( អង្គុត្ត. ចតុក្ក. ៤៣/១៤ , អង្គុត្ត.បញ្ចក.៤៥/៩៩ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រៀនព្រះសូត្រគឺព្រះត្រៃបិដកភ្លាំងភ្លាត់បាន បើសិនបទនិងព្យញ្ជនៈគឺពាក្យពេចន៍ភាសាមានសេចក្តីភ្លាំងភ្លាត់ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងខុស ( ភ្លាំងភ្លាត់) រមែងយល់សេចក្តីបានដោយកម្រ គឺរមែងនាំមកនូវការវាយសេចក្តីខុសបាន ។

ព្រះពុទ្ធដីកានេះសឱ្យឃើញថា ការសិក្សាវេយ្យាករណ៍នេះមានសារៈសំខាន់បំផុត ព្រោះការយល់ព្រះត្រៃបិដកដ៏ជ្រៅនិងសម្បូរណ៍ដោយអត្ថទៅបាន ត្រូវអាស្រ័យសិក្សាវេយ្យាករណ៍ជាខាងដើម ។ ការសិក្សាវេយ្យាករណ៍ទៀតសោតត្រូវអាស្រ័យការសិក្សាវេយ្យាករណ៍ធំ ៗ ៤ ក្រុម គឺ ÷

**១. គម្ពីរវេយ្យាករណ៍** គឺគម្ពីរសំដែងគោលភាសា ឬគោលវេយ្យាករណ៍បាលី ដូចគម្ពីរកច្ចាយនព្យាករណ៍ គម្ពីរមោគ្គល្លានព្យាករណ៍ គម្ពីរសទ្ទនីតិ រូបសិទ្ធិ រូបសិទ្ធិដីកា ជាដើម ។

**២. ក្រុមនិឃណ្ឌុ** គឺប្រភេទបទានុក្រមស័ព្ទ ដូចគម្ពីរ អភិធានប្បទីបិកា អភិធានប្បទីបិកាសូចិ អភិធានប្បទីបិកាដីកា ជាដើម ។

**៣. ក្រុមឆន្ទលក្ខណៈ** គឺគម្ពីរពោលដោយគោលនិងវិធីសម្ពន្ធ ឆ័ន្ទ គាថា ដូចជា គម្ពីរ វុត្តោទ័យ ឆន្ទោមញ្ជរី ឆន្ទោមញ្ជរីដីកា ជាដើម ។

**៤. ក្រុមអេលង្ការ** គឺគម្ពីរសំដែងវិធីតែងពាក្យនិងប្រយោគឱ្យពីរោះរន្ធំ និងសំដែងវិធីប្រើពាក្យពេចន៍ប្រាសចាកទោស និងអត្ថរសរបស់ពាក្យ និងប្រយោគ ដូច គម្ពីរ សុពោធាលង្ការៈ អលង្ការៈ អលង្ការដីកា ជាដើម ។

គម្ពីរវេយ្យាករណ៍ទាំងអស់ដែលព្រះថេរៈទាំងឡាយបាននាំត។ គ្នាមករហូតដល់យើងសព្វថ្ងៃ បានរៀបរៀងទៅតាមក្រុមនីមួយ ៗ ដូចក្រុមគម្ពីរកច្ចាយនព្យាករណ៍ មួយខ្សែ ក្រុមគម្ពីរមោគ្គល្លាន មួយខ្សែ ក្រុមគម្ពីរសទ្ទនីតិ មួយខ្សែ ។ ក្រុមគម្ពីរវេយ្យាករណ៍ទាំង ៣ ខ្សែនេះមានច្រើនណាស់ ដែលកុលបុត្រប្រាថ្នាសិក្សាឱ្យយល់ព្រះពុទ្ធវចនៈមិនឱ្យឃ្លៀងឃ្លាត ត្រូវឈានចូលទៅសិក្សាគម្ពីរទាំងនោះ ។

នៅក្នុងប្រទេសកម្ពុជាបានទទួលមតិកព្រះពុទ្ធសាសនា ថេរវាទ តាំងពីយូរលង់ណាស់មកហើយ ក៏បានទទួលការសិក្សាវេយ្យាករណ៍យ៉ាងល្អ រហូតមកដល់បច្ចុប្បន្ន ។ តែក្នុងសម័យដើមការសិក្សាវេយ្យាករណ៍បាលី ត្រូវផ្អែក

លើការសិក្សាគម្ពីរកច្ចាយនព្យាករណ៍ ឬមួយបែបទៀតខ្មែរយើងហៅថា មូល-កច្ចាយនៈ ។ ការសិក្សាវេយ្យាករណ៍បាលីធំ ៧ នោះខាងក្រោយមកក៏បាត់បង់បន្តិចម្តង ៗ នៅសល់តែការសិក្សា កច្ចាយនូបត្ថម្ភក (សម្តេច ព្រះសង្ឃរាជ ជ.ណ.**ជួន ណាត**) និងវេយ្យាករណ៍បាលី (**សេខ នាខ**) រហូតមកដល់សព្វថ្ងៃនេះ តែទោះជាយ៉ាងណាក៏ដោយ វេយ្យាករណ៍ទាំងអស់នោះនៅមិនទាន់គ្រប់គ្រាន់សម្រាប់អ្នកសិក្សាវេយ្យាករណ៍នៅឡើយ ដូចសម្តេចព្រះសិរីសម្មតិវង្ស **លី ឯម** ចាងហ្វាងសាលាបាលីជាន់ខ្ពស់បានពោលទុកនូវសេចក្តីយល់ឃើញក្នុងសៀវភៅ កច្ចាយនូបត្ថម្ភកថា៖

សៀវភៅកច្ចាយនូបត្ថម្ភ ដែលព្រះសាសនសោភណ (ណាត) ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ បានដកស្រង់យកសេចក្តីពីគម្ពីរមូលដទៃជាច្រើនមករៀបរៀង ជាបែបវេយ្យាករណ៍សម្រាប់រៀនភាសាបាលីជាគ្រឿងជំនួយជួយការសិក្សាមូលកច្ចាយនៈឱ្យបានងាយឡើង... ។

ក្រុមជំនុំព្រះត្រៃបិដកយើងខ្ញុំ ដែលប្រចាំការនៅពុទ្ធសាសនបណ្ឌិត្យនឹងខិតខំធ្វើគម្ពីរវេយ្យាករណ៍ធំ ៧ អដ្ឋកថា ដីកានិងបករណវិសេសដទៃជាច្រើន ដើម្បីជំនួយដល់ការសិក្សាព្រះពុទ្ធសាសនារបស់កុលបុត្រក្នុងកម្ពុជរដ្ឋ ។

តែបច្ចុប្បន្នកាលនេះកុលបុត្រជាច្រើន កំពុងតែសិក្សាវេយ្យាករណ៍បាលីហើយខ្វះគម្ពីរសម្រាប់ជំនួយជួយដល់ការប្រែប្រយោគធំៗ ដែលមានមកក្នុងអដ្ឋកថា ដីកាជាដើម ការឃើញហេតុលំបាកយ៉ាងនោះ ទើបក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានរៀបរៀងសៀវភៅជាជំនួយ

ដល់ការសិក្សាវេយ្យាករណ៍ជាដំបូងសិន ទើបនឹងរៀបចំនូវគម្ពីរធំ ៧ ជាខាងក្រោយ ។ ហើយក្នុងសៀវភៅនេះ មានឈ្មោះ "**ខាគ្យសំសយទីបនី**" មានន័យថា បំភ្លឺនូវសេចក្តីសង្ស័យក្នុងប្រយោគ ដោយថានៅក្នុងស្រុកខ្មែរយើងសព្វថ្ងៃមានកុលបុត្រកំពុងសិក្សានូវវេយ្យាករណ៍ជាច្រើនអង្គ ហើយកំពុងខ្វះខាតនូវគម្ពីរជំនួយការសិក្សាទើបខ្ញុំចាប់រៀបរៀងសៀវភៅនេះ ដែលជាសម្ពន្ធពិសេសនិងប្រយោគពិសេសនេះឡើង តែខ្ញុំមិនបានរៀបតាំងពីសម្ពន្ធវិភត្តិទាំង ៩ នោះទេ ព្រោះមានក្នុង **សម្ពន្ធមាលា** របស់ព្រះតេជគុណ **អ៊ុំ ស៊ុំ** ទៅហើយ ខ្ញុំចាប់រៀបពីប្រយោគណា ដែលថានៅមិនទាន់ច្បាស់លាស់នៅឡើយហើយជាប្រយោគលំបាកស្មុគស្មាញប៉ុណ្ណោះ។ ខ្ញុំព្រះករុណាសង្ឃឹមថា **ខាគ្យសំសយទីបនី** នេះ នឹងសម្រេចបានជាប្រយោជន៍ ដល់ការសិក្សាភាសាបាលីរបស់កុលបុត្រក្នុងកម្ពុជរដ្ឋមិនខានទេ ។ ការរៀបរៀងឡើង ខ្ញុំគិតថា ធ្វើតែមួយក្បាលទេ តែធ្វើទៅឃើញថាក្រាស់ពេក ទើបខ្ញុំបែងចែកជាពីរភាគ គឺ ភាគទី ១ ភាគទី ២ ។ សូមព្រះសង្ឃនិមន្តសិក្សាឱ្យបានចប់ទាំងពីរភាគ ដោយធម្មសប្បាយចុះ។

**ពុទ្ធសាសនបណ្ឌិត្យ**

ថ្ងៃ ៥ កើត ខែ ពិសាខ ឆ្នាំ មមែ បញ្ចស័ក ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ៥ ខែ ឧសភា គ.ស. ២០០៣

**ហ៊ាន់ ចាន់សារ៉េន**

ក្រុមជំនុំព្រះត្រៃបិដនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

## អ្នកមានឧបការៈក្នុងការធ្វើសៀវភៅ

-លោក ខួន ប៉ាន់ចន្ទី នាយកពុទ្ធសាសនបណ្ឌិត្យ

## អ្នកមានឧបការៈក្នុងការពិនិត្យសម្ពន្ធនិងប្រយោគ

១-ព្រះភិក្ខុ ចជិរប្បញ្ញោ គួ សុភាព ឧទ្ទេសាចារ្យ វត្តនិគ្រោធវ័ន

២- ព្រះភិក្ខុ ធម្មានន្ទោ សួង សឿ ឧទ្ទេសាចារ្យ វត្តនិគ្រោធវ័ន

៣-លោក លីម លឿមក្រុមជំនុំព្រះត្រៃបិដក វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

៤-សាស្ត្រាចារ្យ រស់ សារេន ឧទ្ទេសាចារ្យពុទ្ធិកមហាវិទ្យាល័យ សីហនុរាជ

៥-លោក ប៉ាយ ទិប្វុល ក្រុមជំនុំទំនៀមទំលាប់ប្រចាំវិទ្យាស្ថានពុទ្ធ-
សាសនបណ្ឌិត្យ

## អក្សរសង្ខេបនិងឈ្មោះពេញគម្ពីរ

ខ្ញុំសូមបញ្ជាក់លេខដែលប្រើខាងមុខជាលេខក្បាលគម្ពីរ លេខដែលប្រើខាងក្រោយជាលេខទំព័រ ដូចលេខថា ៥២/១ អានថា សុត្តន្ត-បិដក លេខ ៥២ ទំព័រ ១ សូម្បីនៅក្នុង អដ្ឋកថា ដីកា ក៏ដូចគ្នា ។ គម្ពីរតម្រាណាជាសៀវភៅបាលីខ្មែរបានបោះពុម្ពរួចហើយ ខ្ញុំអាងដល់គម្ពីរតម្រានោះ តែគម្ពីរណាដែលខ្មែរមិនទាន់បោះពុម្ពទេ ខ្ញុំអាងដល់គម្ពីរច្បាប់មហាចុឡាខ្លះ មហាមកុដខ្លះ ជាសាធកៈក្នុងសៀវភៅនេះ ។

| អាទិសង្ខេត | ពាក្យពេញ |
|---|---|
| -ធម្ម. | ធម្មបទដ្ឋកថា |
| -សុត្តន្ត.ខុទ្ទក. | សុត្តន្តបិដក ខុទ្ទកនិកាយ |
| -ឧ. | ឧទាហរណ៍ |
| -ប្រែ. | ប្រែលោតប្រយោគ |
| -សមន្ត. | សមន្តប្បាសាទិកា |
| -មង្គលត្ថ. | មង្គលត្ថទីបនី |
| -អភិ.វិ. | អភិធម្មត្ថវិភាវិនីដីកា |
| -បរមត្ថ.អដ្ឋ. | បរមត្ថទីបនី អដ្ឋកថា |
| -ខុទ្ទក. | ខុទ្ទកនិកាយ |

| អាទិសង្កេត | ពាក្យពេញ |
|---|---|
| -វិនយ. | វិនយបិដក |
| -ទ. | ទាំងឡាយ |
| -ម. | មរម្មបោត្ថកេ ( ច្បាប់ភូមា) |
| -បញ្ចក. | បញ្ចកនិបាត |
| -អង្គុត្ត. | អង្គុត្តរនិកាយ |
| -ឯក. | ឯកនិបាត |
| -ទសក. | ទសកនិបាត |
| -មជ្ឈិម. | មជ្ឈិមនិកាយ |
| -សុ.វិ. | សុមង្គលវិលាសិនី |

ខ្ញុំលើកយកចំពោះតែគម្ពីរណាដែលខ្ញុំដាក់ជាពាក្យអាទិសង្កេតមក តែឈ្មោះគម្ពីរដែលខ្ញុំលើកយកជាសាធកៈដោយច្រើនដាក់ឈ្មោះពេញ សូមអ្នកសិក្សាគប្បីជ្រាបតាមអាទិសង្កេតនេះចុះ ។

# មាតិកាអត្ថបទ

**លរ.** **ទំព័រ**


១-បទនមស្ការ ៣

៦-ប្រយោគវិកតិវុត្តកម្ម ១

៧-ប្រយោគវិកតិអវុត្តកម្ម ៤

៨-ប្រយោគវិកតិអវុត្តកម្មចូលទីឯចរធាតុ ១៤

៩-ប្រយោគវិកតិអវុត្តកម្មក្នុងកម្មវាចកៈ ១៥

១០-ប្រយោគវិកតិអវុត្តកម្មចុះក្នុងភាវវាចកៈ ១៦

១១-ប្រយោគវិកតិអវុត្តកម្មឈ្មោះឧបមាវិកតិអវុត្តកម្ម ១៧

១២-ប្រយោគសម្ភាវនៈ ២០

១៣-ប្រយោគសម្ភាវនៈក្នុងកត្តុវាចកៈ ២១

១៤-ប្រយោគសម្ភាវនៈក្នុងកម្មវាចកៈ ២២

១៥-ប្រយោគសញ្ញាវិសេសនៈ-សញ្ញីវិសេសយៈ ២៥

១៦-ប្រយោគវិសេសនលាភី ៣៤

១៧-ប្រយោគសរូបទិទស្សនៈ-សរូបទិទស្សនីយៈ ៤១

១៨-ប្រយោគសរូបវិសេសនៈ ៥៦

១៩-ប្រយោគកិរិយាបរាមាស ៦១

២០-កិរិយាបរាមាស យំ-តំ ៦៤

២១-កិរិយាបកាមាស តំ-យំ ៦៥

២២-កិរិយាបកាមាស ឯតំ-យំ ៦៧

២៣-កិរិយាបកាមាស យំ-តស្ស, យំ-តេន ៧២

២៤-កិរិយាបកាមាស យស្មា-តស្មា ៧៤

២៥-កិរិយាបកាមាស ហិ-ឥតិ ៧៧

២៧-ប្រយោគនាគសោណ្ឌិគតិ ៨០

២៨-កិរិយាបធានន័យ ៩០

២៩-ប្រយោគវិកតិកត្តា ១០២

៣០-ប្រយោគកិមង្គំ បន ១០៨

៣១-គោ បន វាទោ ១១២

៣២-បគេវ ១១៧

៣៣-កិរិយាបទ ១២២

៣៤-សក្កា ១២២

៣៥-លព្ភា ១២៦

៣៦-អលំ ១២៨

៣៧-និគមកថា ១៣៤

៣៨-ឯកសារពិគ្រោះ ១៣៥

# បទនមស្ការ

**បារមិតិទុក្ករាវ ប្ញូរិយានសេដ្ឋពោធី**
**បាបុណិត្ថ យោ អនន្ត- ធម្មសារទំ នមាមិ ។**
**កម្ពុជរដ្ឋវាសិនំ វាក្យសំសយទីបនី**
**បករណំ នាម សេដ្ឋំ កុលបុត្តានំ វក្ខាមិ។**

ព្រះដ៏មានព្រះភាគអង្គណា ទ្រង់បំពេញនូវបារមី ដែលសត្វលោកធ្វើបានដោយកម្រ ហើយទ្រង់បាន សម្រេចនូវព្រះសព្វញ្ញុតញ្ញាណ បង្កឲ្យកើតនូវ សារធម៌រកទីបំផុតមិនមាន ខ្ញុំព្រះករុណា ( វ៉ាន់ ចាន់សារ៉េន ) សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មាន ព្រះភាគអង្គនោះ ដោយគោរព ។ ខ្ញុំព្រះករុណា នឹងពោលនូវបករណ៍ដ៏ប្រសើរ ដែលមានឈ្មោះថា «វាក្យសំសយទីបនី» ដើម្បីជាប្រយោជន៍ ដល់ កុលបុត្រទាំងឡាយ អ្នកនៅក្នុងដែនកម្ពុជរដ្ឋ ដូច តទៅនេះ ។ ៚

# វាក្យសំសយទីបនី

# ភាគទី ១

## ប្រយោគវិកតិវុត្តកម្ម

ប្រយោគវិកតិវុត្តកម្មនេះ ជាប្រយោគសម្រាប់ហៅ **មន គុណនាម** ដូចគ្នា, តែគុណនាមពួកនេះ ចូលនឹងកិរិយាថា **ធ្វើ** គឺចូលនឹងកិរិយាដែលកើតអំពី **ករធាតុ** ហើយរៀងទុកក្នុងប្រយោគដែលជាកម្មវាចកៈ ទាំងប្រកបដោយបឋមាវិភត្តិទៀតផង ។ វេលាប្រែត្រូវប្រែថា "ឱ្យ, ឱ្យជា ,ឱ្យជាអ្នក, ថា ," ហើយជាពិសេស ថែមទៀតនោះ ត្រូវសម្ពន្ធចូលនឹងកិរិយាថា ធ្វើតែម្យ៉ាង ។

ឧ. **បាណាតិបាតកម្មស្ស វោ ភន្តេ អការកោ កតោ ។** ប្រែថា **ភន្តេ** បពិត្រព្រះអង្គដ៏ចំរើន (**កុក្កុដមិត្តោ** វីកុក្កុដមិត្ត) **វោ** គឺព្រះអង្គ **កតោ** ធ្វើហើយ **អការកោ** ឱ្យជាអ្នកមិនធ្វើ **បាណាតិបាតិកម្មស្ស** នូវបាណាតិបាតកម្ម ។ សម្ពន្ធដូចតទៅ **ភន្តេ** សគារវាលបនៈ **កុក្កុដមិត្តោ** បកតិវុត្តកម្ម ក្នុង **កតោ** ៗ កិតបទកម្មវាចកៈ **អការកោ** វិកតិវុត្តកម្មក្នុង **កតោ , វោ**

អនភិហិតកត្តាក្នុង **កតោ, បាណាតិបាតកម្មស្ស** ឆដ្ឋីកម្មក្នុង **អការកោ** (ធម្ម.៥/៣៩) ។ គ្រឿងចំណាំពិសេសនោះគឺយើងត្រូវយល់ថា បទដែលជាវិកតិវុត្តកម្មនោះ មានក្នុងប្រយោគកម្ម-វាចកៈ ហើយប្រកបដោយបឋមាវិភត្តិ ព្រមទាំងសម្ពន្ធចូលនឹងកិរិយាថា **ធ្វើ** គឺ **ករធាតុតែម្យ៉ាង** ។ ក៏ប្រយោគវិកតិវុត្តកម្មនេះផ្សេងពីវិកតិអវុត្តកម្ម ។

ឧ.ទី ២ **តេ វា សាខាបារោហា ឆិន្ទិត្វា ពហិដ្ឋកា កាតព្វា** (សមន្ត. ៣/១១៧) **។** ប្រែថា **វា** ន័យម្យ៉ាងទៀត **សាខាបារោហា** វីមែកនិងពួរទាំងឡាយ **តេ** នោះ **កេនចិ បុគ្គលេន** គឺបុគ្គលណាមួយ **ឆិន្ទិត្វា** កាត់ចោលហើយ **កាតព្វា** គប្បីធ្វើ **ពហិដ្ឋកា** ឱ្យនៅខាងក្រៅ ។ សម្ពន្ធ **វា** ស័ព្ទ បក្ខន្តរ-ជោតកៈ **តេ** វិសេសនៈ របស់ **សាខាបារោហា** ៗ ជាបកតិវុត្តកម្មក្នុង **កាតព្វា** ៗ ជា កិតបទកម្មវាចកៈ , **កេនចិ** វិសេសនៈរបស់ **បុគ្គលេន** ៗ អនភិហិតកត្តា ក្នុង **កាតព្វា** , **ឆិន្ទិត្វា** បុព្វកាល-កិរិយា ក្នុង **កាតព្វា** , **ពហិដ្ឋកា** វិកតិវុត្តកម្ម ក្នុង **កាតព្វា** ។

ឧ.ទី ៣ ( **ឥទំ សរីរំ កម្មេន** ) **អជ្ជិនំ នគរំ កតំ**

៣

**មំសលោហិតលេបនំ** (ធម្ម.រូបនន្ទាថេរីវត្ថុ ៥/១៦៦) ។ ប្រែថា **សរីរំ** រីសរីរៈ **ឥទំ** នេះ **មំសលោហិតលេបនំ** ដែលលាបបូក ដោយសាច់និងឈាម **កម្មេន** គឺកម្ម **កតំ** ធ្វើហើយ **នគរំ** ឱ្យជាគំនរ **អដ្ឋីនំ** នៃឆ្អឹងទាំងឡាយ ។ សម្ពន្ធ **ឥទំ** វិសេសនៈ របស់ **សរីរំ** ៗ បកតិវុត្តកម្មក្នុង **កតំ** ៗ ជាកិតបទកម្មវាចកៈ, **កម្មេន** អនភិហិតកត្តា ក្នុង **កតំ**, **អដ្ឋីនំ** សាមិសម្ពន្ធ ក្នុង **នគរំ**ៗ ជាវិកតិវុត្តកម្ម ក្នុង **កតំ** ។

## ចប់ប្រយោគវិកតិវុត្តកម្មដោយសង្ខេប

# ប្រយោគវិកតិអវុត្តកម្ម

ប្រយោគវិកតិអវុត្តកម្មនេះ ក៏ជាបទគុណនាមដូចគ្នាដែរ តែដោយច្រើនត្រូវសម្ពន្ធចូលនឹងកិរិយាថា **ធ្វើ** គឺ **ករធាតុ** ឬអាចមាន **ចរធាតុ**ខ្លះ តែមានតិច ឬធាតុដទៃទៀត ក៏អាចមានបាន តែមានតិចតួចមិនច្រើនណាស់ណាទេ ។ ចំពោះវិកតិអវុត្តកម្មនេះ ប្រកបដោយទុតិយាវិភត្តិពីរនៅអមជាប់គ្នា ឬ បើមិនមានទេ ត្រូវបន្ថែមមកទៀត ។ ចំណែកកេចិអាចារ្យខ្លះថាប្រើបានប្រយោគកត្តុវាចកៈតែម្យ៉ាងគត់ តែមិនមែនដូច្នោះទេ អាចប្រើបានទាំងប្រយោគកត្តុ និង ប្រយោគកម្ម ប្រយោគភាព ។ តែចំពោះកត្តុវាចកៈត្រូវចូលនឹង **ករធាតុ** ឬ **ចរធាតុ** ខ្លះ , បើមិនមាន **ករ-ធាតុ**ទេ ត្រូវបញ្ចូល **ករធាតុ** មកថែមទៀត ដើម្បីឱ្យត្រឹមត្រូវតាមប្រយោគ ។ តែបើកិរិយាជា **ករធាតុ** ស្រាប់ហើយមិនត្រូវបញ្ចូល **ករធាតុ** មកទៀតទេ ។ ចំណែកបទអវុត្តកម្មត្រូវផ្លាស់ជាបកតិអវុត្តកម្មវិញ ដូចឧទាហរណ៍តទៅនេះ ៖

ឧ.ទី ១ **ពុទ្ធំ សរណំ គច្ឆាមិ** ( សុត្តន្ត.ខុទ្ទក. ខុទ្ទកបាឋ:

៥២/១) ។ នេះជាប្រយោគវិកតិអវុត្តកម្ម ហើយមិនមាន **ករធាតុ** នៅក្នុងប្រយោគនេះទេ ត្រូវបញ្ចូលករធាតុមកទៀត ។ ប្រែថា **អហំ** រីខ្ញុំ **គច្ឆាមិ** សូមដល់ **ពុទ្ធំ** នូវព្រះពុទ្ធ **កត្វា** ធ្វើ **សរណំ** ឱ្យជាទីពឹង ។ សម្ពន្ធ **អហំ** សយកត្តា ក្នុង **គច្ឆាមិ** ៗ អាខ្យាតបទកត្តុវាចកៈ **ពុទ្ធំ** បកតិអវុត្តកម្ម ក្នុង **គច្ឆាមិ** , **សរណំ** វិកតិអវុត្តកម្ម ក្នុង **កត្វា** ៗ កិរិយាវិសេសនៈ ក្នុង **គច្ឆាមិ** ។

ឧ.ទី ២ **អជ្ជេវ ពុទ្ធំ សរណំ វជាហិ** ។ (ធម្មបទដ្ឋកថា ភាគ១ ទំព័រ៤៥) **អជ្ជ ឯវ** ក្នុងថ្ងៃនេះឯង **ត្វំ** រីលោក **វជាហិ** ចូរដល់ **ពុទ្ធំ** នូវព្រះពុទ្ធ **កត្វា** ធ្វើ **សរណំ** ឱ្យជាទីពឹង ។ សម្ពន្ធ **ឯវ** ស័ព្ទអវធារណត្ថវាចកៈក្នុង **អជ្ជ** ៗ កាលត្ថសត្តមី **ត្វំ** សយកត្តា ក្នុង **វជាហិ** ៗ អាខ្យាតបទ កត្តុវាចកៈ **ពុទ្ធំ** បកតិអវុត្តកម្ម ក្នុង **វជាហិ** , **សរណំ** វិកតិអវុត្តកម្មក្នុង **កត្វា** ៗ កិរិយាវិសេសនៈក្នុង **វជាហិ** ។

នៅក្នុងគម្ពីរយោជនាធម្មបទដ្ឋកថា ភាគ ១ ទំព័រ ២៤៩ ខ្លាចក្រែងកុលបុត្រច្រឡំប្រយោគនេះ លោកខែបទ **សរណំ** ថា **សរណន្តិ សរណំ កត្វា** ។ ត្រង់ពាក្យថា **សរណំ** ដូច្នេះ

ធ្វើឱ្យជាទីពឹង ។ ព្រះគន្ថរចនាចារ្យ លោកពន្យល់ឱ្យដឹងច្បាស់ថា ប្រយោគនេះ ជាប្រយោគវិកតិអវុត្តកម្ម។ តែកន្លែងខ្លះលោកដាក់ **កត្វា** មកតែម្តង ដូចនៅក្នុងគម្ពីរវិនយសង្គហដ្ឋកថា ទំព័រ ១៤ ថា **មេត្តចិត្តំ បុរេចារិកំ កត្វា វត្តព្វំ** ។ ប្រែថា **អាជានាជិយបរិត្តំ** រីអាជានាជិយបរិត្ត **ភិក្ខុនា** គឺភិក្ខុ **កត្វា** ធ្វើហើយ **មេត្តចិត្តំ** នូវមេត្តចិត្ត **បុរេចារិកំ** ឱ្យប្រព្រឹត្តទៅខាងមុខ **វត្តព្វំ** គប្បីពោលចុះ។ សម្ពន្ធ **អាជានាជិយបរិត្តំ** ជាវុត្តកម្មក្នុង **វត្តព្វំ** ៧ ជាកិតបទកម្មវាចកៈ **ភិក្ខុនា** អនភិហិតកត្តាក្នុង **វត្តព្វំ**, **មេត្តចិត្តំ** បកតិ-អវុត្តកម្មក្នុង **កត្វា** ,**បុរេចារិកំ** វិកតិអវុត្តកម្ម ក្នុង **កត្វា** ៧ បុព្វកាលកិរិយាក្នុង **វត្តព្វំ** ។ ចំណាំ បើបកតិអវុត្តកម្ម ប្រែចូលនឹងកិរិយាធំ ត្រូវសម្ពន្ធចូលក្នុងកិរិយាធំ តែបើប្រែចូលក្នុង **កត្វា** ត្រូវសម្ពន្ធនឹង **កត្វា** ។ **ពុទ្ធំ សរណំ គច្ឆាមិ**។ **ពុទ្ធំ** ប្រែចូលនឹង **គច្ឆាមិ** ត្រូវសម្ពន្ធថា បកតិអវុត្តកម្មក្នុង **គច្ឆាមិ** ។ **មេត្តចិត្តំ បុរេចារិកំ កត្វា វត្តព្វំ ។** ត្រង់ **មេត្តចិត្តំ** ប្រែចូលនឹង **កត្វា** ត្រូវសម្ពន្ធថា បកតិអវុត្តកម្ម ក្នុង **កត្វា** ។ ចំពោះ **កត្វា** បើប្រែមុនកិរិយាថា **កត្វា** ធ្វើហើយ ត្រូវសម្ពន្ធថា **បុព្វកាលកិរិយា**

វិញ ។ តែក្នុងឧ.ខាងលើ ប្រែក្រោយកិរិយាត្រូវសម្ពន្ធថា **កិរិយាវិ-សេសនៈ** ។ ព្រោះ **ត្វា** បច្ច័យប្រែបាន ៧ យ៉ាង ។ ដូចប្រ-យោគវិកតិអវុត្តកម្មមានក្នុងគម្ពីរសមន្តប្បាសាទិកា ភាគ ១ ទំព័រ៤ មានបាលីថា **សំវណ្ណនំ តញ្ច សមារភន្តោ តស្សា មហា-អដ្ឋកថំ សរីរំ កត្វា... អបរិច្ចជន្តោ ... សមារភិស្សំ** ។ ប្រែ. **ច** ក៏ **អហំ** វីខ្ញុំ **សមារភន្តោ** កាលប្រារព្ធផ្តើម **តំ សំវណ្ណនំ** នូវការពណ៌នានោះ **កត្វា** ធ្វើហើយ **មហាអដ្ឋកថំ** នូវមហា-អដ្ឋកថា **សរីរំ** ឱ្យជាគោលធំ **អបរិច្ចជន្តោ** កាលមិនលះបង់... **សមារភិស្សំ** ប្រារព្ធផ្តើមហើយ ។ នៅក្នុងគម្ពីរអត្ថយោជនា សមន្តប្បាសាទិកា ភាគ ១ ទំព័រ ១៤ ខែពន្យល់ថា **សំវណ្ណនន្តិ បទំ សមារភន្តោតិ បទេ កម្មំ , តន្តិ បទំ សំវណ្ណនន្តិ បទស្ស វិសេសនំ , ច_សទ្ទោ វាក្យារម្ភោ , សមារភន្តោតិ បទំ អហន្តិ បទស្ស វិសេសនំ , តស្សាតិ បទំ សរីរន្តិ បទេ សម្ពន្ធោ , មហាអដ្ឋកថន្តិ បទំ កត្វាតិ បទេ បកតិកម្មំ , សរីរន្តិ បទំ កត្វាតិ បទេ វិកតិកម្មំ កត្វាតិ បទំ អបរិច្ចជន្តោតិ បទេ បុព្វកាលកិរិយា...អហន្តិ បទំ**

**សមាវភិស្សន្តិ** **បទេ** **កត្តា** , **សមាវភិស្សន្តិ** **អាខ្យាតបទំ** **កត្តុវាចកំ** ។ បទថា **សំវណ្ណនំ** ជាកម្ម (អវុត្តកម្ម)ក្នុង **សមាវភន្តោ** , **តំ** វិសេសនៈ របស់ **សំវណ្ណនំ** , **ច** សព្ទជាវាក្យារម្ភៈ , បទថា **សមាវភន្តោ** ជា វិសេសនៈ(ឬជា អព្ភន្តរកិរិយា)របស់ **អហំ** , បទថា **តស្ស** ជាសម្ពន្ធៈរបស់ **សីវំ** , បទថា **មហាអដ្ឋកថំ** ជាបកតិកម្ម (បកតិអវុត្តកម្ម)ក្នុងបទថា **កត្វា**, បទថា **សីវំ** ជាវិកតិកម្ម (វិកតិអវុត្តកម្ម)ក្នុង **កត្វា** , បទថា **កត្វា** ជាបុព្វកាលកិរិយា ក្នុងបទថា **អបរិច្ចជន្តោ** ... បទថា **អហំ** ជា **កត្តា** (សយកត្តា) ក្នុងបទថា **សមាវភិស្សំ** , បទថា **សមាវភិស្សំ** ជាអាខ្យាតបទ កត្តុវាចកៈ ។ តាមការសម្ពន្ធក្នុងភាសាបាលី លំបាកយល់បន្តិច តែខ្ញុំលើកមកដើម្បីបានជាគ្រឿងអាងពីប្រយោគវិកតិអវុត្តកម្ម ហើយបានបញ្ជាក់ថែមទៀតថា **កត្វា** ប្រែថា **ធ្វើហើយ** ប្រែមុនកិរិយាឱ្យឈ្មោះ **បុព្វកាលកិរិយា** ។ តែបើប្រែក្រោយកិរិយា ប្រែត្រឹមពាក្យថា **ធ្វើ** មួយម៉ាត់ប៉ុណ្ណោះឱ្យឈ្មោះ **កិរិយាវិសេសនៈ** ។

ឧ.ទី ៣ **ឥមំ** **អត្ថំ** **បាកដំ** **ករោហិ** ។ អ្នកចូរ

ធ្វើនូវអត្ថនេះឱ្យប្រាកដ ។ ប្រែលោតប្រយោគ **ត្វំ** រីអ្នក **ករោហិ** ចូរធ្វើ **អត្ថំ** នូវអត្ថ **ឥមំ** នេះ **បាកដំ** ឱ្យប្រាកដ ។ សម្ពន្ធ **ត្វំ** សយកត្តា ក្នុង **ករោហិ** ៗ អាខ្យាតបទ កត្តុវាចកៈ **ឥមំ** វិសេសនៈ របស់ **អត្ថំ** ៗ បកតិអវុត្តកម្មក្នុង **ករោហិ** , **បាកដំ** ជាវិកតិអវុត្តកម្មក្នុង **ករោហិ** ។

នៅក្នុងប្រយោគនេះមាន **ករធាតុ** ស្រាប់ហើយមិនត្រូវបន្ថែម ករធាតុ មកទៀតទេ ។

ឧ.ទី ៤ **កុដុម្ពស្ស សាមិកំ តំ ករិស្សាមិ** ។ អញនឹងធ្វើនូវបុគ្គលនោះ ឱ្យជាម្ចាស់នៃទ្រព្យ ។ ប្រែលោតប្រយោគ **អហំ** រីអញ **ករិស្សាមិ** នឹងធ្វើ **តំ បុគ្គលំ** នូវបុគ្គលនោះ **សាមិកំ** ឱ្យជាម្ចាស់ **កុដុម្ពស្ស** នៃទ្រព្យ ។ សម្ពន្ធ **អហំ** សយកត្តា ក្នុង **ករិស្សាមិ** ៗ អាខ្យាតបទកត្តុវាចកៈ **កុដុម្ពស្ស** សាមិសម្ពន្ធក្នុង **សាមិកំ** ៗ វិកតិអវុត្តកម្មក្នុង **ករិស្សាមិ** , **តំ** វិសេសនៈ របស់ **បុគ្គលំ** ៗ បកតិអវុត្តកម្ម ក្នុង **ករិស្សាមិ** ។ កន្លែងប្រយោគខ្លះមិនមានបកតិអវុត្តកម្មមកអមខាងលើទេ តែវេលាប្រែត្រូវទាញបកតិអវុត្តកម្មមកផង ។

ឧ.ទី ៥ **សេដ្ឋី...តស្ស បាលោតិ នាមំ អកាសិ** (ធម្ម.១/៤)។ **សេដ្ឋី** រីសេដ្ឋី **អកាសិ** បានធ្វើហើយ **វចនំ** នូវពាក្យ **បាលោ ឥតិ** ថាបាលៈដូច្នេះ **នាមំ** ឱ្យជាឈ្មោះ **តស្ស បុត្តស្ស** នៃកូននោះ។ សម្ពន្ធ **សេដ្ឋី** សយកត្តា ក្នុង **អកាសិ** ៗ ជាអាខ្យាតបទ កត្តុវាចកៈ , **តស្ស** វិសេសនៈ របស់ **បុត្តស្ស** ៗ សាមិសម្ពន្ធៈក្នុង **អកាសិ**, **បាលោ** សរូបៈ ក្នុង **ឥតិ** ៗ សរូបៈក្នុង **វចនំ** ៗ បកតិអវុត្តកម្មក្នុង **អកាសិ**, **នាមំ** វិកតិអវុត្តកម្មក្នុង **អកាសិ** ។

ឧ.ទី ៦ **ឧក្ខិបិត្វា វា តុលាសង្ឃាដេ ឋបេត្វា អដ្ដំ កត្វា បរិភុញ្ជតិ** (សមន្ត.៤/៣០៦) ។ **វា**ម្យ៉ាងទៀត **ភិក្ខុ** រីភិក្ខុ **ឧក្ខិបិត្វា** លើកឡើងហើយ **មញ្ចំ** នូវគ្រែ **ឋបេត្វា** តម្កល់ទុកហើយ **តុលាសង្ឃាដេ** លើធ្នឹម (ដង្កៀប) **កត្វា** ធ្វើហើយ **តំ មញ្ចំ** នូវគ្រែនោះ **អដ្ដំ** ឱ្យជារាន **បរិភុញ្ជតិ** ប្រើប្រាស់ចុះ ។ សម្ពន្ធ **ភិក្ខុ** សយកត្តា ក្នុង **បរិភុញ្ជតិ** ៗ ជាអាខ្យាតបទ កត្តុវាចកៈ **ឧក្ខិបិត្វា** ក្តី **ឋបេត្វា** ក្តី **កត្វា** ក្តី ជាបុព្វកាល-កិរិយាក្នុង **បរិភុញ្ជតិ** , **តុលាសង្ឃាដេ** ជាឧបសិលេសិកាធារៈក្នុង

**ថបេត្វា** , **តំ** វិសេសនៈរបស់ **មញ្ចំ** ៗ ជា បកតិអវុត្តកម្មក្នុង **កត្វា** , **អដ្ដំ** វិកតិអវុត្តកម្មក្នុង **កត្វា** ។ នៅក្នុង គម្ពីរកង្ខា-វិតរណី អភិនវដីកា ឈ្មោះ វិនយត្ថមញ្ជូសា ទំព័រ ៤៥៥ មាន ប្រយោគវិកតិអវុត្តកម្មនេះដែរ ហើយក៏មានបាលីស្រដៀងគ្នាដែរគឺ **ឧក្ខិបិត្វា តុលាសង្ឃាតេ**(១) **ថបេត្វា អដ្ដំ កត្វា ។** ចំណែកការប្រែនិងសម្ពន្ធសូមអ្នកសិក្សាប្រែតាមសេចក្តីខាងលើនិង សម្ពន្ធតាមនោះចុះ ។

ឧ.ទី ៧ **កម្មវាចាបរិយោសានេ សីមា បថវិសន្ធារ-ឧទកំ បរិយន្តំ កត្វា ឱតរតិ** (សមន្ត. ៣/១១៤) ។ **កម្មវាចាបរិយោសានេ** ក្នុងកាលជាទីបំផុតនៃកម្មវាចា **សីមា** វិសីមា **កត្វា** ធ្វើហើយ **បថវិសន្ធារឧទកំ** នូវទឹកដែលទ្រផែនដី **បរិយន្តំ** ឱ្យជាទីបំផុត **ឱតរតិ** តែងធ្លាក់ចុះទៅ ។ សម្ពន្ធ **កម្មវាចាបរិយោសានេ** កាលត្ថសត្តមី **សីមា** សយកត្តា ក្នុង **ឱតរតិ**ៗ ជាអាខ្យាតបទកត្តុវាចកៈ **បថវិសន្ធារឧទកំ** ជាបកតិ-អវុត្តកម្ម ក្នុង **កត្វា** , **បរិយន្តំ** ជាវិកតិអវុត្តកម្ម ក្នុង **កត្វា** ៗ ជាបុព្វកាលកិរិយាក្នុង **ឱតរតិ** ។

---

(១) នៅក្នុង ដីកា មានបាឋៈបាលី គឺ **តុលាសង្ឃាតេ** យ៉ាងនេះ ខ្ញុំទុកថែរក្សាតាមច្បាប់ដើម

ឧ.ទី ៨ នៅក្នុងគម្ពីរធម្ម.រូបនន្ទាថេរីវត្ថុ (៥/១៦៣) មានប្រយោគវិកតិអវុត្តកម្មយ៉ាងនេះ **អថ សត្ថា តំ ព្យាធិនា អភិភូតំ កត្វា ទស្សេសិ** ។ ប្រែដូច្នេះ **អថ** គ្រានោះ **សត្ថា** វី ព្រះសាស្តា **ទស្សេសិ** ទ្រង់សំដែងហើយ **តំ រូបំ** នូវរូបនោះ **កត្វា** ធ្វើ **ព្យាធិនា អភិភូតំ** ឱ្យជាធម្មជាតគឺព្យាធិបៀតបៀនហើយ ។ សម្ពន្ធ. **អថ** កាលត្ថសត្តមី **សត្ថា** សយកត្តា ក្នុង **ទស្សេសិ** ៗ អាខ្យាតបទ កត្តុវាចកៈ, **តំ** វិសេសនៈរបស់ **រូបំ** ៗ បកតិអវុត្តកម្មក្នុង **ទស្សេសិ** , **ព្យាធិនា** អនភិហិតកត្តាក្នុង **អភិភូតំ** ៗ វិកតិអវុត្តកម្ម ក្នុង **កត្វា** ៗ កិរិយាវិសេសនៈ ក្នុង **ទស្សេសិ** ។

ឧ.ទី ៩ **ឥមិស្សា សាលាយ មំ ជេដ្ឋកំ ករោហិ** (ធម្មបទដ្ឋកថា ២/១៦៩) ។

ប្រែ. **ត្វំ** វីអ្នក **ករោហិ** ចូរធ្វើ **មំ** នូវខ្ញុំ **ជេដ្ឋកំ** ឱ្យជាចម្បង **សាលាយ** នៃសាលា **ឥមិស្សា** នេះ ។ សម្ពន្ធ **ត្វំ** សយកត្តា ក្នុង **ករោហិ** ៗ អាខ្យាតបទ កត្តុវាចកៈ **ឥមិស្សា** វិសេសនៈរបស់ **សាលាយ** ៗ សាមិសម្ពន្ធៈក្នុង **ជេដ្ឋកំ** , **មំ** បកតិអវុត្តកម្ម

ក្នុង **ករោហិ** , **ជេដ្ឋកំ** ជាវិកតិអវុត្តកម្ម ក្នុង **ករោហិ** ។

ឧ.ទី ១០ **សម្មាសម្ពុទ្ធោ សក្កស្ស សម្បត្តឹ មហតឹ កត្វា កថេសិ** ( ធម្ម.២/១៦១ ) ។ ប្រែ. **សម្មាសម្ពុទ្ធោ** វី ព្រះសម្មាសម្ពុទ្ធ **កថេសិ** ទ្រង់សំដែងហើយ **កត្វា** ធ្វើ **សម្បត្តឹ** នូវសម្បត្តិ **សក្កស្ស** របស់ស្តេចសក្កៈ **មហតឹ** ឱ្យធំធេង ។ សម្ពន្ធ. **សម្មាសម្ពុទ្ធោ** ជា សយកត្តា ក្នុង **កថេសិ** ៗ ជា អាខ្យាតបទ កត្តុវាចកៈ , **សក្កស្ស** សាមិសម្ពន្ធៈក្នុង **សម្បត្តឹ ៗ** បកតិអវុត្តកម្មក្នុង **កត្វា** ,**មហតឹ** វិកតិអវុត្តកម្មក្នុង **កត្វា** ៗ កិរិយាវិសេសនៈ របស់ **កថេសិ** ។

ឧ.ទី ១១ **សបុត្តទារំ មំ តវ គេហេ ទាសំ ករោហិ** ( ធម្ម.អជគរបេតវត្ថុ ៥/៩០ ) ។ ប្រែដូច្នេះ **ត្វំ** វីលោក **ករោហិ** ចូរធ្វើ **មំ** នូវខ្ញុំ **សបុត្តទារំ** ប្រព្រឹត្តទៅមួយអន្លើដោយកូន និងប្រព័ន្ធ **ទាសំ** ឱ្យជាខ្ញុំបំរើ **គេហេ** ក្នុងផ្ទះ **តវ** របស់លោក ។ សម្ពន្ធ **ត្វំ** សយកត្តា ក្នុង **ករោហិ** ៗ អាខ្យាតបទ កត្តុវាចកៈ **សបុត្តទារំ** ជាវិសេសនៈរបស់ **មំ** ៗ បកតិអវុត្តកម្មក្នុង **ករោហិ** **ទាសំ** វិកតិអវុត្តកម្ម ក្នុង **ករោហិ** , **តវ** សាមិសម្ពន្ធៈក្នុង

**គេហេ** ៗ វេសយិកាធារៈក្នុង **ករោហិ** ។

## ប្រយោគវិកតិអវុត្តកម្មចូលនឹងចរធាតុ

ចំពោះវិកតិអវុត្តកម្មមានចូលជាមួយ **ចរធាតុ** ដូចដែលខ្ញុំពោលខាងដើមរួចហើយដូចតទៅនេះ ៖

នៅក្នុងគម្ពីរធម្មបទដ្ឋកថា ( សុទ្ធោទនវត្ថុ ភាគ ៦ ទំព័រ ៤៧ ) ព្រះដ៏មានព្រះភាគទ្រង់សំដែងគាថាថា ៖

**ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ** ។ នៅក្នុងគម្ពីរធម្មបទវិវរណៈទំព័រ ១៥៦ ខែពន្យល់ថា **នរោ ធម្មំ សុចរិតំ** <u>**ចរេ**</u> **ចរេយ្យ នរោ** <u>**តំ**</u> **ធម្មំ ទុច្ចរិតំ ន ចរេ** ។ ប្រែថា **នរោ** វីនរៈ **ចរេ** គប្បីប្រព្រឹត្ត **ធម្មំ** នូវធមិ **សុចរិតំ** ឱ្យជាសុចរិត , **នរោ** វីនរៈ **ន ចរេយ្យ** មិនគប្បីប្រព្រឹត្ត **តំ ធម្មំ** នូវធមិនោះ **ទុច្ចរិតំ** ឱ្យជាទុច្ចរិតទេ ។ សម្ពន្ធ **នរោ** សយកត្តាក្នុង **ចរេ** ៗ អាខ្យាតបទ កត្តុវាចកៈ **ធម្មំ** បកតិអវុត្តកម្ម ក្នុង **ចរេ** , **សុចរិតំ** វិកតិអវុត្តកម្ម ក្នុង **ចរេ** ។ **នរោ** សយកត្តាក្នុង **ន ចរេ, ន** បដិសេធក្នុង **ចរេ** ៗ អាខ្យាតបទ កត្តុវាចកៈ **តំ** វិសេសនៈរបស់ **ធម្មំ** ៗ បកតិអវុត្តកម្មក្នុង **ន ចរេ** , **ទុច្ចរិតំ**

វិកតិអវុត្តកម្ម ក្នុង **ន ចរេ** ។

## ប្រយោគវិកតិអវុត្តកម្មក្នុងកម្មវាចកៈ

កេចិអាចារ្យខ្លះពោលថាប្រយោគវិកតិអវុត្តកម្មនេះប្រើបានតែប្រយោគកត្តុវាចកៈតែម្យ៉ាងគត់ ក្រៅពីនោះមិនបានទេ តែពាក្យនោះមិនត្រូវឡើយព្រោះក្នុងគម្ពីរអដ្ឋកថា ដីកា បានប្រើប្រយោគវិកតិអវុត្តកម្មនេះក្នុងកម្មវាចកៈនិងភាវវាចកៈច្រើនសន្ធឹកសន្ធាប់ ។

ចំណាំប្រយោគដែលជាកម្មវាចកៈប្រធានដែលប្រែថា **"វី"** សម្ពន្ធថា **វុត្តកម្ម** កាលណាចូលក្នុងប្រយោគ វិកតិអវុត្តកម្ម មកជាមួយត្រូវផ្លាស់ថា **បកតិវុត្តកម្ម** វិញ ។

ឧ.ទី ១ **សោ គាមោ តស្សាយេវ នហានមូលំ កត្វា ទិន្នោ** ( ធម្ម.បសេនទិកោសលវត្ថុ ៦/១៩២ ) ។ ប្រែ **សោ គាមោ** វីស្រុកនោះ **មយា** គឺអញ **ទិន្នោ** ឱ្យហើយ **តស្សាយ ឯវ** ដល់នាងនោះឯង **កត្វា** ធ្វើ **នហានមូលំ** ឱ្យជាតម្លៃសម្រាប់ងូត ។ សម្ពន្ធ **សោ** វិសេសនៈរបស់ **គាមោ** ៗ បកតិ-វុត្តកម្មក្នុង **ទិន្នោ** ៗ កិតបទកម្មវាចកៈ,**ឯវ** ស័ព្ទ អវធារណត្ថៈក្នុង **តស្សាយ** ៗ ជាសម្បទានក្នុង **ទិន្នោ** , **នហានមូលំ** វិកតិអវុត្ត-

កម្ម ក្នុង **កត្វា** ៧ ជា កិរិយាវិសេសនៈ ក្នុង **ទិន្នោ** ។

ឧ.ទី ២ **ចីវរទានាទិភេទំ ពហុំ កុសលំ កត្តព្វំ** (ធម្ម.វិសាខាវត្ថុ ៣/១២៩) ។ ប្រែ **កុសលំ** វិកុសល **ចីវរទា-នាទិភេទំ** ដែលផ្សេងដោយកុសលមានចីវរទានជាដើម **បុគ្គលេន** គឺបុគ្គល **កត្តព្វំ** គប្បីធ្វើ **ពហុំ** ឱ្យច្រើន ។ សម្ពន្ធ **ចីវរទា-នាទិភេទំ** វិសេសនៈរបស់ **កុសលំ** ៧ បកតិវុត្តកម្ម ក្នុង **កត្តព្វំ** ៧ កិតបទកម្មវាចកៈ, **បុគ្គលេន** អនភិហិតកត្តា ក្នុង **កត្តព្វំ** , **ពហុំ** វិកតិអវុត្តកម្ម ក្នុង **កត្តព្វំ** ។ អាចារ្យខ្លះថា **ពហុំ** ជាកិរិយា-វិសេសនៈដូច្នេះក៏មាន ។

## ប្រយោគវិកតិអវុត្តកម្មចុះក្នុងនាមវាចកៈ

ឧ.ទី ១ **ន សក្កា អគារំ អជ្ឈាវសន្តេន សង្ខ-លិខិតំ ព្រហ្មចរិយំ ចរិតុំ** ។ (ធម្ម. ៨/២២១ សុន្ទរសមុទ្ទ-ត្ថេរវត្ថុ)ប្រែថា **បុគ្គលេន** គឺបុគ្គល **អជ្ឈាវសន្តេន** ដែលនៅគ្រប់គ្រង **អគារំ** នូវផ្ទះ **ន សក្កា** មិនអាច **ចរិតុំ** ដើម្បីប្រព្រឹត្ត **ព្រហ្មចរិយំ** នូវព្រហ្មចរិយៈ **សង្ខលិខិតំ** ឱ្យដូចជាស័ង្ខដែលគេខាត់ល្អទេ ។ សម្ពន្ធ **អជ្ឈាវសន្តេន** វិសេសនៈរបស់

**បុគ្គលេន** ៗ អនភិហិតកត្តា ក្នុង **ន សក្កា** , **ន** បដិសេធ ក្នុង **សក្កា** ៗ កិតបទភាវវាចកៈ , **ព្រហ្មចរិយំ** បកតិអវុត្តកម្មក្នុង **ចរិតុំ** ៗ ជាតុមត្ថសម្បទាន ក្នុង **ន សក្កា** , **សង្ខលិខិតំ** វិកតិ-អវុត្តកម្ម ក្នុង **ចរិតុំ** ។

**<u>ប្រយោគវិកតិអវុត្តកម្មឈ្មោះឧបមាវិកតិអវុត្តកម្ម</u>**

ឈ្មោះនេះសម្រាប់ហៅ សម្ពន្ធស័ព្ទ ដែលជាវិកតិអវុត្តកម្ម ដូចពោលខាងដើមនោះឯង ផ្សេងតែលោកប្រើ **ឥវ** ឬ **វិយ** ស័ព្ទ ជាតួគួបបទ វិកតិអវុត្តកម្មប៉ុណ្ណោះ នឹងចូលជាមួយ **ករធាតុ** ឬ (**ចរធាតុ**តែមានតិច) វេលាប្រែត្រូវប្រែថា ឱ្យជាអ្នកប្រហែលនឹងថា ... ឱ្យជាគុណជាតត្រឹមតែថា ... ហៅឈ្មោះសម្ពន្ធថា **ឧបមា-វិកតិអវុត្តកម្ម** ។

ឧ.ទី ១ **ឯកោ តេន កតំ វត្ថុំ អត្តនា កតំ វិយ (កត្វា ) ទស្សេន្តោ មុខោទកទន្តកដ្ឋានំ បដិយាទិតភាវំ ញត្វា... វទតិ** ( ធម្ម.មហាកស្សបត្ថេរស្ស សទ្ធិវិហារិកវត្ថុ ៣/១៩៣ ) ។ ប្រែថា **ឯកោ សទ្ធិវិហារិកោ** វិសទ្ធិវិហារិកមួយ **ទស្សេន្តោ** កាលសំដែង **តេន សទ្ធិវិហារិកេន កតំ វត្ថុំ**

នូវវត្តដែលសទ្ធិវិហារិកនោះធ្វើហើយ **កត្វា** ធ្វើ **អត្តនា កតំ វត្តំ វិយ** ឱ្យជាអ្នកប្រហែលនឹងថា នូវវត្តដែលខ្លួនធ្វើហើយ **ញត្វា** ដឹងហើយ **មុខោទកទន្តកដ្ឋានំ បដិយាទិតភាវំ** នូវភាវៈនៃទឹក លុបព្រះភក្ត្រនិងឈើស្ទន់ ដែលចាត់ចែងហើយ... ។ សម្ពន្ធដូច្នេះ **ឯកោ** វិសេសនៈរបស់ **សទ្ធិវិហារិកោ** ៗ ជាសយកត្តា ក្នុង **វទតិ** ៗ អាខ្យាតបទ កត្តុវាចកៈ , **តេន** វិសេ-សនៈរបស់ **សទ្ធិវិហារិកេន** ៗ អនភិហិតកត្តា ក្នុង **កតំ** ៗ វិសេ-សនៈរបស់ **វត្តំ** ៗ អវុត្តកម្ម ក្នុង **ទស្សេន្តោ** , **អត្តនា** អនភិហិ-តកត្តា ក្នុង **កតំ** ៗ វិសេសនៈរបស់ **វត្តំ** ៗ ឧបមារិកតិអវុត្តកម្ម ក្នុង **កត្វា** , **វិយ** ស័ព្ទ ឧបមាជោតកៈ ក្នុង **អត្តនា កតំ វត្តំ** , **កត្វា** កិរិយាវិសេសនៈ ក្នុង **ទស្សេន្តោ** ៗ អព្ភន្តរកិរិយា របស់ **សទ្ធិវិហារិកោ** , **មុខោទកទន្តកដ្ឋានំ** ភាវាទិសម្ពន្ធៈ ក្នុង **បដិយាទិតភាវំ** ៗ អវុត្តកម្ម ក្នុង **ញត្វា** ៗ បុព្វកាលកិរិយា ក្នុង ... **វទតិ** ។

ឧទាហរណ៍ខាងលើនេះឯងអាចារ្យខ្លះ លោកប្រែបែបជាឧបមាវិសេសនៈវិញ គឺប្រែថា **ឯកោ** (**សទ្ធិវិហារិកោ**) វិសទ្ធិ-

វិហារិកមួយរូប **ទស្សេន្តោ** កាលសំដែង **វត្តំ** នូវវត្ត **តេន** (**សទ្ធិវិហារិកេន**) **កតំ** ដែលសទ្ធិវិហារិកនោះធ្វើហើយ **អត្តនា កតំ វិយ** ដូចជាវត្តដែលខ្លួនធ្វើហើយ ...។ **...កតំ** ជាឧបមាវិ-សេសនៈ របស់ **វត្តំ** , **វិយ** ស័ព្ទ ជាឧបមាជោតកៈ ក្នុង **កតំ ...**។

ចំពោះប្រយោគឧបមាវិកតិអវុត្តកម្មនេះមានច្រើនពេកណាស់នៅក្នុងគម្ពីរ ធម្មបទដ្ឋកថា អដ្ឋកថា ដីកា យោជនា តែខ្ញុំមិនបានលើកយកមកពន្យល់ក្នុងទីនេះ ឱ្យបានវែងឆ្ងាយទេ សូមកុលបុត្រអ្នកសិក្សាពិចារណាតាមប្រយោគខាងលើនេះហើយ គិតវិនិច្ឆ័យឱ្យត្រឹមត្រូវហើយកាន់យកចុះ ។

## ចប់ប្រយោគវិកតិវុត្តកម្មនិងវិកតិអវុត្តកម្ម ដោយសង្ខេប

# ប្រយោគសម្ភាវន:

ប្រយោគសម្ភាវនៈនេះស្រដៀងគ្នានឹងប្រយោគវិកតិវុត្តកម្ម និងវិកតិអវុត្តកម្ម ដែលពោលខាងដើមមកហើយ, ប្រយោគនេះអាចធ្វើឱ្យអ្នកសិក្សាខ្លះច្រឡំគ្នាទៀតផង បើគិតមិនដល់ ព្រោះហេតុនោះ ទើងខ្ញុំរៀងដាក់តាមលំដាប់ប្រយោគវិកតិវុត្តកម្មនិងវិកតិអវុត្តកម្មនេះ ។ ប្រយោគនេះជា គុណនាមក្តី ជានាមនាមក្តី តែប្រើប្រហែលគុណនាមដែរ ហើយគ្រឿងចំណាំក្នុងប្រយោគជាកត្តុវាចកៈប្រកបដោយទុតិយាវិភត្តិ , ចំណែកប្រយោគកម្មវាចកៈប្រកបដោយបឋមាវិភត្តិ ហើយប្រែថា ថា ,ថាជា ថាដឹង , ថាពោល ប្រហែលនឹងវិកតិអវុត្តកម្មរហូតកេចិអាចារ្យខ្លះច្រឡំថាជាប្រយោគវិកតិអវុត្តកម្ម ។ តាមពិតប្រយោគសម្ភាវនៈនេះផ្សេងពីប្រយោគវិកតិអវុត្តកម្ម ដោយថា ប្រយោគនេះមាន ដូចសម្ភាវនបុព្វបទកម្មធារយសមាសឬមិនមាន **ករធាតុ** និង **ចរធាតុ** សម្រាប់សម្ពន្ធចូលជាមួយ បើវិកតិវុត្តកម្មវិញត្រូវតែប្រកបដោយ **ឥរធាតុ** នៅទីនោះហើយ **ឥរធាតុ** នោះត្រូវជា បឋមាវិភត្តិ និងជា

ប្រយោគកម្មវាចកៈតែម្យ៉ាងដូច **អការកោ**ជាដើម ។

**ប្រយោគសម្ពាទនៈក្នុងកត្តុវាចកៈ**

ឧ.ទី ១ **អត្តានញ្ចេ បិយំ ជញ្ញា** ( ធម្ម.ពោធិរាជ-កុមារ. ៦/៦, សំយុត្តនិកាយ កោសលសំយុត្ត .បិយសូត្រ ២៩/១៩៧) ។ ប្រែថា **ចេ** ប្រសិនបើ **បុគ្គលោ** រីបុគ្គល **ជញ្ញា** គប្បីដឹង **អត្តានំ** នូវខ្លួន **បិយំ** ថាជាទីស្រលាញ់ ។ សម្ពន្ធ. **ចេ** បរិកប្បត្ថៈ **បុគ្គលោ** សយកត្តា ក្នុង **ជញ្ញា** ៗ អាខ្យាត-បទ កត្តុវាចកៈ **អត្តានំ** អវុត្តកម្មក្នុង **ជញ្ញា** , **បិយំ** សម្ពាទនៈ ក្នុង **ជញ្ញា** ។ នេះជាគុណនាម ។

ឧ.ទី ២ **តមហំ ព្រូមិ ព្រាហ្មណំ** ។ (កីសាគោតមី ៨/១៧១ )ប្រែថា **អហំ** រី តថាគត **ព្រូមិ** ពោល **តំ បុគ្គលំ** នូវបុគ្គលនោះ **ព្រាហ្មណំ** ថាជាព្រាហ្មណ៍ ។ សម្ពន្ធដូច្នេះ **អហំ** សយកត្តា ក្នុង **ព្រូមិ** ៗ អាខ្យាតបទ កត្តុវាចកៈ **តំ** វិសេសនៈរបស់ **បុគ្គលំ** ៗ អវុត្តកម្ម ក្នុង **ព្រូមិ** , **ព្រាហ្មណំ** សម្ពាទនៈ ក្នុង **ព្រូមិ** ។ នេះជានាមនាម ។

ឧ.ទី ៣ **សត្ថា បដាចារំ តនុភូតសោកំ ញត្វា** ។

(ធម្ម. បដាចារាវត្ថុ ៧/១២៨) ប្រែថា **សត្ថា** វ៉ព្រះសាស្តា **ញត្វា** ទ្រង់ដឹងហើយ **បដាចារំ** នូវនាងបដាចារ **តនុភូត-សោកំ** ថាមានសោកស្វាងហើយ ។ សម្ពន្ធដូច្នេះ **សត្ថា** សយកត្តា ...**បដាចារំ** អវុត្តកម្មក្នុង **ញត្វា** ៗ បុព្វកាលកិរិយា ...**តនុភូត-សោកំ** សម្ភាវនៈក្នុង **ញត្វា** ។

## ប្រយោគសម្ភាវនៈក្នុងកម្មវាចកៈ

ឧ.ទី ១ **វិរាគោ តេសំ ធម្មានំ អគ្គមក្ខាយតិ** ។ (ធម្ម. បញ្ចសតភិក្ខុ ៧/១៩០) ប្រែថា **ធម្មានំ** បណ្តាធម៌ទាំងឡាយ **តេសំ** នោះ **វិរាគោ** វ៉វិរាគៈ **បណ្ឌិតេន** គឺបណ្ឌិត **អក្ខាយតិ** ពោល **អគ្គំ** ថាលើស ។ សម្ពន្ធ **តេសំ** វិសេសនៈរបស់ **ធម្មានំ** ៗ ឆដ្ឋីនិទ្ធារណៈ ,**វិរាគោ** បឋមានិទ្ធារណីយៈរបស់ **ធម្មានំ** និងជាវុត្តកម្មក្នុង **អក្ខាយតិ** ៗ អាខ្យាតបទកម្មវាចកៈ **អគ្គំ** សម្ភាវនៈក្នុង **អក្ខាយតិ** ។ (សូមបញ្ជាក់ **អគ្គំ** នេះ ជាបឋមាវិភត្តិ មិនមែនទុតិយាវិភត្តិទេ ដូចពាក្យនៅក្នុងគម្ពីរ អភិធម្មត្ថវិភាវិនីដីកាថា **តថាគតោ តេសំ អគ្គមក្ខាយតិ** , យោជនាប្រាប់ថា **អគ្គំ** បានដល់ **អគ្គោ** ។ នេះជាគុណនាម ។

ឧ.ទី ២ **អមតំ វុច្ចតិ និព្វានំ** ។ ( ធម្ម. សាមាវតីវត្ថុ ១/១១១) ប្រែថា **និព្វានំ** រីព្រះនិព្វាន **វុច្ចតិ** គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅ **អមតំ** ថា អមតៈ ។ សម្ពន្ធ **និព្វានំ** វុត្តកម្មក្នុង **វុច្ចតិ** ៗ អាខ្យាតបទ កម្មវាចកៈ **តថាគតេន** អនភិហិតកត្តាក្នុង **វុច្ចតិ** , **អមតំ** សម្ភាវនៈ ក្នុង **វុច្ចតិ** ។

ឧ.ទី ៥ **នេបក្កំ វុច្ចតិ បញ្ញា** ។ ( វិសុទ្ធិមគ្គ ១/៥ ) ប្រែថា **បញ្ញា** រី បញ្ញា **វុច្ចតិ** គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅ **នេបក្កំ** ថា **នេបក្កះ** ។ សម្ពន្ធដូចគ្នាខាងលើគ្រាន់តែដឹងថា **នេបក្កំ** ជាសម្ភាវនៈក្នុង **វុច្ចតិ** ។

ឧ.ទី ៦ **មន្តា វុច្ចតិ បញ្ញា** ។ ( ធម្ម.កោកាលិក-ភិក្ខុ ៨/៨៣ ) ប្រែថា **បញ្ញា**រីបញ្ញា **វុច្ចតិ** គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅ **មន្តា** ថា **មន្តា** ។ **មន្តា** នេះជាសម្ភាវនៈក្នុង **វុច្ចតិ** ។

សាកល្បងប្រែប្រយោគនេះមើល ៖

**ធោនា វុច្ចតិ បញ្ញា** ( នេត្តិដីកា សាសនប្បដ្ឋានវារ-វណ្ណនា ទំព័រ ១៥៦ )

ឧ.ទី ៧ **វានំ វុច្ចតិ តណ្ហា** ( មង្គលត្ថ. ៤/២៣៣ ) ។ ប្រែ **តណ្ហា** វីតណ្ហា **វុច្ចតិ** គឺលោកហៅ **វានំ** ថា វានៈ ។ **វានំ** ជាសម្ភាវនៈក្នុង **វុច្ចតិ** ។

ប្រយោគសម្ភាវនៈមានច្រើនណាស់នៅក្នុង អដ្ឋកថា ដីកា យោជនា បានជាឱ្យឈ្មោះថា សម្ភាវនៈ ព្រោះលើកឡើងដូច សម្ភាវនបុព្វបទកម្មធារយសមាស , ដោយន័យនេះ ពាក្យថា សម្ភាវនៈក្នុងទីនេះមិនសំដៅសរសើរជាគួតិះដៀលទេ សំដៅត្រឹម លើកឡើងដូចកម្មធារយសមាសប៉ុណ្ណោះ , ម្យ៉ាងទៀត ប្រយោគ នេះក្នុងយោជនាខ្លះហៅថា **អាការៈ** ព្រោះ ប្រែថា “**ថា**” ដូច **ឥតិ** ស័ព្ទដែលជាអាការៈ ។ ដូចប្រយោគថា **តថាគតោ តេសំ អគ្គមក្ខាយតិ** នោះ យោជនា សម្ពន្ធថា **អគ្គំ** ជាអាការៈក្នុង **អក្ខាយតិ** ។ ឧទាហរណ៍នេះខ្លីពេក តែសូមកុលបុត្រអ្នកសិក្សា សង្កេតពិនិត្យក្នុងអដ្ឋកថា ដីកា ហើយឃើញដូចប្រយោគខាងដើម ប្រៀបធៀបគ្នានឹងឧទាហរណ៍ដែលបានលើកមកជាសាធកៈ ហើយ ប្រែពិនិត្យឱ្យបានត្រឹមត្រូវតាមប្រយោគនេះផង ។

**ចប់ប្រយោគសម្ភាវនៈដោយសង្ខេប**

## ប្រយោគសញ្ញាវិសេសនៈ-សញ្ញីវិសេសយៈ

## (ឬហៅសង្ខេបថា សញ្ញា-សញ្ញី )

ពាក្យថា សញ្ញាវិសេសនៈ នេះ សម្រាប់ហៅ បទគុណនាម ដូចគ្នា តែជាវិសេសនៈ បញ្ជាក់ដល់ឈ្មោះ, ហើយវេលាប្រែមាន ពាក្យអែបសម្រួលថា "**ឈ្មោះ**" ឬ"**ឈ្មោះថា** " ចូលមកផង ។ គុណនាមបទនេះ ជាប់ទាក់ទងសំដែងឈ្មោះរបស់មនុស្ស សត្វ ទីកន្លែង ទ្រព្យ របស់ ។ កាលបើមានបទមួយជាសញ្ញាវិសេសនៈ ដូច្នេះ បទនាមនាមដែលជាម្ចាស់របស់នេះ ត្រឡប់ឱ្យហៅថា "សញ្ញីវិសេសយៈ" ត្រូវសម្ពន្ធបទ សញ្ញាវិសេសនៈនោះចូលជាមួយ បទនាមនាមដែលជាម្ចាស់របស់ៗត្រូវទទួលថា សញ្ញីវិសេសយៈ ហើយបើមានបទត្រូវសម្ពន្ធចូលមកទៀត ដូច សយកត្តា ជាដើម ត្រូវសម្ពន្ធមកទៀតផង ។

កេចិអាចារ្យខ្លះថា ប្រយោគសញ្ញាវិសេសនៈបានសម្រាប់ តែសញ្ញាវិសេសនៈដែលមិនមាន **នាមស័ព្ទ** បើមាននាមស័ព្ទនៅ ជាមួយឱ្យសម្ពន្ធជាវិសេសនៈធម្មតា ដូចពាក្យថា **កស្សបោ នាម ថេរោ** "ព្រះថេរៈព្រះនាម កស្សបៈ" ក្នុងទីដែលមាននាមស័ព្ទ

នៅកំដរផងដូច្នេះ ក៏ហៅតាមវិសេសនៈធម្មតាទៅ, ដូចយ៉ាង **កស្សបោ** ក្នុងទីនេះ ត្រូវសម្ពន្ធថា វិសេសនៈរបស់ **ថេរោ** , តែពាក្យកេចិអាចារ្យនោះ បណ្ឌិតអ្នកឈ្លាសក្នុងនិរុត្តិសាស្ត្រមិនទទួលព្រមទេ ព្រោះមានគ្រឿងអាងជាច្រើនក្នុងគម្ពីរយោជនានៃ អភិធម្មត្ថវិភាវិនីដីកា ព្រះគន្ថរចនាចារ្យបានបញ្ជាក់ច្បាស់ថា មាន **នាមស័ព្ទ** នៅជាមួយក៏ជាប្រយោគសញ្ញាវិសេសនៈ-សញ្ញីវិសេសយៈដែរ ឧ. **ហេតុសម្បទា នាម មហាករុណាសមាយោគោ ពោធិសម្ភារសម្ភរណញ្ច ។** ( អភិ.វិ.បឋមបរិច្ឆេទ. ទំព័រ ៦៤ ) ការប្រកបព្រមដោយមហាករុណានិងការបំពេញធម៌ជាគ្រឿងឧបត្ថម្ភដល់ការត្រាស់ដឹង ឈ្មោះថា **ហេតុសម្បទា** ។ យោជនា (១/១១២) ថា **ហេតុសម្បទា នាមាតិ (បទំ) សញ្ញា ,មហាករុណាសមាយោគោ ពោធិសម្ភារសម្ភរណញ្ចាតិ បទទ្វយំ សញ្ញី ។** ដូច្នេះ តាមក្នុងយោជនាបានបញ្ជាក់មកហើយ ធ្វើឱ្យអ្នកសិក្សាក្នុងប្រយោគបានជ្រាបថា ទោះបីមាននាមស័ព្ទក៏ដោយ មិនមានក៏ដោយ ជាប្រយោគសញ្ញាវិសេសនៈ-សញ្ញីវិសេសយៈបានទាំងអស់ ។ កាលបើយើងពិចារណា

ន័យដទៃទៀត ក៏គង់ឃើញច្បាស់ថា ពាក្យថា **សញ្ញាវិសេសនៈ** សំដៅសេចក្តីថា វិសេសនៈដែលជាឈ្មោះ គឺបទវិសេសនៈនោះជាឈ្មោះ ដោយន័យនេះនឹងមានសញ្ញាជោតកៈនៅជាមួយក៏ដោយ មិនមានក៏ដោយ បទវិសេសនៈ ដែលជាឈ្មោះនោះ ក៏គង់នៅហៅថា **សញ្ញាវិសេសនៈ** ។

ឧ.ទី ១ **កស្សបោ ភគវា** (អញ្ញតរបុរិស.៣/១៧៩) ប្រែ. **ភគវា** វិព្រះដ៏មានព្រះភាគ **កស្សបោ** ព្រះនាមកស្សបៈ ។ សម្ពន្ធដូច្នេះ **កស្សបោ** សញ្ញាវិសេសនៈរបស់ **ភគវា** ៗ ជាសញ្ញីវិសេសយៈនិងជា... ។

ឧ.ទី ២ **រាជា បសេនទិកោសលោ ។** (ចូឡេក-សាជក.៥/៣) ព្រះរាជាទ្រង់ព្រះនាមបសេនទិកោសល ។ **បសេ-**នទិកោសលោ ជាសញ្ញាវិសេសនៈរបស់ រាជា ៗ ជាសញ្ញីវិសេស-យៈ ។

ឧ.ទី ៣ **បទុមុត្តរោ នាម ពុទ្ធោ** (ធម្មបទ.វិសាខ-វត្ថុ ៣/១២៦) ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ។ **នាម** ស័ព្ទសញ្ញាជោតកៈ **បទុមុត្តរោ** សញ្ញាវិសេសនៈរបស់ **ពុទ្ធោ** ៗ ជា

សញ្ញីវិសេសយៈនិងជា... ។

ឧ.ទី ៤ **គោតមោ នាម ពុទ្ធោ** (វិសាខ.៣/១២៧) ព្រះពុទ្ធទ្រង់ព្រះនាមគោតម សម្ពន្ធដូចខាងលើ ។

ឧ.ទី ៥ **អនុបិយំ នាម មល្លានំ និគមោ** (ទេវទត្ត-វត្ថុ ១/១៩៥) និគមរបស់មល្លក្សត្រទាំងឡាយ ឈ្មោះថា **អនុ-បិយៈ** ។ **នាម** ស័ព្ទ ជាសញ្ញាជោតកៈ **អនុបិយំ** សញ្ញាវិសេ-សនៈរបស់ **និគមោ** ៗ ជាសញ្ញីវិសេសយៈនិងជា... **មល្លានំ** សាមិសម្ពន្ធៈក្នុង **និគមោ** ។

ឧ.ទី ៦ **លិច្ឆវិកុមារោ មហាលិ នាម** (វិឌូឌភ-វត្ថុ ៣/៧) លិច្ឆវិកុមារ ឈ្មោះ មហាលិ ។ សម្ពន្ធដូចគ្នាខាងដើមនោះឯង ។

ឧ.ទី ៧ **បច្ចយានំ ធម្មេន សមេន ឧប្បត្តិ បច្ចយ-សម្បទា នាម** ។ (ធម្ម.៥/១៣៣) ប្រែ ការកើតឡើងនៃបច្ច័យទាំងឡាយ ដោយធម៌ដ៏ស្មើ ឈ្មោះថា **បច្ចយសម្បទា** ។ **សមេន** វិសេសនៈរបស់ **ធម្មេន** ៗ ជាករណៈក្នុង **ឧប្បត្តិ**, **បច្ចយានំ** សាមិសម្ពន្ធ ក្នុង **ឧប្បត្តិ**, **នាម** ស័ព្ទ ជាសញ្ញាជោតកៈ,

**បច្ចយសម្បទា** ជាសញ្ញាវិសេសនៈរបស់ **ឧប្បត្តិ** ៗ ជាសញ្ញីវិ-សេសយៈនិងជាលិង្គត្ថ ។

ឧ.ទី ៨ **ឧទ្ទេសាចរិយោ នាម ធម្មាចរិយោ ។** (មង្គលត្ថទីបនី ៤/៧) ។ ធម្មាចារ្យ ឈ្មោះថា ឧទ្ទេសាចារ្យ ។ **នាម** ស័ព្ទជាសញ្ញាជោតកៈ, **ឧទ្ទេសាចរិយោ** ជាសញ្ញាវិសេសនៈរបស់ **ធម្មាចរិយោ** ៗ ជាសញ្ញីវិសេសយៈ ។

ឧ.ទី ៩ **ចិន្តនមត្តំ ចិត្តំ** (អភិ.វិ.បឋមបរិច្ឆេទ.ទំព័រ ៦៦) ធម្មជាតត្រឹមតែគិត ឈ្មោះថា **ចិត្ត** ។ **ចិត្តំ** ជាសញ្ញាវិសេស-នៈរបស់ **ចិត្តនមត្តំ** ៗ ជា សញ្ញីវិសេសយៈនិងជាលិង្គត្ថៈ ។

បទវិសេសនៈដែលជាឈ្មោះ ប្រើស័ព្ទនាមនាមជាផ្ទៃ ដូចតួយ៉ាងសំដែងមកហើយ ជាអសាធារណនាម, ដែលជាសាធារ-ណនាមក៏មាន ឧទាហរណ៍ដូចតទៅ ៖

**តេសុ ហេដ្ឋិមកោដិយោ សោតាបន្នោ <u>សង្ខាតធម្មោ</u>** (ជម្ពុកាជីវក.៣/២៥៤) ។ ក្នុងបុគ្គលអ្នកមានធមិត្រាស់ដឹងហើយដោយទាបបំផុតសោតាបន្ន ក៏ឈ្មោះថា អ្នកមានធមិដឹងហើយ ។

**មហន្តា រុក្ខា <u>វនំ</u> នាម** (មហាល្លកត្ថេរវត្ថុ ៧/១១៥) ។

ដើមឈើធំ ឈ្មោះថា **ព្រៃ** ។

សូមបញ្ជាក់បទវិសេសនៈដែលមិនមែនជាឈ្មោះ សូម្បីបើមាន សញ្ញាជោតកនិបាតនៅជាមួយផង ក៏មិនហៅថាជា សញ្ញាវិសេ-សនៈ ព្រោះបទនោះមិនមែនប្រើជាឈ្មោះ , សញ្ញាជោតកនិបាត មានត្រឹមតែលើកសរសើរប៉ុណ្ណោះ ឧទាហរណ៍ដូចជា ៖

**ឥត្ថី សទ្ទោ វិយ ហិ អញ្ញោ សទ្ទោ បុរិសានំ សកលសរីរំ ផរិត្វា ឋាតុំ សមត្ថោ នាម នត្ថិ** (ចក្ខុបា-លត្ថេរវត្ថុ ១/ ២១) ។ មែនពិត សំឡេងដទៃ ឈ្មោះថា អាច ផ្សាយទៅកាន់សរីរៈទាំងអស់របស់បុរសទាំងឡាយ ហើយតាំងនៅ ដូចសំឡេងស្ត្រីមិនមាន ។

**ន ហិ កោចិ សត្តោ អជរាមរោ នាម អត្ថិ** (សាមាវតី.២/១១២ ) ។ ព្រោះថា សត្វណានីមួយៗឈ្មោះថា មិនចាស់មិនស្លាប់ រមែងមិនមាន ។

ប្រយោគសញ្ញាវិសេសនៈ-សញ្ញាវិសេសយៈនេះ មិនមែន មានតែចំពោះវិសេសនៈ ដែលជាឈ្មោះរបស់និងនាមស័ព្ទប៉ុណ្ណោះទេ សូម្បីតែ **ឥតិ** ស័ព្ទជា **នាមវាចកៈ**ឬ**សញ្ញាជោតកៈ**ក៏ជាប្រយោគ

សញ្ញាវិសេសនៈ-សញ្ញីវិសេសយៈដែរ តែមានប្រើច្រើនចំពោះក្នុង អដ្ឋកថា ដីកា ដែលខែលើគាថា ឬខែលើស័ព្ទនីមួយៗ ឧទាហរណ៍ ដូចតទៅ ៖

ឧ.ទី ១ **ឈានង្គានិ វិតក្កោ វិចារោ បីតិ សុខំ ឯកគ្គតា** (អភិ.វិ. បឋមបរិច្ឆេទ. ទំព័រ ៨៦) ។ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ឈ្មោះថា **ឈាន** ។ នៅក្នុងយោជនា នៃអភិធម្មត្ថវិភាវិនីដីកាខែថា **ឈានង្គានិ ឈានំ នាម ... ឈានង្គានីតិ ឯត្ថ ឥតិសទ្ទោ នាមវាចកោ** ។ ដើម្បីសំដែង សម្ពន្ធតែម្យ៉ាងថា **ឈានង្គានិ បទំ សញ្ញា ឥតិសទ្ទោ នាមវាចកោ , វិតក្កោ...ឯកគ្គតាតិ បញ្ចបទំ សញ្ញី** ។

ឧ.ទី ២ **ធម្មាតិ វេទនាទយោ តយោ ខន្ធា** (ធម្ម. មដ្ឋកុណ្ឌលិ. ១/៥០) ។ **ខន្ធា** វិខន្ធទាំងឡាយ **តយោ** បី **វេទនាទយោ** មានវេទនាខន្ធជាដើម **ធម្មា ឥតិ** ឈ្មោះថា **ធម្មា** ។ សម្ពន្ធ ដូច្នេះ **ឥតិ** ស័ព្ទ ជានាមវាចកៈឬសញ្ញាជោតកៈ, **វេទនាទយោ** ក្តី **តយោ** ក្តី ជាវិសេសនៈរបស់ **ខន្ធា** ,**ធម្មា** ជាសញ្ញាវិសេសនៈរបស់ **ខន្ធា** ៗ សញ្ញីវិសេសយៈនិងជាលិង្គត្ថ ។

ឧ.ទី ៣ **ធីរោតិ បណ្ឌិតោ** ( អសទិសទាន.៦/ ៨៤ ) ។ **បណ្ឌិតោ** វិបណ្ឌិត **ធីរោ ឥតិ** ឈ្មោះថា **ធីរៈ**( អ្នកប្រាជ្ញ ) ។ **ធីរោ** សញ្ញាវិសេសនៈរបស់ **បណ្ឌិតោ** ៗ ជាសញ្ញីវិសេសយៈ ។

ឧ.ទី ៤ **ពាលាតិ ឥធលោកបរលោកត្ថំ អជាននកា** (អសទិសទាន.៦/៨៤) ។ ជនដែលមិនដឹងនូវប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ ឈ្មោះថា **ពាល** ។ សម្ពន្ធ **ឥធលោកបរ-លោកត្ថំ** អវុត្តកម្មក្នុង **អជាននកា** ៗ វិសេសនៈរបស់ **ជនា** , **ពាលា** សញ្ញាវិសេសនៈរបស់ **ជនា** ៗ សញ្ញីវិសេសយៈ និងជាលិង្គត្ថ , **ឥតិ** ស័ព្ទ សញ្ញាជោតកៈ ។

ឧ.ទី ៥ **តមោតិ អន្ធការភូតោ** ( មង្គលត្ថទីបនី ៤/៩) ។ **អន្ធការភូតោ** វិការងងឹត **តមោ ឥតិ** ឈ្មោះថា **តមោ** ។

ឧ.ទី ៦ **នរោតិ សត្តោ** (វិសុទ្ធមគ្គ ១/៥ ) ។ **សត្វ** ឈ្មោះថា **នរៈ** ។

សាធកៈដែលមានមកក្នុងដីកា ឧទាហរណ៍ដូចតទៅ ៖

**អចិត្តកន្តិ បណ្ណត្តិអជាននចិត្តេន អចិត្តកំ** ( សារត្ថទីបនីដីកា ២/ ៤១១) ។ **អចិត្តកៈ** ដោយចិត្តដែលមិនដឹង

បញ្ញត្តិ ឈ្មោះថា **អចិត្តកៈ** ។

ចំពោះប្រយោគសញ្ញាវិសេសនៈ-សញ្ញីវិសេសយៈនេះមាន ច្រើនណាស់ក្នុងអដ្ឋកថា ដីកា និងបករណ៍ដទៃ ៗ ទៀត តែចំពោះ ឧទាហរណ៍ដែលលើកយកមកទាំងប៉ុណ្ណោះនេះ គ្រាន់បានជាឧបករណ៍ ដល់កុលបុត្រអ្នកសិក្សាក្នុងគម្ពីរទាំងឡាយ ដែលមិនទាន់ស្ទាត់ក្នុង ប្រយោគ **សញ្ញាវិសេសនៈ-សញ្ញីវិសេសយៈ** ។

**ចប់ដោយសេចក្តីសង្ខេប**

# ប្រយោគវិសេសលាភី

ប្រយោគនេះមានបទនាមនាម ២ បទ, បទមួយពោល សេចក្ដីទូលាយ តែបានអត្ថពិសេសដែលពោលកំណត់ដោយអត្ថ ។ មួយទៀត ដើម្បីហាមឃាត់ពាក្យដទៃ ដូចជាអវធារណត្ថនិបាត ឬអវធារណបុព្វបទកម្មធារយសមាស ក្នុងវេលាប្រែឱ្យប្រែភ្ជាប់ពាក្យខ្មែរថា "**គឺ**"មកជាមួយ ។ ឧទាហរណ៍ដូចជា "**កណ្ឌកោ** " បន្លា , ពាក្យថា បន្លា នេះនៅជាពាក្យទូលាយជា សាធារណៈនៅឡើយ មិនទាន់សំដៅដល់បន្លាអ្វីទេ លុះលោកដាក់ពាក្យដទៃមកទៀត ដើម្បីហាមឃាត់បន្លាដទៃ, ដូចជាពាក្យថា **វេឡុ កណ្ឌកោ** ប្រែថា **កណ្ឌកោ** វ៉ិបន្លា **វេឡុ**គឺ ឫស្សី ដូច្នេះបន្លាក្នុងទីនេះ សំដៅដល់បន្លាឫស្សី ។ ន័យម្យ៉ាងទៀត ឧទាហរណ៍ ដូចពាក្យថា **យានំ** , ពាក្យថា យាននេះនៅជាសាធារណៈនៅឡើយ នៅជាពាក្យទូលាយ មិនទាន់សំដៅដល់យានអ្វីទេ ពេលលោកដាក់ពាក្យនាមនាមមួយបទមកហាមឃាត់ ទើបអាចដឹងថាយាននោះ លោកសំដៅដល់យានអ្វី ហើយពាក្យនោះជាពាក្យ

ហាមឃាត់យានណាបាន យានណាមិនបាន ឧ. **ឧបាហនា បន បព្វជិតស្ស យានំ យេវ** (សទ្ទម្មប្បជ្ជោតិកា អដ្ឋកថា មហា-និទ្ទេស ៣៩/១៤០)។ នេះជាប្រយោគ **វិសេសលាភី** វេលាប្រែត្រូវប្រែថា **បន** មានតែ **ឧបាហនា យានំ ឯវ** វិយានគឺស្បែកជើងតែម្យ៉ាងគត់ **កប្បតិ** គួរ **បព្វជិតស្ស** ដល់បព្វជិត ។ ដូច្នេះនៅក្នុងប្រយោគនេះងាយស្រួល ដល់ការយល់របស់យើងបានថា ពាក្យថា **យាន** នេះជាពាក្យទូលាយ ជាពាក្យសាធារណៈ តែពេលលោកដាក់ **ឧបាហនា** មកជាវិសេសលាភី ដើម្បីហាមឃាត់យានដទៃ ដូច្នេះសំដៅយានក្នុងទីនេះគឺស្បែកជើង ទើបយើងងាយយល់ថា ប្រយោគនេះជាប្រយោគ **វិសេសលាភី** ។

ចំណាំប្រយោគវិសេសលាភីឱ្យតែវិភត្តិដូចគ្នា ទោះបីមានលិង្គផ្សេងគ្នាក៏ដោយ វចនៈផ្សេងគ្នាក៏ដោយ ឱ្យតែវិភត្តិដូចគ្នាជាវិសេសលាភីទាំងអស់ ហើយប្រើបានចំពោះនាមនាម ហាក់ដូចគុណនាម ។ ឧទាហរណ៍ដូចតទៅ ៖

**ទុក្ខំ អរិយសច្ចំ , ទុក្ខសមុទយោ អរិយសច្ចំ , ទុក្ខ-និរោធោ អរិយសច្ចំ , ទុក្ខនិរោធគាមិនី បដិបទា អរិយ-**

**សច្ចំ** (វិនយ.មហាវគ្គ ៦/៣០-៣៣) ។ **អរិយសច្ចំ** រី អរិយ-សច្ចៈ **ទុក្ខំ** គឺទុក្ខ ,**អរិយសច្ចំ** រីអរិយសច្ចៈ **ទុក្ខសមុទយោ** គឺទុក្ខសមុទយៈ , **អរិយសច្ចំ** រីអរិយសច្ចៈ **ទុក្ខនិរោធោ** គឺទុក្ខនិរោធៈ **អរិយសច្ចំ** រីអរិយសច្ចៈ **ទុក្ខនិរោធគាមិនី បដិ-បទា** គឺទុក្ខនិរោធគាមិនីបដិបទា ។ ដូច្នេះនៅក្នុងទីនេះ **អរិយ-សច្ចំ** ជា នបុំសកលិង្គ **ទុក្ខំ** ជានបុំសកលិង្គដែរ អាចជាវិសេ-សលាភីបាន , **ទុក្ខនិរោធោ** ជាបុំលិង្គ អាចជាវិសេសលាភីជាមួយ **អរិយសច្ចំ** ដែលជានបុំសកលិង្គបាន ,**ទុក្ខនិរោធគាមិនី បដិបទា** ជាឥត្ថីលិង្គអាចជាវិសេសលាភីជាមួយ**អរិយសច្ចំ** ដែលជានបុំសក-លិង្គបាន ។ ប្រយោគនេះឱ្យតែវិភត្តិដូចគ្នា ទោះបីលិង្គផ្សេងគ្នាក៏ដោយ ក៏ជាវិសេសលាភីបានទាំងអស់ ដូចពាក្យ **ឧបាហនា** ជាឥត្ថីលិង្គទេ តែអាចជាវិសេសលាភីជាមួយ **យានំ** ដែលជានបុំសកលិង្គបាន ។ យ៉ាងណាក៏ដោយ បើជាបឋមាវិភត្តិ នាម-នាមមួយបទទៀត ក៏ជាបឋមាវិភត្តិដូចគ្នា បើជាទុតិយាវិភត្តិនាមនាមមួយបទទៀតក៏ជាទុតិយាវិភត្តិដូចគ្នា គ្រប់ៗវិភត្តិយ៉ាងនេះឯង សូម្បីមានវចនៈផ្សេងគ្នាក៏ដោយ អាចជាវិសេសលាភី

បានទាំងអស់ ឧទាហរណ៍ដូចជា **បាណាតិបាតា វេរមណី** [១] **សិក្ខាបទំ សមាទិយាមិ** (សុត្តន្ត.ខុទ្ទកបាឋៈ ៥២/១) ។ ពាក្យថា **សិក្ខាបទំ** នេះនៅ ជាពាក្យទូលាយនៅឡើយ មិនទាន់សំដៅដល់សិក្ខាបទណានីមួយទេ ទើបលោកដាក់ **វេរមណី** មកជាពាក្យហាមឃាត់ពាក្យដទៃ ឱ្យទៅជាវិសេសលាភី ។ តែ **សិក្ខាបទំ** ជាទុតិយាវិភត្តិហើយជា ឯកវចនៈ ចំណែក **វេរមណី** ជាទុតិយា-វិភត្តិហើយជា ពហុវចនៈ ទោះបីមានវចនៈផ្សេងគ្នាយ៉ាងនេះក៏ដោយ ក៏អាចជាវិសេសលាភីបានទាំងអស់ ។ ប្រែលោតប្រយោគ **អហំ** វីខ្ញុំ **សមាទិយាមិ** សូមសមាទាន **សិក្ខាបទំ** នូវសិក្ខាបទ **វេរមណី** គឺចេតនាវៀរ **បាណាតិបាតា** ចាកការសម្លាប់សត្វ ។ សម្ពន្ធ . **អហំ** សយកត្តា ក្នុង **សមាទិយាមិ** ៗ អាខ្យាតបទកត្តុវាចកៈ , **វេរមណី** ជាវិសេសលាភី ក្នុង **សិក្ខាបទំ** ៗ អវុត្តកម្មក្នុង **សមាទិយាមិ**,**បាណាតិបាតា** អបាទានក្នុង **វេរមណី** ។

ឧ.ទី ៤ **អនភិជ្ឈា បរិច្ចាជកា ធម្មបទំ , អព្យាបាទោ**

---

(១) តាមនៅក្នុងគម្ពីរបទរូបសិទ្ធិ និងច្បាប់ឆដ្ឋសង្គាយនាខ្លះ មានរូបជា វេរមណិសិក្ខាបទំ នូវសិក្ខាបទដែលវៀរ ។

**បរិព្វាជកា ធម្មបទំ , សម្មាសតិ បរិព្វាជកា ធម្មបទំ , សម្មាសមាធិ បរិព្វាជកា ធម្មបទំ** (ធម្មបទ. កុណ្ឌលកេសី-ថេរីវត្ថុ ៤/១៦៤) ។ ប្រែ. ម្នាលបរិព្វាជកនិងបរិព្វាជិកាទាំងឡាយ វិធម្មបទ គឺ **អនភិជ្ឈា**, ម្នាលបរិព្វាជកនិងបរិព្វាជិកាទាំងឡាយ វិធម្មបទ គឺ **អព្យាបាទៈ**, ម្នាលបរិព្វាជក និងបរិព្វាជិកាទាំងឡាយ វិធម្មបទ គឺ **សម្មាសតិ**, ម្នាលបរិព្វាជកនិងបរិព្វាជិកាទាំងឡាយ វិធម្មបទ គឺ **សម្មាសមាធិ**, ។ ខ្ញុំមិនបាច់លោតប្រយោគឱ្យវែងឆ្ងាយ ព្រោះងាយស្រួលទៅហើយ ។ ចំពោះប្រយោគវិសេសលា-ភីនេះមានប្រើច្រើនក្នុងគម្ពីរ អដ្ឋកថា ដីកា ដូចនៅក្នុងអដ្ឋកថាធម្មបទដ្ឋកថា (តិស្សត្ថេរវត្ថុ.១/៦៣) **យេ កេចិ ទេវា វា មនុស្សា វា គហដ្ឋា វា បព្វជិតា វា តំ អក្កោច្ឆិ មន្តិ-អាទិវត្ថុកំ កោធំ សកដធុរំ វិយ នទ្ធិនា បូតិមច្ឆាទីនិ វិយ ច កុសាទីហិ បុនប្បុនំ វេឋេត្វា ឧបនយ្ហន្តិ តេសំ សកឹ ឧប្បន្នំ វេរំ ន សម្មតិ ន វូបសម្មតិ ។** វិញ្ញេរ, ជនទាំងឡាយឯណានីមួយ គឺ ទេវតាឬ ឬគឺមនុស្ស គឺគ្រហស្ថឬ ឬគឺអ្នកបួស វេចចងនូវសេចក្តីក្រោធនោះថា គឺថាមានកិរិយាក្រោធ

ថា រីបុគ្គលឯណោះជេរហើយនូវអញ ដូច្នេះ ជាដើមជាវត្ថុ រឿយ ៗ ដូចជាជនកាលជ្រាមនូវនឹមនៃរទេះដោយមេកំព្រាផង, ដូចជា រីជនកាលរុំនូវវត្ថុទាំងឡាយមានត្រីស្អុយជាដើម ដោយវត្ថុទ.ផងឈ្មោះថា ចូលទៅជិតចងនៃជនទាំងឡាយនោះ កើតឡើងហើយអស់វារៈម្តង រមែងមិនរម្ងាប់គឺថា មិនចូលទៅជិតរម្ងាប់ ។ សម្ពន្ធ ដូច្នេះ **យេ កេចិ** វិសេសនៈរបស់ **ជនា** ៗ សយកត្តា ក្នុង **ឧប-នយ្ហន្តិ** ៗ អាខ្យាតបទ កត្តុវាចកៈ **ទេវា** ក្តី **មនុស្សា** ក្តី **គហដ្ឋា** ក្តី **បព្វជិតា** ក្តី ជាវិសេសលាភីរបស់ **យេ កេចិ ជនា** , **វា** ទាំង ៤ ស័ព្ទ បទវិកប្បត្ថក្នុង **ទេវា - មនុស្សា- គហដ្ឋា- បព្វជិតា**, **តំ** វិវរិយៈ ក្នុង **អកោច្ឆិ មន្តិអាទិវត្ថុកំ** ៗ វិវរណៈរបស់ **តំ** , **តំ** ក្តី **អកោច្ឆិ មន្តិអាទិវត្ថុកំ** ក្តី វិសេសនៈរបស់ **កោធំ** ៗ អវុត្តកម្ម ក្នុង **វេបេត្វា** ,**ជនោ** លិង្គត្ថ , **វេបេត្វា** សមានកាលកិរិយាក្នុង **ឧបនយ្ហន្តិ** ,**សកដធុរំ** អវុត្តកម្ម ក្នុង **វេបេន្តោ ៗ** អព្ភន្តរកិរិយារបស់ **ជនោ** , **វិយ** ស័ព្ទ ឧបមាជោតកៈក្នុង **ជនោ** , **ច** សព្ទ បទ-វិកប្បត្ថ ក្នុង **វិយ** , **នទ្ធិនា** ករណត្ថតតិយា ក្នុង **វេបេន្តោ** ជាអព្ភន្តរកិរិយារបស់ **ជនោ** ៗ លិង្គត្ថ , **បូតិមច្ឆាទីនិ** អវុត្តកម្ម ក្នុង

**វេវេន្តោ** , **វិយ** ស័ព្ទ ឧបមាជោតកៈក្នុង **ជនោ** , **ច** សព្ទ៍ បទ-វិកប្បត្ថក្នុង **វិយ** , **កុសាទីហិ** ករណត្ថតតិយា ក្នុង **វេវេន្តោ** , **បុនប្បុនំ** កិរិយាវិសេសនៈ ក្នុង **ឧបនយ្ហន្តិ** , **វេរំ** សយកត្តា ក្នុង **សម្មតិ -វូបសម្មតិ** , **សម្មតិ** វិវរិយ ក្នុង **វូបសម្មតិ** ៗ វិវរណរបស់ **សម្មតិ** , **សម្មតិ** ក្តី **វូបសម្មតិ** ក្តី ជាអាខ្យាតបទ កត្តុវាចកៈ, **តេសំ** វិសេសនៈរបស់ **ជនានំ** ៗ សម្បទាន ក្នុង **ឧប្បន្នំ** , **សកឹ** អច្ចន្តសំយោគត្ថទុតិយា ក្នុង **ឧប្បន្នំ** ៗ វិសេសនៈ របស់ **វេរំ** , **ន** ទាំងពីរសព្ទ៍ បដិសេធ ក្នុង **សម្មតិ -វូបសម្មតិ** ។

ប្រយោគវិសេសលាភីនេះ មានប្រើច្រើនណាស់ក្នុងគម្ពីរធម្មបទដ្ឋកថា មង្គលត្ថទីបនី វិសុទ្ធិមគ្គ អដ្ឋកថា ដីកា តែខ្ញុំមិនបានលើកយកឧទាហរណ៏មកឱ្យវែងឆ្ងាយនោះទេ សូមអ្នកសិក្សាពិចារណាសេចក្តីពន្យល់ខាងលើនិងឧទាហរណ៏ខ្លះៗនោះ ហើយត្រូវចងចាំថានេះជាប្រយោគ **វិសេសលាភី** ។

<u>**ចប់ប្រយោគវិសេសលាភីដោយសង្ខេប**</u>

៤១

## សរូបនិទស្សន:-សរូបនិទស្សនិយ:

(តាមយោជនាច្រើនហៅថា សរូប:ឬអាការ:)

ប្រយោគនេះសម្រាប់ហៅ បទនាមនាមច្រើនបទជាការកំណត់ដោយវិភាគគឺចំណែក នៃនិក្ខេបបទដែលលើកឡើងជាការចែករំលែកពីបទនាមនាមដែលជាម្ចាស់របស់, តែដើមកំណើតក៏ជានាមនាមសុទ្ធ ដូចវិសេសលាភី, គ្រាន់តែមិនមែនជាឥស្សរះចំពោះខ្លួន ត្រូវចូលជាមួយបទនាមនាមដទៃ ដែលជាម្ចាស់របស់ខ្លួនប៉ុណ្ណោះ ដែលផ្សេងពីបទវិសេសលាភីនោះ តែត្រង់បទសរូបៈនេះជាបទរាយមកពីបទនាមនាម ដែលជាម្ចាស់របស់ដោយចំពោះច្រើន ៗ បទ ដែលនៅច្រឡូកច្រឡំគ្នា , ចំណែកបទនាមនាមជាម្ចាស់របស់នោះជាឈ្មោះរួមបៀមសេចក្ដីទុក ហើយក៏ចែករំលែកសេចក្ដីឱ្យទូលាយចេញទៅ ព្រះគន្ថរចនាចារ្យច្រើនដាក់សង្ខ្យាស័ព្ទមកជាមួយដោយច្រើន ,បើមិនមានសង្ខ្យាស័ព្ទទេ លោករៀងទុកជាប់ទាក់ទងដោយ **ឥតិ** សព្ទ,**ឥតិ** សព្ទនេះរួមឬបៀមសេចក្ដីនេះទុកហើយ ជាបឋមាវិភត្តិ ហៅឈ្មោះថា **លិង្គត្ថោ** តាមគម្ពីរយោជនា ,បើជាវិភត្តិដទៃក៏ហៅតាមឈ្មោះនិក្ខេបបទ ។ វេលាប្រែ

ត្រូវប្រែថា **"គឺ"** ដូច វិសេសលាភីដែរ ។ ចំណែកការសម្ពន្ធ ត្រូវសម្ពន្ធ បទដែលពង្រីកសេចក្ដីនោះថា សរូបនិទស្សនៈ ឯសរូបៈ ដែលជាម្ចាស់របស់នោះត្រូវសម្ពន្ធថា សរូបនិទស្សនីយៈនិងសម្ពន្ធ យ៉ាងណាទៀតក៏សម្ពន្ធយ៉ាងនោះទៅ ។

ឧ.ទី ១ **ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ** (ធម្ម.អាយុវឌ្ឍនកុមារ.៤/១៧៩) ។ ប្រែ. **ធម្មា** វិធមិទាំងឡាយ **ចត្តារោ** បួន **អាយុ** គឺអាយុ **វណ្ណោ** គឺពណ៌សម្បុរ **សុខំ** គឺសុខ **ពលំ** គឺកំលាំង **វឌ្ឍន្តិ** តែងចំរើន ។ សម្ពន្ធ. **អាយុ** ក្ដី **វណ្ណោ** ក្ដី **សុខំ** ក្ដី **ពលំ** ក្ដី ជាសរូបនិទស្សនៈរបស់ **ចត្តរោ ធម្មា** , **ចត្តរោ** ជាវិសេសនៈរបស់ **ធម្មា** ៗ ជាសរូបនិទស្សនីយៈនិងជាសយកត្ដា ក្នុង **វឌ្ឍន្តិ** ៗ ជាអាខ្យាតបទកត្តុវាចកៈ ។

ឧ.ទី ២ **និសភោ ច អនោមោ ច ទ្វេ អគ្គសាវកា** (ធម្ម.សញ្ជយ.១/១៥២) ។ ប្រែ. **អគ្គសាវកា** វិ អគ្គសាវកទាំងឡាយ **ទ្វេ** ពីរ **និសភោ ច** គឺព្រះនិសភៈ ១ **អនោមោ ច** គឺព្រះអនោមៈ ។ សម្ពន្ធ **ច** ទាំងពីរជា បទសមុច្ចយត្ថ **និសភោ** ក្ដី

**អនោមោ** ក្តី ជាសរូបនិទស្សនៈរបស់ **ទ្វេ អគ្គសាវកា , ទ្វេ** វិសេសនៈរបស់ **អគ្គសាវកា** ៗ ជាសរូបនិទស្សនីយនិងជាលិង្គត្ថ ។

ឧ.ទី ៣ **សុន្ទរា ច សុមនា ច ទ្វេ អគ្គសាវិកា** (ធម្ម.សញ្ញយ.១/១៥២) ។ ការប្រែនិងសម្ពន្ធដូចខាងលើ ។

ឧ.ទី ៤ **អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ**

**សេយ្យាវសថំ បទីបេយ្យំ ទានវត្ថូ ឥមេ ទស**

(មង្គលត្ថទីបនី ៣/៤) ។ ប្រែ. **ទានវត្ថូ** វិវត្ថុជាគ្រឿងបំពេញនូវទាន ទ. **ទស** ដប់យ៉ាង **ឥមេ** នេះ **អន្នំ** គឺបាយ **បានំ** គឺទឹក **វត្ថំ** គឺសំពត់ **យានំ** គឺយាន **មាលា** គឺកម្រងផ្កា **គន្ធំ** គឺគ្រឿងក្រអូប **វិលេបនំ** គឺគ្រឿងលាប **សេយ្យំ** គឺទីដេកទីអង្គុយ **អាវសថំ** ផ្ទះសំបែង **បទីបេយ្យំ** គឺប្រទីប ។ សម្ពន្ធ **អន្នំ** ក្តី **បានំ** ក្តី **វត្ថំ** ក្តី **យានំ** ក្តី **មាលា** ក្តី **គន្ធំ** ក្តី **វិលេបនំ** ក្តី **សេយ្យំ** ក្តី **អាវសថំ** ក្តី **បទីបេយ្យំ** ក្តី ជាសរូបនិទស្សនៈរបស់ **ឥមេ ទស ទានវត្ថូ , ឥមេ** ក្តី **ទស** ក្តី ជាវិសេសនៈរបស់ **ទានវត្ថូ** ៗ ជាសរូបនិទស្សនីយនិងជាលិង្គត្ថ ។

បទសរូបៈដែលលើកឧទាហរណ៍ខាងលើនេះ ជាបឋមាវិភត្តិ តែអាចជាវិភត្តិដទៃផ្សេងពីបឋមាវិភត្តិបាន អនុវត្តនិក្ខេបបទ ដូច ឧ.តទៅនេះ ៖

**ឧស្សូរសេយ្យំ អាលស្សំ ចណ្ឌិក្កំ ទីឃសោត្តិយំ** (១)
**ឯកស្សទ្ធានគមនំ បរទារូបសេវនំ**
**ឯតំ ព្រាហ្មណ សេវស្សុ ....................។**

(ធម្ម.អនត្ថបុច្ឆកព្រាហ្មណ.៤/១៦៥) នៅក្នុងយោជនា(១/៥៨) លោកខែ ថា **ឥតិ ឯតំ** , លោកដាក់ **ឥតិ** មកដើម្បីបញ្ជាក់ដល់ប្រយោគសរូបនិទស្សនៈនេះ ប្រែ. **ព្រាហ្មណ** ម្នាលព្រាហ្មណ៍ **ត្វំ** វីលោក **សេវស្សុ** ចូរសេព **ឯតំ ឆព្វិធកម្មំ** នូវកម្មមានបការៈ ៦ យ៉ាង នេះ **ឧស្សូរសេយ្យំ** គឺដេករហូតថ្ងៃរះឡើង **អាលស្សំ** គឺ ការខ្ជិលច្រអូស **ចណ្ឌិក្កំ** គឺកាច **ទីឃសោត្តិយំ** គឺការលេងស្រីលេងល្បែងលេងស្រាអស់កាលយូរ **ឯកស្សទ្ធានគមនំ** គឺការទៅផ្លូវឆ្ងាយតែម្នាក់ឯង **បរទារូបសេវនំ** គឺការសេពនូវប្រព័ន្ធ

---

(១) ច្បាប់ឆដ្ឋសង្គាយនា ម.មានរូបជា **សោណ្ឌិយំ** តាមបាលិឆដ្ឋសង្គាយនា ត្រឹមត្រូវជាង ព្រោះហេតុនោះ នៅក្នុងធម្មបទមហាដីកា ១/១១៣ខែថា **ទីឃសោណ្ឌិយន្តិ ចិរកាលំ ទីឃមទ្ធានំ ឥត្ថិធុត្តអក្ខធុត្តសុរាធុត្តភាវោ ។**

អ្នកដទៃ ។ សម្ពន្ធ **ឧស្សូរសេយ្យំ** ក្តី **អាលស្យំ** ក្តី **ចណ្ឌិក្កំ** ក្តី **ទីឃសោត្តិយំ** ក្តី **ឯកស្សទ្ធានគមនំ** ក្តី ជាសរូបនិ-ទស្សនៈរបស់ **ឯតំ ឆព្វិធកម្មំ** , **ឯតំ** វិសេសនៈរបស់ **ឆព្វិធ-កម្មំ** ៗ ជាសរូបនិទស្សនីយនិង ជាអវុត្តកម្ម ក្នុង **សេវស្សុ** ៗ ជាអាខ្យាតបទ កត្តុវាចកៈ ។

ឧ.ទី ២ **ធម្មចរិយំ ព្រហ្មចរិយំ ឯតទាហុ វសុត្តមំ ។** (ធម្ម. កបិលមច្ឆ.៨/៨).ប្រែ **បណ្ឌិតា** វី បណ្ឌិតទាំងឡាយ **អាហុ** ពោលហើយ **ទុវិធចរិយំ** នូវការប្រព្រឹត្ត ២ ប្រការ **ឯតំ** នេះ **ធម្មចរិយំ** គឺការប្រព្រឹត្តធម៌ **ព្រហ្មចរិយំ** គឺការប្រព្រឹត្ត ព្រហ្មចរិយៈ **វសុត្តមំ** ថាជាកែវខ្ពង់ខ្ពស់ ។ សម្ពន្ធ **បណ្ឌិតា** សយកត្តា ក្នុង **អាហុ** អាខ្យាតបទ កត្តុវាចកៈ, **ធម្មចរិយំ** ក្តី **ព្រហ្មចរិយំ** ក្តី ជាសរូបនិទស្សនៈរបស់ **ឯតំ ទុវិធចរិយំ** , **ឯតំ** វិសេសនៈរបស់ **ទុវិធចរិយំ** ៗ ជាសរូបនិទស្សនីយៈនិងជាអវុត្តកម្ម ក្នុង **អាហុ** , **វសុត្តមំ** ជាសម្ភាវនៈ ក្នុង **អាហុ** ។

ឧ.ទី ៣ **អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេ-**

**សនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ** ( វិន-យបិដក មហាវគ្គ ៦/៥០ )ប្រែ គ្រានោះ វិធម្មទេសនា ដែលលើកឡើងសំដែងដោយព្រះពុទ្ធទាំងឡាយឯណា វិព្រះដ៏មានព្រះភាគទ្រង់ប្រកាសសំដែងហើយ នូវធម្មទេសនានោះ គឺ ទុក្ខ គឺ សមុទយៈ គឺ និរោធ គឺមគ្គ ។ សម្ពន្ធ ត្រឹម **តំ** តទៅ , **ភគវា** សយកត្តា ក្នុង **បកាសេសិ** ៗ អាខ្យាតបទ កត្តុវាចកៈ , **ទុក្ខំ** ក្តី **សមុទយំ** ក្តី **និរោធំ** ក្តី **មគ្គំ** ក្តី ជាសរូបនិទស្សនៈរបស់ **តំ ធម្មទេសនំ** , **តំ** វិសេសនៈរបស់ **ធម្មទេសនំ** ៗ សរូបនិទស្សនីយៈ និងជា អវុត្តកម្មក្នុង **បកាសេសិ** ។

ឧ.ទី ៤ **ឥធ បន ភិក្ខវេ ឯកច្ចេ មោឃបុរិសា ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ** (សុត្តន្ត.មជ្ឈិម. មូល.អលគទ្ទូបមសូត្រ ២១/៣៩ ,សមន្ត.១/៣៨ ធម្ម.ចក្ខុបាល-ត្ថេរ.១/៣១) ។ ប្រែ. **ភិក្ខវេ** ម្នាលភិក្ខុទ. **បន** ក៏ **មោឃ-បុរិសា** វិមោឃបុរសទ. **ឯកច្ចេ** ពួកខ្លះ **ឥធ លោកេ** ក្នុងលោកនេះ **បរិយាបុណន្តិ** រៀនយក **ធម្មំ** នូវធមិ **សុត្តំ** គឺ សុត្ត

**គេយ្យំ** គឺគេយ្យ **វេយ្យាករណំ** គឺ វេយ្យាករណ **គាថំ** គឺ គាថា **ឧទានំ** គឺ ឧទាន **ឥតិវុត្តកំ** គឺ ឥតិវុត្តក **ជាតកំ** គឺជាតក **អព្ភុតធម្មំ** គឺ អព្ភូតធមិ **វេទល្លំ** គឺ វេទល្ល ។

សរូបនិទស្សនៈមិនមែនមានតែប៉ុណ្ណេះទេ តាមគម្ពីរយោជនាបានពន្យល់មកថា សរូបនេះមានចូលជាមួយ **ឥតិ** ស័ព្ទដែលបៀមសេចក្តីទុកខាងក្នុងរបស់ខ្លួន តែមានប្រើច្រើននោះច្រើនតែនៅក្នុងអដ្ឋកថា ដីកា ដែលខែសេចក្តីពីស័ព្ទគាថា ឬស័ព្ទព្រះបាលីគឺព្រះពុទ្ធដីកា មានឧទាហរណ៍ដូចតទៅ ៖

**ចតស្សោ ហិ សម្បទា នាម វត្ថុសម្បទា បច្ចយ-សម្បទា ចេតនាសម្បទា គុណាតិរេកសម្បទាតិ** ( ធម្ម.សុខ-សាមណេរ.៥/១៣៣) ។ ប្រែ. **ហិ** មែនពិត **សម្បទា នាម** ឈ្មោះថា វិសម្បទាទាំងឡាយ **ចតស្សោ** ៤ **ឥតិ** គឺ **វត្ថុ-សម្បទា** វិវត្ថុសម្បទា **បច្ចយសម្បទា** វិបច្ចយសម្បទា **ចេត-នាសម្បទា** វិចេតនាសម្បទា **គុណាតិរេកសម្បទា** វិគុណាតិ-រេកសម្បទា ។ សម្ពន្ធ. **វត្ថុសម្បទា** ក្តី **បច្ចយសម្បទា** ក្តី **ចេតនាសម្បទា** ក្តី **គុណាតិរេកសម្បទា** ក្តី ជាលិង្គត្ថ , **ឥតិ**

ស័ព្ទ ជាសរូបនិទស្សនៈរបស់ **សម្បទា** ។ សរូបនិទស្ស-នីយៈនិងជាលិង្គត្ថ ។

ឧ.ទី ២ **អថ ខោ សោ ទក្ខិណេយ្យសង្ឃោ សម្មុតិសង្ឃោ ចាតិ ទុវិធោ ហោតិ** (កង្ខាវិតរណី ១/៥) ។ ប្រែ. **អថ ខោ** បើតាមពិតទៅ **សោ សង្ឃោ** រីសង្ឃនោះ **ទុវិធោ ហោតិ** ជាសង្ឃមានបការៈ ២ យ៉ាង **ឥតិ** គឺ **ទក្ខិណេយ្យសង្ឃោ ច** រីទក្ខិណេយ្យសង្ឃ ១ **សម្មុតិសង្ឃោ ច** រី សម្មុតិសង្ឃ ១ ។ សម្ពន្ធ. **អថ** អរុចិសូចនត្ថ **ខោ** វចនាលង្ការៈ **ច** ទាំងពីរស័ព្ទ ជា បទសមុច្ចយត្ថៈ , **ទក្ខិណេយ្យ-សង្ឃោ** ក្តី **សម្មុតិសង្ឃោ** ក្តី ជាលិង្គត្ថ , **ឥតិ** ស័ព្ទជា សរូប-និទស្សនៈរបស់ **សោ សង្ឃោ** ,**សោ** វិសេសនៈរបស់ **សង្ឃោ** ។ ជាសរូបនិទស្សនីយៈនិងជាបកតិកត្តា ក្នុង **ហោតិ** ។ ជាអាខ្យា-តបទ កត្តុវាចកៈ , **ទុវិធោ** វិកតិកត្តា ក្នុង **ហោតិ** ។

ឧ.ទី ៣ **សីលវិសុទ្ធិ ចេវ ចិត្តវិសុទ្ធិ ចាតិ ឥមា ទ្វេ វិសុទ្ធិយោ** (វិសុទ្ធិមគ្គ ៣/៨៩១) ។ ប្រែ. **វិសុទ្ធិយោ** រីវិសុទ្ធិទាំងឡាយ **ទ្វេ** ២យ៉ាង **ឥមា** នេះ **ឥតិ** គឺ **សីលវិសុទ្ធិ ច**

**ឯវ** វីសីលវិសុទ្ធិ ១ មែនពិត **ចិត្តវិសុទ្ធិ ច ឯវ** វីចិត្តវិសុទ្ធិ ១ មែន ពិត ។ សម្ពន្ធ **ច** ស័ព្ទ បទសមុច្ចយត្ថ ,**ឯវ** ស័ព្ទ ជាអវធារណៈ ក្នុង សីលវិសុទ្ធិ និង ចិត្តវិសុទ្ធិ , **សីលវិសុទ្ធិ** ក្តី **ចិត្តវិសុទ្ធិ** ក្តី ជាលិង្គត្ថ **ឥតិ** ស័ព្ទជាសរូបនិទស្សនៈរបស់ **ឥមា ទ្វេ វិសុទ្ធិយោ ,** **ឥមា** ក្តី **ទ្វេ** ក្តី ជាវិសេសនៈរបស់ **វិសុទ្ធិយោ** ៧ សរូបនិ-ទស្សនីយៈនិង ជា...។

ឧ.ទី ៤ **ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញ្ញា-ណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណ-ទស្សនវិសុទ្ធីតិ ឥមា បញ្ច វិសុទ្ធិយោ** ( វិសុទ្ធិមគ្គ ៣/៨៩១) ការប្រែនិងសម្ពន្ធសូមពិនិត្យឧ.ទី ៣ ហើយប្រែសម្ពន្ធចុះ ។

ឧ.ទី ៥ **ភូតរូបំ ចតុព្វិធំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ** (វិសុទ្ធមគ្គ ៣/៨៩២) ។ សូម ពិនិត្យមើលឧ.ទី ២ ហើយប្រែ-សម្ពន្ធចុះ ។

សរូបៈមានមកក្នុងព្រះអដ្ឋកថា អ្នកឈ្លាសក្នុងនិរុត្តិសាស្ត្រគប្បី ជ្រាបឧទាហរណ៍ដូចតទៅនេះ ៖

ឧ.ទី ១. **សព្វម្បិ ចេតំ វិនយបិដកំ សុត្តន្តបិដកំ**

**អភិធម្មបិដកន្តិ តិប្បភេទមេវ ហោតិ** (សុមង្គលវិលាសិនី អដ្ឋកថា ព្រហ្មជាលសូត្រ សមន្ត.១/២៨)។ ប្រែ. **ច** ក៏ **ឯតំ ពុទ្ធវចនំ** វី ពុទ្ធវចនៈនោះ **សព្វម្បិ** សូម្បីទាំងអស់ **តិប្បភេ-ទមេវ ហោតិ** ជាពុទ្ធវចនៈ ៣ ប្រភេទគត់ **ឥតិ** គឺ **វិនយ-បិដកំ** វីវិនយបិដក **សុត្តន្តបិដកំ** វីសុត្តន្តបិដក **អភិធម្មបិដកំ** វីអភិធម្មបិដក ។ សម្ពន្ធ **ច** ស័ព្ទ វាក្យារម្ភជោតកៈ, **វិនយបិដកំ** ក្តី **សុត្តន្តបិដកំ** ក្តី **អភិធម្មបិដកំ** ក្តី ជាលិង្គត្ថ , **ឥតិ** ជាសរូបនិទស្សនៈរបស់ **សព្វម្បិ ឯតំ ពុទ្ធវចនំ** , **សព្វំ** ក្តី **ឯតំ** ក្តី ជាវិសេសនៈរបស់ **ពុទ្ធវចនំ** ៗ ជាសរូបនិទស្សនីយៈនិង ជាបកតិ-កត្តា ក្នុង **ហោតិ** ៗ អាខ្យាតបទ កត្តុវាចក ,**ឯវ** ស័ព្ទជាអវធារណៈក្នុង **តិប្បភេទំ** ៗ ជាវិកតិកត្តា ក្នុង **ហោតិ** ។

ឧ.ទី ២ **ទ្វេ វិភង្គា ទ្វាវីសតិ ខន្ធកា សោឡស បរិវារាតិ ឥទំ វិនយបិដកំ នាម** (សុមង្គលវិលាសិនី អដ្ឋកថា ព្រហ្មជាលសូត្រ សមន្ត.១/២៨)។ **ឥទំ ពុទ្ធវចនំ** វី ពុទ្ធវចនៈនេះ **ឥតិ** គឺ **វិភង្គា** វីវិភង្គទាំងឡាយ **ទ្វេ** ២ **ខន្ធកា** វីខន្ធកៈទាំងឡាយ **ទ្វាវីសតិ** ២២ **បរិវារា** វីបរិវារៈទាំងឡាយ

**សោឡស** ១៦ **វិនយបិដកំ នាម** ឈ្មោះថា វិនយបិដក ។ សម្ពន្ធ **ទ្វេ** វិសេសនៈរបស់ **វិភង្គា** ៧ លិង្គត្ថ , **ទ្វាវីសតិ** វិសេសនៈរបស់ **ខន្ធកា** ៧ លិង្គត្ថ ,**សោឡស** វិសេសនៈរបស់ **បរិវារា** ៧ លិង្គត្ថ , **ឥតិ** ស័ព្ទសរូបនិទស្សនៈរបស់**ឥទំ ពុទ្ធវចនំ , ឥទំ** វិសេសនៈ របស់ **ពុទ្ធវចនំ** ៧ សរូបនិទស្សនីយៈនិងជាលិង្គត្ថ, **នាម** ស័ព្ទ សញ្ញាជោតកៈ,**វិនយបិដកំ** សញ្ញាវិសេសនៈរបស់ **ពុទ្ធវចនំ** ៧ សញ្ញីវិសេសយៈ ។

ឧ.ទី ៣ **សព្វមេវ ហីទំ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវប្បភេទំ ហោតិ** (សមន្ត.១/៤៤, សុមង្គ.អដ្ឋកថា ព្រហ្មជា-លសូត្រ អដ្ឋសាលិនី អដ្ឋកថា ចិត្តុប្បាទកណ្ឌ , ចូឡគន្ថវិសបិដកត្តយបរិច្ឆេទ ) ។ ការប្រែនិងសម្ពន្ធចូរមើលឧទាហរណ៍ទី ១ ហើយប្រែនិងសម្ពន្ធតាមនោះចុះ ។

ឧ.ទី ៤ **សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវសុ សាសនង្គេសុ ឧទានសង្គហំ** (បរមត្ថទីបនី អដ្ឋកថា ឧទាន) ។ ប្រែ.

**ឧទានសង្គហំ** វិឧទានសង្គហៈ **សាសនង្គេសុ** ក្នុងអង្គនៃសាសនា **នវសុ** ៩ **ឥតិ** គឺ **សុត្តំ** គឺ សុត្ត...**វេទល្លំ** គឺវេទល្លៈ ។ សម្ពន្ធ. **សុត្តំ** ក្តី...**វេទល្លំ** ក្តី ជាលិង្គត្ថ , **ឥតិ** ស័ព្ទជាសរូបនិទស្សនៈរបស់ **នវសុ សាសនង្គេសុ ឧទានសង្គហំ** , **នវសុ** វិសេសនៈរបស់ **សាសនង្គេសុ** ៗភិន្នាធារៈក្នុង ឧទានសង្គហំ ៗជាសរូបនិទស្សនីយ និងជាលិង្គត្ថ ។

ឧ.ទី ៤ **សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវសុ សាសនង្គេសុ គាថាសង្គហំ** (បរមត្ថទីបនី អដ្ឋកថា វិមានវត្ថុ ឥត្ថិវិមាន. បរមត្ថ.បេតវត្ថុ ឧរគវគ្គ ,បរមត្ថ.អដ្ឋ.ចរិយាបិដក អកិត្តិវគ្គ ។ ការប្រែនិងសម្ពន្ធសូមពិនិត្យមើលឧ.ទី ៣ ។

ឧ.ទី ៥ **សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវសុ សាសនង្គេសុ គាថាយ សង្គហិតំ** (វិសុទ្ធជនវិលាសិនី អដ្ឋ.អបទាន ពុទ្ធវគ្គ) ។ ការប្រែនិងសម្ពន្ធសូមពិនិត្យមើលឧ.ទី ៣ ។

សួរថាអាងអ្វីទើបហ៊ានប្រែនិងសម្ពន្ធចំពោះ **ឥតិ** ស័ព្ទថា ជាសរូបៈនោះ សូមលោកលើកយកសាធកៈក្នុងគម្ពីរមកជាគ្រឿងអាងមកមើល! បាទបាន ខ្ញុំសូមជំរាបដល់លោកអ្នកសួរបានជាហ៊ានព្រោះអាងក្នុងយោជនា ដែលព្រះគន្ថរចនាចារ្យខែលើគម្ពីរអភិធម្មត្ថវិភាវិនីដីកា បឋមបរិច្ឆេទ ទំព័រ ៨៥ ត្រង់បាលីថា **វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ឯកគ្គតា ចាតិ ឥមេហិ សហិតំ វិតក្កវិចារបីតិសុខឯកគ្គតាសហិតំ ។ ចិត្តំ** វិចិត្ត **សហិតំ** ដែលប្រកប **ឥមេហិ ធម្មេហិ** ដោយធមិទ.នេះ **ឥតិ** គឺ **វិតក្កោ ច** វិវិតក្កៈ ១ **វិចារោ ច** វិវិចារៈ ១ **បីតិ ច** វីបីតិ ១ **សុខំ ច** វីសុខៈ ១ **ឯកគ្គតា ច** គឺឯកគ្គតា ១ **វិតក្ក-វិចារបីតិសុខឯកគ្គតាសហិតំ** ឈ្មោះ វិតក្កវិចារបីតិសុខឯកគ្គតា-សហិតចិត្ត ។ យោជនា (១/៤០៧) **ថា វិតក្កោ...ឯកគ្គតា ចាតិ បញ្ចបទំ លិង្គត្ថោ , ឥតីតិ (បទំ) ឥមេហីតិ បទស្ស សរូបំ , ឥមេហីតិ (បទំ) សហិតន្តិ បទេ សហយោគត-តិយា , សហិតន្តិ (បទំ) ចិត្តន្តិ បទស្ស វិសេសនំ , វិតក្ក...សហិតន្តិ បទំ លិង្គត្ថោ ។**

បទសរូបៈដែលលើកឧ.មកសំដែងនេះប្រកបដោយបឋមា-វិភត្តិ សូម្បីនិក្ខេបបទដែលប្រកបដោយវិភត្តិដទៃក៏មាន ព្រោះកាន់ថាជាបទក្នុង **ឥតិ** ,ម្យ៉ាងទៀត ក៏មានការប្រកបអនុវត្តនិក្ខេបបទ ដូចជា៖

**ទ្វិតាលមត្តំ តិតាលមត្តន្តិ ឯវំ សត្តាលមត្តំ វេហាសំ អព្ភុគ្គន្ត្វា ឱរុយ្ហ អត្តនោ សាវកភាវំ ជានាបេសិ** (ធម្ម.ជម្ពុកាជីវិក.៣/២៥៣)។ ហោះឡើងកាន់អាកាស ៧ ជួរដើមត្នោតយ៉ាងនេះគឺ កាន់វេហាស៍ ២ ដើមត្នោត , កាន់វេហាស៍ ៣ ដើមត្នោត ជាដើម ចុះហើយ ញុំាងមហាជនឱ្យជ្រាបនូវភាវៈនៃខ្លួនជាសាវ័ក (៧ដង) ។ សម្ពន្ធ **ទ្វិតាលមត្តំ តិតាលមត្តំ បទទ្វយំ សម្បាបុណិយកម្មំ , ឥតិ សទ្ទេ សរូបំ , ឥតិសទ្ទោ ឯវំ សទ្ទេ អាទ្យត្ថោ ។**

ឧ. ទី ២ **តទង្គវិមុត្តិយា វិក្ខម្ភនវិមុត្តិយា សមុច្ឆេទ-វិមុត្តិយា បដិប្បស្សទ្ធិវិមុត្តិយា និស្សរណវិមុត្តិយាតិ ឥមាហិ បញ្ចហិ វិមុត្តីហិ វិមុត្តានំ** (ធម្មបទ.គោធិកត្ថេរបរិនិ-ព្វាន.៣/១៥០) ។ រួចផុតហើយដោយវិមុត្តិទាំងឡាយ ៥

នេះគឺដោយតទង្គវិមុត្តិ ដោយវិក្ខម្ភនវិមុត្តិ ដោយសមុច្ឆេទវិមុត្តិ ដោយបដិប្បស្សទ្ធិវិមុត្តិ ដោយនិស្សរណវិមុត្តិ ។ សម្ពន្ធ **តទង្គ-វិមុត្តិយា ... និស្សរណវិមុត្តិយាតិ បញ្ចបទំករណំ , ឥតិ-សទ្ទេ ស្សរូបំ , ឥតិសទ្ទោ ឥមាហីតិ បទេ ស្សរូបំ ។**

សូមកុលបុត្រអ្នកប្រាថ្នាការសិក្សា ដើម្បីឱ្យយល់ច្បាស់នូវប្រយោគព្រមទាំងការសម្ពន្ធមិនឱ្យឃ្លៀងឃ្លាតនោះ ត្រូវសង្កេតពិនិត្យនូវឧទាហរណ៍ ដែលខ្ញុំលើកយកមកពីគម្ពីរនានាហើយចងចាំទុកឱ្យល្អសម្រាប់ប្រែប្រយោគសរូបនិទស្សនៈ-សរូបនិទស្សនីយៈ ។

**ចប់សរូបនិទស្សនៈ-សរូបនិទស្សនីយៈ**

**ដោយសង្ខេប**

# ប្រយោគសរូបវិសេសនៈ

ជាបទវិសេសនៈដែលជាសរូបៈ ហៅឈ្មោះថា **សរូបវិ-សេសនៈ**, សរូបវិសេសនៈនេះប្រហែលនឹងវិសេសលាភីដែរ ដែលផ្សេងគ្នានោះ គឺវិសេសលាភីធ្វើឱ្យបានអត្ថពិសេស , ចំណែកសរូ-បវិសេសនៈវិញជាបទពង្រីកដើម្បីធ្វើសេចក្តីប្រាថ្នាឱ្យច្បាស់ ទំនងដូចជាបទខៃ, ទោះជាផ្សេងលិង្គ វចនៈអំពីបទនាមនាមដែលសម្ពន្ធចូលក៏ដោយ ឱ្យតែមានវិភត្តិដូចគ្នាឧទាហរណ៍ ៖

**មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុ-សតេហិ** (វិនយបិដក មហាវិភង្គ ១/១ ព្រហ្មជាលសូត្រ ទីឃ. និកាយ ១៤/១)។ ប្រែ. **សទ្ធឹ** ជាមួយ **ភិក្ខុសង្ឃេន** នឹងភិក្ខុ-សង្ឃ **មហតា** ដ៏ធំ **ភិក្ខុសតេហិ** គឺរយនៃភិក្ខុទាំងឡាយ **បញ្ចមត្តេហិ** ប្រមាណ ៥ ។ សូមបញ្ជាក់នៅក្នុងគម្ពីរសុមង្គ-លវិលាសិនី លោកពន្យល់ឱ្យប្រែពាក្យ**មត្ត**ស័ព្ទយ៉ាងនេះថា **មត្តាតិ បមាណំ វុច្ចតិ** ប្រមាណលោកហៅថា មត្តៈដូច្នេះ ។ សម្ពន្ធ. **ភិក្ខុសតេហិ** សរូបវិសេសនៈរបស់ **ភិក្ខុសង្ឃេន** ។

តួយ៉ាងមានមកក្នុងអដ្ឋកថាធម្មបទដូចជា**សោបិ អត្តតោ តយោ អរូបិនោ ខន្ធា** ( ធម្ម.ចក្ខុបាល.១/៣២ ) ។ **សោ និជ្ជីវធម្មោបិ** សូម្បីវិនិជ្ជីវធមិនោះ **អត្តតោ** ដោយអត្ត **ខន្ធា** គឺ ខន្ធទ. **អរូបិនោ** មិនមានរូប **តយោ** ៣ ។ សម្ពន្ធ. **ខន្ធា** ជាសរូបវិសេសនៈរបស់ **សោ ធម្មោបិ** ។ ( ប្រយោគនេះប្រែ បែបជាវិកតិកត្តាក៏បាន ) ។

បទដែលមានលក្ខណៈយ៉ាងនេះ ឬប្រហែលគ្នានេះ ក្នុងយោជនាលោកហៅថា សរូបវិសេសនំ ខ្លះ សរូបំ ខ្លះ លិង្គត្ថោ ខ្លះ គប្បីសង្កេតតាមឧទាហរណ៍ដូចតទៅនេះ ៖

**សរូបវិសេសនៈ**

**ធារណញ្ច បនេតស្ស អបាយាទិនិព្វត្តកកិលេស-វិទ្ធំសនំ ។** ( អភិ.វិ.បឋមបរិច្ឆេទ. ទំ.៦៤ ) ប្រែ ក៏ឯ វីការទ្រទ្រង់ទុកនៃធមិនោះ គឺការកំចាត់កិលេសជាហេតុឱ្យកើតក្នុងអបាយជាដើម ។ សម្ពន្ធ យោជនា ( ១/១៤០ ) ធារណញ្ចាតិ ( បទំ ) លិង្គត្ថោ , ឯតស្សាតិ ( បទំ ) ធារណន្តិ បទេ កិរិយា-

សម្ពន្ធោ , អបា...សនន្តិ (បទំ) ធារណន្តិ បទស្ស សរូប-
វិសេសនំ ។

សរូបៈ

ឧ.ទី ១ **ចិត្តស្ស អាលម្ពិតុកាមតាមត្តំ ឆន្ទោ** ។ (អភិ. វិ. ទុតិយបរិច្ឆេទ. ទំ. ១០២) វិឆន្ទៈ គឺកិរិយាត្រឹមតែភាវៈនៃចិត្តប្រាថ្នាដើម្បីហួងហែង ។

យោជនា (១/៥៨៣) ថា ចិត្តស្សាតិ (បទំ) កាមតាតិ បទេ សម្ពន្ធោ , អាលម្ពិតុកាមតាមត្តន្តិ (បទំ) ឆន្ទោ បទស្ស សរូបំ ,ឆន្ទោតិ (បទំ) លិង្គត្ថោ ។

ឧ.ទី ២ **លោភោ តត្ថ អភិគិជ្ឈនំ** (អភិ.វិ. ទុតិយ-បរិច្ឆេទ.ទំ. ១២០) ប្រែ វិលោភៈ គឺសេចក្តីចង់បានក្រៃពេកក្នុងអារម្មណ៍នោះ ។

យោជនា(១/៥៨៣) ថា លោភោតិ (បទំ) លិង្គត្ថោ តត្ថាតិ (បទំ) អភិគិជ្ឈនន្តិ បទេ អាធារោ , អភិគិជ្ឈនន្តិ (បទំ) លោភោតិ បទស្ស សរូបំ ។

លិង្គត្ថៈ

ឧ.ទី ១ **រតនត្តយប្បណាមោ ហិ អត្ថតោ បណា-មកិរិយាភិនិប្ផាទិកា កុសលចេតនា** (អភិ.វិ.បឋមបរិច្ឆេទ. ទំ.៦៤)។ មែនពិត រីកិរិយាក្រាបថ្វាយបង្គំព្រះរតនត្រៃ ដោយសេចក្ដី គឺកុសលចេតនា ដែលញុំាងកិរិយាថ្វាយបង្គំឱ្យសម្រេច ។

យោជនា (១/៥៩)ថា រតនត្តយប្បណាមោតិ (បទំ) លិង្គត្ថោ ,...កុសលចេតនា (បទំ) លិង្គត្ថោ ។

ឧ.ទី ២ **រូបំ ភូតូបាទាយភេទភិន្នោ រូបក្ខន្ធោ** (អភិ. វិ. បឋមបរិច្ឆេទ.ទំ.៦៦) ។ រីរូប គឺរូបក្ខន្ធ ផ្សេងដោយប្រភេទនៃភូតរូបនិងឧបាទាយរូប ។

យោជនា (១/១៦៧)ថា រូបំ រូបក្ខន្ធោតិ (បទទ្វយំ) លិង្គត្ថោ ។

ឧ.ទី ៣ **ឧបាទានក្ខន្ធសង្ខាតលោកតោ ឧត្តរតិ អនា-សវភាវេនាតិ លោកុត្តរំ មគ្គចិត្តំ** (អភិ.វិ.បឋមបរិច្ឆេទ. ទំ. ៦៩)។ រីចិត្តឯណា រមែងឆ្លងចាកលោក ពោលគឺឧបាទានក្ខន្ធ

ដោយមិនមានអាសវៈ ព្រោះហេតុនោះ វិចិត្តនោះ ឈ្មោះថា លោកុត្តរៈ គឺមគ្គចិត្ត ។

យោជនា (១/២១៩) ថា លោកុត្តរន្តិ (បទំ) សញ្ញា, មគ្គចិត្តន្តិ (បទំ) លិង្គត្ថោ ។ ឧ.នេះសំដែងបទខៃបទដាក់នៃរូបវិគ្គហៈ ។ បទខៃបទដាក់នេះបោរាណាចារ្យលោកច្រើន ហៅថា វិសេសលាភី ដូចពោលក្នុងខាងដើមនោះឯង ។

**សរុបបរិសេសនៈ**

**ចប់ដោយសង្ខេប**

# ប្រយោគកិរិយាបរាមាស

កិរិយាបរាមាសនេះសង្កេតបានដោយងាយ ព្រោះរៀងទុកខាងដើមប្រយោគ និងមិនមែនជាវិសេសនៈរបស់នាមនាមណាមួយឡើយ តែជាវិសេសនៈរបស់ពាក្យទាំងអស់ក្នុងមួយប្រយោគនោះរហូតដល់កិរិយាតែម្តង ទើបហៅថា កិរិយាបរាមាស ដោយអត្ថថា ស្ទាបអង្អែលឬចាប់ត្រូវដល់កិរិយា ។ កិរិយាបរាមាសនេះច្រើនប្រើនៅក្នុងគម្ពីរជាន់ អដ្ឋកថា មានសមន្តប្បាសាទិកាជាដើម ឬក្នុងវិសុទ្ធិមគ្គជាដើម ។ ម្យ៉ាងទៀត សំដៅដល់ **យំ** , **យស្មា** ឬ **ហិ** ហើយយោគស័ព្ទ ដូច្នេះ **តំ យំ** , **ឯតំ យំ** , **យំ តេន** , **យំ តស្ស** , **យស្មា តស្មា** , **យស្មា តេន** , **យស្មា ឥតិ** , **ហិ តេន** , **ហិ ឥតិ** , ។ **យំ យស្មា ហិ** ទាំង ៣ នេះសម្មន្ធថា កិរិយាបរាមាស ។ វេលាប្រែ **យំ យស្មា ហិ** ប្រែថា ព្រោះហេតុណា,ឯណា។ ម្យ៉ាងទៀត **តំ** ដែលជាយោគស័ព្ទរបស់ **យំ** នោះ ត្រូវទាញស័ព្ទបាលីដែលប្រែផ្ទែក **យំ** នោះមកទាំងអស់ តែចំពោះ **យំ តស្ស**, **យំ តេន**, **យស្មា តស្មា** , **ហិ ឥតិ** , មិនចាំបាច់យោគស័ព្ទមកទេ ប្រែទទេថា **យស្មា** ព្រោះហេតុណា

**តស្មា** ព្រោះហេតុនោះ , **ហិ** ព្រោះហេតុណា **ឥតិ** ព្រោះហេតុនោះ យ៉ាងនេះតែម្តងជាការស្រេច ឯការសម្ពន្ធវិញ **តស្មា ឥតិ** សម្ពន្ធថា ហេតុ ឬ ហេត្វត្ថវាចកៈ ។ ប្រយោគ **យំ** កិរិយាបរាមាសដែលមាន **តំ** ឬ **ឯតំ** មកទទួលនោះ **តំ** ឬ **ឯតំ** ត្រូវប្រកបបទក្នុងប្រយោគ **យំ** ទាំងអស់ (វៀរតែ **យំ** ជាកិរិយាបរាមាសចេញ) ហើយប្រកបប្រធាន តាមលិង្គ តាមវចនៈរបស់ប្រយោគ **តំ** ឬ **ឯតំ** , សម្ពន្ធថា វិសេសនៈ មានគោលការណ៍ត្រូវបន្ថែមបទប្រធានដូច្នេះ ៖

១. បទប្រធាន បទវិសេសនៈ (បើមាន) បទអព្ភន្តរកិរិយា (បើមាន) បទវិកតិកត្តា (បើមាន) របស់ប្រធានប្រយោគ ខាង **យំ** កិរិយាបរាមាស ឱ្យប្រកបជា **ស-នំ** ឆដ្ឋីវិភត្តិ ។

២. កិរិយាគ្រប់គ្រងប្រយោគ **យំ** ត្រូវផ្លាស់ជាបទប្រធានដោយប្រើ **តំ** ប្រកបជាមួយ ប្រែថា **"វី"** មានវិធីដូច្នេះ ៖

ក. បើកិរិយាគ្រប់គ្រងប្រយោគ **យំ** ជា ហុ ភូ, អស ធាតុ

ឱ្យផ្លាស់ជា ត្ត តា , បច្ច័យក្នុងភាវតទ្ធិត ឬភាវស័ព្ទ តាមលិង្គរបស់ប្រយោគ **តំ** គឺ បុំលិង្គជា **ភាវោ** ឥត្ថីលិង្គជា **តា** នបុំសកលិង្គជា **ត្តំ** (តែដែលប្រើច្រើនគឺ **ត្ត** បច្ច័យ ព្រោះសម្រេចរូបជា នបុំសក-លិង្គ ដែលមាន **តំ** ឬ **ឯតំ** ជាវិសេសនៈ) ហើយនាំមកប្រកបជាមួយបទវិកតិកត្តា ដែលមាននៅមុខឬក្រោយកិរិយាគ្រប់គ្រងពាក្យនោះឯង តែបើកិរិយាវិកតិកត្តា ( ហុ ភូ អស ជន ធាតុ) មាន **ន** បដិសេធនៅជាមួយផងនោះ ឱ្យផ្លាស់ **ន** ជា **អ** ឬ **អន** (តាមវិធីនៃបទសមាស) ប្រកបទុកមុខបទប្រធានរបស់ប្រយោគ **តំ** ដែលសម្រេចរូបហើយ ដូច **សមត្ថោ ន ភវេយ្យ** ប្រយោគ **តំ** ,**ឯតំ** ត្រូវប្រកបជា **អសមត្ថត្តំ** ជាដើម ។

ខ. បើកិរិយាគ្រប់គ្រងប្រយោគ **យំ** ជាធាតុដទៃអំពី ហុ , ភូ អស, ឱ្យប្រកបធាតុនោះជា **យុ** បច្ច័យ ក្នុងនាមកិតកៈជាភាវសាធនៈ ដូច **ទទេយ្យាសិ** ជា **ទានំ** ជាដើម , ម្យ៉ាងទៀតបើជាហេតុកត្តុវាចកៈ ក៏ត្រូវប្រកប **យុ** បច្ច័យជារូបហេតុកត្តុវា-ចកៈដូចគ្នា ដូច **ការាបេតិ** ជា **ការាបនំ** ជាដើម សូម្បីបទ **អវុត្ត-**

**កម្ម** ដែលចូលជាមួយកិរិយាគ្រប់គ្រងប្រយោគ **យំ** កាលចូលជាមួយ **យុ** បច្ច័យ ក៏ត្រូវជាឆដ្ឋីវិភត្តិដែរ ។

## យំ - តំ

ឧ. ទី ១ **យំ ឥមស្មឹ កុលេ សវិញ្ញាណកាវិញ្ញាណកំ ធនំ កិញ្ចិ អត្ថិ សព្វន្តំ តវ ភារោ** (ធម្ម. ចក្ខុបាល. ១/៨) ។ ប្រយោគនេះជាប្រយោគកិរិយាបរាមាស ព្រោះលោកបានដាក់ **យំ** ឱ្យនៅរៀងពីខាងមុខពាក្យទាំងអស់ ហើយ **យំ** នេះទៀតមិនមែនជាវិសេសនៈរបស់នាមនាមណាមួយឡើយ តែជាវិសេសនៈរបស់ពាក្យទាំងអស់ បើសិនជាលោកប្រាថ្នាឱ្យជាវិសេសនៈរបស់ **ធនំ** នោះលោកប្រាកដជាដាក់ភ្ជាប់ **កិញ្ចិ** ជា **យំ កិញ្ចិ** មិនខានទេ តែក្នុងទីនេះលោករៀងទុកខាងដើម ដើម្បីបញ្ជាក់ដល់ប្រយោគកិរិយាបរាមាសនោះឯង ។ ប្រែ. **ធនំ** វីទ្រព្យ **សវិញ្ញាណកាវិញ្ញាណកំ** ប្រព្រឹត្តទៅមួយអន្លើដោយទ្រព្យមានវិញ្ញាណនិងមិនមានវិញ្ញាណ **កិញ្ចិ** ណានីមួយ **អត្ថិ** តែងមាន **កុលេ** ក្នុងត្រកូល **ឥមស្មឹ** នេះ **យំ** ឯណា , **សព្វំ តំ**

**ឥមស្មឹ កុលេ សវិញ្ញាណកាវិញ្ញាណកស្ស ធនស្ស កស្សចិ អត្ថិត្តំ** វីភារៈនៃទ្រព្យដែលប្រព្រឹត្តទៅមួយអន្លើដោយទ្រព្យមានវិញ្ញាណនិងមិនមានវិញ្ញាណណានីមួយ តែងតែមានក្នុងត្រកូលនេះទាំងអស់នោះ **ភារោ ហោតុ** ចូរជាភារៈ **តវ** របស់អ្នក ។ សម្ពន្ធ **យំ** កិរិយាបរាមាសក្នុង **អត្ថិ** , **សវិញ្ញាណ-កាវិញ្ញាណកំ** ក្តី **កិញ្ចិ** ក្តី ជាវិសេសនៈរបស់ **ធនំ** ៗ សយកត្តា ក្នុង **អត្ថិ** ៗ អាខ្យាតបទ កត្តុវាចកៈ, **ឥមស្មឹ** វិសេសនៈរបស់ **កុលេ** អាធារៈ ក្នុង **អត្ថិ** , **សព្វំ** ក្តី **តំ** ក្តី វិសេសនៈរបស់ **អត្ថិត្តំ** , **សវិញ្ញាណកាវិញ្ញាណកស្ស** ក្តី **កស្សចិ** ក្តី ជាវិសេសនៈរបស់ **ធនស្ស** ៗ សាមិសម្ពន្ធ ក្នុង **អត្ថិត្តំ** ៗ ជាបកតិកត្តាក្នុង **ហោតុ** ៗ អាខ្យាតបទ កត្តុវាចកៈ **ភារោ** វិកតិកត្តាក្នុង **ហោតុ** ។

## តំ_យំ

ឧ.ទី ២ **ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច ភវេយ្យាថ សោរតា ច** (ធម្ម.កោសម្ពិក.១/៨០) **។** ប្រែ.

**ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **តុម្ហេ** រីអ្នកទ. **ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា** ជាអ្នកបួសក្នុងធម៌វិន័យដែលតថាគតសំដែងដ៏ល្អយ៉ាងនេះ **ខមា ភវេយ្យាថ ច** ជាអ្នកអត់ធន់ផង **សោរតា ភវេយ្យាថ ច** ជាអ្នកស្ងៀមស្ងាត់ផង **យំ** ឯណា , **តំ តុម្ហាកំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតានំ សមានានំ ខមសោរតត្តំ** រីភាវៈនៃអ្នកទាំងឡាយកាលបួសក្នុងធម៌វិន័យ ដែលតថាគតសំដែងដ៏ល្អយ៉ាងនេះ ជាអ្នកអត់ធន់និងស្ងៀមស្ងាត់នោះ **សោភេថ** គប្បីល្អស្អាត **ឥធ សាសនេ ខោ** ក្នុងសាសនានេះឯង ។ សម្ពន្ធ **តុម្ហេ** បកតិកត្តាក្នុង **ភវេយ្យាថ**ៗ អាខ្យាតបទ កត្តុវាចកៈ , **ឯវំ** កិរិយាវិសេសនៈរបស់ **ស្វាក្ខាតេ** ៗ វិសេសនៈរបស់ **ធម្មវិនយេ** ៗ អាធារៈក្នុង **សមានា** ៗ អព្ភន្តរ-កិរិយារបស់ **តុម្ហេ** , **បព្វជិតា** ៗ វិកតិកត្តា ក្នុង **សមានា**, **ខមា** ក្តី **សោរតា** ក្តី ជាវិកតិកត្តាក្នុង **ភវេយ្យាថ** , **ច** ទាំងពីរជា វាក្យ-សមុច្ចត្ថៈ , **យំ** កិរិយាបរាមាសក្នុង **ភវេយ្យាថ** , **តំ** វិសេសនៈរបស់ **ខមសោរតត្តំ** ៗ សយកត្តាក្នុង **សោភេថ** ៗ អាខ្យាតបទ កត្តុវាចកៈ, **បព្វជិតានំ** ក្តី **សមានានំ** ក្តី ជាវិសេសនៈរបស់

**កុម្មាកំ** ៗ ភាវាទិសម្ពន្ធក្នុង**ខមសោរតត្តំ**, **ឯវំ** កិរិយាវិសេសនៈក្នុង **ស្វាក្ខាតេ** ៗ វិសេសនៈរបស់ **ធម្មវិនយេ** ៗ អាធារៈក្នុង **បព្វជិតានំ** , **ឥធ** វិសេសនៈរបស់ **សាសនេ** ៗ អាធារៈក្នុង **សោភេថ** , **ខោ** ស័ព្ទ វចនាលង្ការៈ ។

## ឯតំ_យំ

ឧ. ទី ១ **ឋានំ ខោ បនេតំ វិជ្ជតិ យំ ត្វំ កុមារោ វ សមានោ កាលំ ករេយ្យាសិ** ( ធម្ម.ទេវទត. ១/២០៥ ) ។ ប្រែ. **ត្វំ** វីព្រះអង្គម្ចាស់ **កុមារោ វ សមានោ** ជាកុមារពិត **ករេយ្យាសិ** គប្បីធ្វើ **កាលំ** នូវមរណកាល **យំ** ឯណា, **បន** ក៏ **តវ កុមារស្ស សមានស្ស កាលស្ស ករណំ** វីកិរិយាធ្វើនូវមរណកាលនៃព្រះអង្គដែលជាកុមារនោះ **ឋានំ ខោ វិជ្ជតិ** ជាឋានៈពិត ។ សម្ពន្ធ **ត្វំ** សយកត្តាក្នុង **ករេយ្យាសិ** ៗ អាខ្យាតបទ កត្តុវាចក , **វ** ស័ព្ទ អវធារណៈ ក្នុង**កុមារោ** ៗ វិកតិកត្តា ក្នុង **សមានោ** ៗ អព្ភន្តរកិរិយារបស់ **ត្វំ**, **កាលំ** អវុត្តកម្មក្នុង **ករេយ្យាសិ** , **យំ** កិរិយាបរាមាសក្នុង **ករេយ្យាសិ** , **បន** វាក្យា-

វម្កជោតក **កាលស្ស** ឆដ្ឋីកម្មក្នុង **ករណំ**៧ បកតិកត្តាក្នុង **វិជ្ជតិ** ៧ អាខ្យាតបទ កត្តុវាចក , **កុមារស្ស** ក្តី **សមានស្ស** ក្តី ជាវិសេសនៈ របស់ **តវ** ៧ ភាវាទិសម្ពន្ធ ក្នុង **ករណំ** , **ខោ** ស័ព្ទ វចនាលង្ការ , **ឋានំ** វិកតិកត្តា ក្នុង **វិជ្ជតិ** ។

ឧ.ទី ២ **ញាតមេតំ កុរុង្គស្ស យំ ត្វំ សេបណ្ណិ សេយ្យសិ** (ធម្ម. ទេវទត្ត. ១/២១២ ខុទ្ទក. កុរុង្គវគ្គ កុរុង្គមិគជាតក ៥៨/១១) ។ ប្រែ. **សេបណ្ណិ** ម្នាលដើមចម្បក់ **ត្វំ** វីអ្នក **សេយ្យសិ** ជម្រុះចុះ (**ផលានិ** នូវផ្លែទ.**បជិមុខេ** ក្នុងទីចំពោះមុខ) **យំ** ព្រោះហេតុណា ,**ឯតំ តវ សេយ្យនំ** វីការជម្រុះចុះរបស់អ្នកនោះ **កុរុង្គស្ស** គឺអញប្រើស **ញាតំ** ដឹងហើយ ។ **យំ** កិរិយាបរាមាសក្នុង **សេយ្យសិ** ។

ឧ.ទី ៣ **អនច្ឆរិយំ ខោ បនេតំ ភិក្ខុ យំ ត្វំ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆោ អហោសិ** (និគម-វាសិតិស្សត្ថេរ.២/១៩១) ។ ប្រែ. **ភិក្ខុ** នែ៎ភិក្ខុ **បន** ក៏ **ត្វំ** វីអ្នក **លភិត្វា** បានហើយ **អាចរិយំ** នូវអាចារ្យ **មាទិសំ** ប្រាកដដូចយើង **អប្បិច្ឆោ អហោសិ** ជាអ្នកប្រាថ្នាតិច **យំ** ឯណា , **ឯតំ**

**តវ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆត្តំ** វីភាវៈនៃអ្នកបាន នូវ អាចារ្យប្រាកដដូចយើង ហើយជាអ្នកប្រាថ្នា តិចនោះ **អនច្ឆរិយំ ខោ ហោតិ** មិនជាការអស្ចារ្យទេ ។ សម្ពន្ធ **ភិក្ខុ** អគារវាលបទ **បន** វាក្យារម្ភជោតក **ត្វំ** បកតិកត្តា ក្នុង **អហោសិ** ៗ អាខ្យាតបទ កត្តុវាចក , **មាទិសំ** វិសេសនៈ របស់ **អាចរិយំ** ៗ អវុត្តកម្ម ក្នុង **លភិត្វា** ៗ បុព្វកាលកិរិយាក្នុង **អហោសិ** , **អប្បិច្ឆោ** វិកតិកត្តាក្នុង **អហោសិ** , **យំ** កិរិយាប-រាមាស ក្នុង **អហោសិ** , **ឯតំ** វិសេសនៈរបស់ **អប្បិច្ឆត្តំ** ៗ បកតិកត្តាក្នុង **ហោតិ** ៗ អាខ្យាតបទ កត្តុវាចក , **តវ** សាមិសម្ពន្ធ ក្នុង **អប្បិច្ឆត្តំ** , **អនច្ឆរិយំ** វិកតិកត្តាក្នុង **ហោតិ** , **ខោ** ស័ព្ទ វចនាលង្ការ ។

ឧ.ទី ៤ **អនច្ឆរិយមេតំ យំ ឥទានិ មម ធុរំ វហិតុំ សមត្ថោ ន ភវេយ្យ** (ធម្មបទ.យមកប្បាដិហារិយវត្ថុ. ៦/១១៩) ។ ប្រែ. **ឥទានិ** ក្នុងកាលឥឡូវនេះ **កោចិ បុគ្គលោ** វីបុគ្គលណាមួយ **ន សមត្ថោ ភវេយ្យ** ជាបុគ្គលមិនអាច **វហិតុំ** ដើម្បីនាំទៅ **ធុរំ** នូវធុរៈ **មម** របស់តថាគតបានទេ **យំ** ឯណា ,

**ច** ក៏ **ឯតំ កស្សចិ មម ធុរំ វហិតុំ អសមត្ថត្តំ** វីភារៈនៃបុគ្គលណានីមួយ មិនអាចដើម្បីនាំទៅនូវធុរៈរបស់តថាគតនោះ **អនច្ឆរិយំ ហោតិ** មិនជាការអស្ចារ្យទេ ។ សម្ពន្ធ **ឥទានិ** កាលត្ថសត្តមី **កោចិ** បកតិកត្តាក្នុង **ន ភវេយ្យ** , **ន** បដិសេធក្នុង **ភវេយ្យ** ៗ អាខ្យាតបទ កត្តុវាចក , **មម** សាមិសម្ពន្ធក្នុង **ធុរំ** ៗ អវុត្តកម្មក្នុង **វហិតុំ** ៗ តុមត្ថសម្បទានក្នុង **សមត្ថោ** ៗ វិកតិកត្តាក្នុង **ភវេយ្យ** , **យំ** កិរិយាបរាមាស ក្នុង **ភវេយ្យ** ។ **ច** វាក្យារម្ភជោតក , **មម** សាមិសម្ពន្ធក្នុង **ធុរំ** ៗ អវុត្តកម្មក្នុង **វហិតុំ** ៗ តុមត្ថសម្បទានក្នុង **អសមត្ថ-** ,**កស្សចិ** ភាវាទិសម្ពន្ធក្នុង **អសមត្ថត្តំ** , **ឯតំ** វិសេសនៈរបស់ **អសមត្ថត្តំ** ៗ បកតិកត្តាក្នុង **ហោតិ** ៗ អាខ្យាតបទ កត្តុវាចក , **អនច្ឆរិយំ** វិកតិកត្តា ក្នុង **ហោតិ** ។

ឧ.ទី ៥ **អនច្ឆរិយំ ភិក្ខវេ ឯតំ យំ សត្ថោ ទេវរាជា មយិ សិនេហំ ករោតិ** (ធម្ម. សក្កវត្ថុ ៦/១៩៧) ។ សូមបញ្ចោក់ បទយោគ **ឯតំ** នោះ គឺទាញពី **ករោតិ** មកដូចពិធីផ្លាស់ពន្យល់នៅខាងលើដូច្នេះត្រូវផ្លាស់ **ករ** ធាតុជាមួយ **យុ** បច្ច័យ

ទៅជា **ករណំ** ។ ប្រែ. **ភិក្ខវេ** ម្នាលភិក្ខុទ. **សក្កោ** វីសក្កៈ **ទេវរាជា** ដែលជាស្ដេចនៃទេវតា **ករោតិ** ធ្វើ **សិនេហំ** នូវសេចក្ដីស្រលាញ់ **មយិ** ក្នុងព្រះតថាគត **យំ** ឯណា , **ឯតំ សក្កស្ស ទេវរាជស្ស មយិ សិនេហស្ស ករណំ** វីកិរិយាធ្វើនូវសេចក្ដីស្រលាញ់ក្នុងព្រះតថាគតរបស់សក្កៈ ដែលជាស្ដេចនៃទេវតានោះ **អនច្ឆរិយំ ហោតិ** មិនជាការអស្ចារ្យទេ ។ សម្ពន្ធស្រដៀងៗគ្នា សូមពិនិត្យសេចក្ដីខាងលើហើយសម្ពន្ធតាមនោះចុះ គ្រាន់តែក្នុងទីនេះ **សិនេហស្ស** ជាឆដ្ឋីកម្មក្នុង **ករណំ** ។

ចំពោះ **ឯតំ-យំ** នេះខ្ញុំធ្លាប់ប្រែជួបច្រើនក្នុងព្រះត្រៃបិដក ដូចនៅក្នុងសុត្តន្តបិដក លេខ ៤០ ចាប់ពីទំព័រ ៥៩ រហូតដល់ទំព័រ ៦៧ សុទ្ធតែជាប្រយោគ **ឯតំ_យំ** ដែលជាកិរិយាបរាមាសទាំងអស់ ឧ. **អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ កិញ្ចិ សង្ខារំ និច្ចតោ ឧបគច្ឆេយ្យ នេតំ ឋានំ វិជ្ជតិ** (អង្គុត្ត. ឯក-ទុកនិបាត ៤០/៥៩) ។ ម្នាលភិក្ខុទាំងឡាយ វីបុគ្គលដែលដល់ព្រមដោយទិដ្ឋិ គប្បីប្រកាន់មាំនូវសង្ខារណានីមួយ ថា ទៀង ឯណា វីភាវៈនៃបុគ្គលដែលដល់ព្រមដោយទិដ្ឋិ ប្រកាន់

មាំនូវសង្ខារណានីមួយ ថា ទៀង នោះ មិនមែនជាហេតុ មិនមែន ជាឱកាស មិនមែនជាឋានៈទេ ។ ឧទាហរណ៍មួយទៀតមានក្នុង វិនយបិដក **អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តថាគតោ អបរិសុទ្ធាយ បរិសាយ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ** (វិនយ. ចុល្លវគ្គ ១១/២១៦) ។ ម្នាលភិក្ខុទាំងឡាយ វីព្រះតថាគត គប្បីធ្វើឧបោសថ គប្បីសំដែងនូវបាតិមោក្ខ ដល់ បរិស័ទ ដែលមិនបរិសុទ្ធ ឯណា វីកិរិយាធ្វើនូវឧបោសថ កិរិយា សំដែងនូវបាតិមោក្ខរបស់តថាគត ដល់បរិស័ទដែលមិនបរិសុទ្ធនោះ មិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ។ ប្រយោគនេះមាន ច្រើនក្នុង អដ្ឋកថា ដីកា មង្គលត្ថទីបនី វិសុទ្ធិមគ្គ កង្ខាវិតរណី សមន្តប្បាសាទិកាជាដើម កាលបើកុលបុត្របានសិក្សាយល់ច្បាស់ នូវឧទាហរណ៍នេះហើយ ក៏ជាការងាយស្រួលក្នុងការប្រែគម្ពីរទាំង នោះ ទើបខ្ញុំមិនលើកជាឧទាហរណ៍ដាក់ក្នុងទីនេះ នាំឱ្យវែងឆ្ងាយ នោះទេ ។

## **យំ_តស្ស យំ_តេន**

ឧ. ទី ១ **យំ បន សោ ទីឃរត្តំ ពុទ្ធវចនំ វាចេសិ**

**ពុទ្ធស្ស វណ្ណំ កថេសិ តស្ស និស្សន្ទេន ឥមំ សុវណ្ណ-វណ្ណំ បដិលភតិ , យំ ភិក្ខូនំ អក្កោសកបរិភាសកោ អហោសិ តេនស្ស មុខតោ ទុគ្គន្ធោ វាយតិ** (ធម្មបទ.. កបិលមច្ឆ. ៨/៧) ។ **បទ** ក៏ **សោ កបិលោ** រីកបិលនោះ **វាចេសិ** តែងបង្រៀន **ពុទ្ធវចនំ** នូវពុទ្ធវចនៈ **កថេសិ** តែងពោល **វណ្ណំ** នូវគុណ **ពុទ្ធស្ស** នៃព្រះពុទ្ធ **ទីឃរត្តំ** អស់កាលយូរអង្វែង **យំ** ឯណា **សោ កបិលោ** រីកបិលនោះ **បដិលភតិ** បានចំពោះ **សុវណ្ណវណ្ណំ** នូវសម្បុរដូចសម្បុរនៃមាស **ឥមំ** នេះ **និស្សន្ទេន** ដោយអានិសង្ស **តស្ស កម្មស្ស** នៃកម្មនោះ , **សោ កបិលោ** រីកបិលនោះ **អក្កោសកបរិភាសកោ អហោសិ** ជាអ្នកជេរប្រទេចនិងផ្តាសា **ភិក្ខូនំ** នូវភិក្ខុទាំងឡាយ **យំ** ឯណា , **ទុគ្គន្ធោ** រីក្លិនស្អុយ **វាយតិ** តែងផ្សាយចេញ **មុខតោ** អំពីមាត់ **អស្ស កបិលស្ស** នៃកបិលនោះ **តេន កម្មេន** ដោយកម្មនោះ ។ **យំ** ជាកិរិយាបរាមាសក្នុង **វាចេសិ** និង **កថេសិ** , **តស្ស** ជាវិសេសនៈរបស់ **កម្មស្ស** ។ សាមិសម្ពន្ធក្នុង **និស្សន្ទេន, យំ** មួយទៀតជាកិរិយាបរាមាសក្នុង **អហោសិ, ភិក្ខូនំ** ប្រែថា **នូវ** នោះជា ឆដ្ឋី-

កម្មក្នុង **អក្កោសកបរិភាសកោ ,តេន** ជាវិសេសនៈរបស់ **កម្មេន** ៗ ករណៈក្នុង **វាយតិ** , ហើយសម្ពន្ធយ៉ាងណាទៀតនោះ សូមសម្ពន្ធយ៉ាងនោះចុះ ។

## យស្មា- តស្មា

ចំពោះ **យស្មា-តស្មា** តាមធ្លាប់សិក្សាមកឃើញថាមានប្រើច្រើនជាង **តំ-យំ** ទៅទៀត ពិសេសនៅក្នុងគម្ពីរជាន់អដ្ឋកថា ដីកាឬក៏នៅក្នុងដីកាព្រះគន្ថរចនាចារ្យលោកខែបទ **យំ** នេះថា ស្មើពាក្យ **យស្មា** ដើម្បីបញ្ជាក់ដល់ប្រយោគកិរិយាបរាមាស ដូចនៅក្នុងនៅក្នុងគម្ពីរសីលក្ខន្ធវគ្គដីកា ឈ្មោះ លីនត្ថប្បកាសិនី ខែលើអដ្ឋកថា សុមង្គលវិលាសិនី ព្រហ្មជាលសូត្រថា **យន្តិ យស្មា , យេន ការណេនាតិ វុត្តំ ហោតិ , កិរិយាបរាមសនំ វា ឯតំ ។** ឬនៅក្នុងគម្ពីរសីលក្ខន្ធវគ្គ-អភិនវដីកា ឈ្មោះ សាធុវិលាសិនីខែថា **យន្តិ យស្មា , កិរិយាបរាមសនំ វា ឯតំ ។** ដូច្នេះឃើញថា **យស្មា-តស្មា**មានប្រើច្រើនណាស់ នៅក្នុងគម្ពីរជាន់ប្រយោគធំ ៗ តែសូមបញ្ជាក់ថា មិនមែនសុទ្ធតែជាកិរិយាបរាមាសទាំងអស់នោះទេ **យស្មា** ដែលជាកិរិយាបរាមាសនោះគឺសំដៅ

ដល់ **យស្មា** ដែលជាវិសេសនៈរបស់ពាក្យក្នុងប្រយោគទាំងអស់ តែចំពោះ **យស្មា** ដែលគ្រាន់តែសំដែងឡើងនូវហេតុ ទោះបីមាន **តស្មា** ទទួលដូចកិរិយាបរាមាសក៏ដោយ តែមិនហៅថា កិរិយាប-រាមាសទេ ដូចពាក្យថា **យស្មា បមាណំ ឥធ បណ្ឌិតានំ** (សមន្ត.១/៥) វិពាក្យនោះ ជាប្រមាណដល់បណ្ឌិតទ. ក្នុងសាសនានេះ ព្រោះហេតុណា ។ យោជនា ១/១៩ យស្មាតិ បទំ បមាណន្តិ បទេ ហេតុ ។

កិរិយាបរាមាស

ឧ. **យស្មា បុរេ អដ្ឋកថា អកំសុ** (សមន្ត.១/៤ . ៣/២០៤) ។ ប្រែ.**សីហឡដ្ឋកថាចរិយា** វិព្រះអដ្ឋកថាចារ្យជនជាតិសីហឡទ. **អកំសុ** បានធ្វើហើយ **អដ្ឋកថា** នូវអដ្ឋកថាទ. **បុរេ** ក្នុងកាលមុន **យស្មា** ព្រោះហេតុណា ។ យោជនា ១/១៦ថា យស្មាតិ បទំ អកំសូតិ បទេ កិរិយាបរាមសនំ ។

ឧ.ទី ២ **យស្មា ជរាព្យាធិមរណមិស្សតាយ ជាតិនាមេសា បុនប្បុនំ ឧបគន្តុំ ទុក្ខា ន ច សា តស្មឹ អទិដ្ឋេ និវត្តតិ តស្មា តំ គវេសន្តោ សន្ធាវិស្សំ** (ធម្ម.

បឋមពោធិវត្ថុ ៥/១៨០) ។ ប្រែ. **ឯសា ជាតិ នាម** ឈ្មោះថា រីជាតិនោះ **ទុក្ខា** ឈ្មោះថាជា ទុក្ខ **ឧបគន្តុំ** ដើម្បីចូលដល់ **បុនប្បុនំ** ញយ ៗ **ជរាព្យាធិមរណមិស្សតាយ** ព្រោះលាយឡំទៅដោយ ជរា និង ព្យាធិ, **ច** ក៏ **តស្មឹ គហការកេ** នាកាលជាងធ្វើនូវផ្ទះនោះ **អទិដ្ឋេ** ដែលយើងមិនឃើញហើយ **សា ជាតិ** រីជាតិនោះ **ន និវត្តតិ** តែងមិនត្រឡប់វិញ **យស្មា** ព្រោះហេតុណា , **តស្មា** ព្រោះហេតុនោះ **អហំ** រីអញ **គវេសន្តោ** កាលស្វែងរក **តំ គហការកំ** នូវជាងអ្នកធ្វើនូវផ្ទះនោះ **សន្ធាវិស្សំ** អន្ទោលត្រាច់ទៅហើយ ។ សម្ពន្ធ **យស្មា** កិរិយាបរាមាសក្នុង **ន និវត្តតិ** , **តស្មា** ហេតុ ក្នុង **សន្ធាវិស្សំ** ។

ឧ.ទី ៣ **យស្មា នាព្វណំ វិសមេន្វតិ ( តស្មា ហរេយ្យ បាណិនា វិសំ )** ធម្ម. កុក្កុដមិត្ត. ៥/៤១ ប្រែ. **វិសំ** រីថ្នាំពិស **ន អន្វេតិ** តែងមិនជ្រាបចូល **បាណឹ** នូវបាតដៃ **អព្វណំ** ដែលមិនមានដំបៅ **យស្មា** ព្រោះហេតុណា , **តស្មា** ព្រោះហេតុនោះ **បុគ្គលោ** រីបុគ្គល **ហរេយ្យ** គប្បីនាំ **វិសំ** នូវថ្នាំពិស **បាណិនា** ដោយបាតដៃបាន ។ សម្ពន្ធ **យស្មា**

កិរិយាបរាមាសក្នុង **ន អន្វេតិ** , **តស្មា** ហេតុ ឬហេតុត្ថវាចក ក្នុង **ហរេយ្យ** ។

នៅក្នុងគម្ពីរខ្លះព្រះគន្ថរចនាចារ្យដាក់ **ហិ** ជំនួស **យស្មា** ក៏មាន ហើយមានការទទួលដោយ **ឥតិ** ស័ព្ទ នេះសំដៅដល់កិរិយាបរាមាស គឺ

**ហិ_ឥតិ**

ឧ. **សោ ហិ ភគវា**

**វធកេ ទេវទត្តម្ហិ ចោរេ អង្គុលិមាលិកេ**

**ធនបាលេ រាហុលេ ច សព្វត្ថ សមមានសោតិ**

**ទស្សេថ មេ នំ ភគវន្តន្តិ បុនប្បុនំ យាចិ** (ធម្ម. ទេវទត្តវត្ថុ ១/២១៣) ។ ប្រែ. **ភគវា** រីព្រះដ៏មានព្រះភាគ **សោ** អង្គនោះ **សមមានសោ ហោតិ** ព្រះអង្គទ្រង់ជាអ្នកមានព្រះទ័យស្មើ **សព្វត្ថ ជនេសុ** ក្នុងជនទាំងឡាយទាំងពួង **វធកេ ច** គឺនាយខ្មាន់ធ្នូផង **ទេវទត្តម្ហិ ច** គឺ ទេវទត្តផង **អង្គុលិមាលិកេ ចោរេ ច** គឺចោរ អង្គុលិមាលផង **ធនបាលេ ច** គឺដំរីធនបាលផង **រាហុលោ ច** គឺរាហុលផង **ហិ** ព្រោះហេតុណា **ឥតិ** ព្រោះហេតុនោះ

**សោ ទេវទត្តោ** វីទេវទត្តនោះ **យាចិ** អង្វរហើយ **បុនប្បុនំ** ញយ ៗ **ទស្សេថ មេ នំ ភគវន្តំ ឥតិ** ថាវីអ្នកទាំងឡាយ សូមសំដែងនូវព្រះដ៏មានព្រះភាគអង្គនោះ ដល់ខ្ញុំ ដូច្នេះ ។ សម្ពន្ធ. **ភគវា** បកតិកត្តា ក្នុង **ហោតិ** អាខ្យាតបទ កត្តុវាចក , **ច** ទាំង ៥ ជាបទសមុច្ចយត្ថ , **វធកេ** ក្តី **ទេវទត្តម្ហិ** ក្តី **អង្គុលិមាលិកេ** **ចោរេ** ក្តី **ធនបាលេ** ក្តី **រាហុលេ** ក្តី ជាវិសេសលាភីក្នុង **សព្វត្ថ ជនេសុ**, **សព្វត្ថ** វិសេសនៈរបស់ **ជនេសុ** ៗ ភិន្នាធារៈក្នុង **សមមានសោ**ៗ វិកតិកត្តា ក្នុង **ហោតិ** , **ហិ** កិរិយាបរាមាសក្នុង **ហោតិ** , **ឥតិ** ហេតុ ក្នុង **យាចិ** (សម្ពន្ធយ៉ាងណាទៀត សូមសម្ពន្ធតាមនោះចុះ) ។

សូមកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ក្នុងការសិក្សាភាសាបាលីស្រាវជ្រាវតាមឧទាហរណ៍ ដែលខ្ញុំលើកឡើងហើយ សូមសង្កេតពិនិត្យហើយពិនិត្យទៀត កាលបើប្រែជួបនូវប្រយោគដូចខាងលើនេះហើយ ទោះបីនៅក្នុងគម្ពីរធំ ៗ មានអដ្ឋកថា ដីកាក៏ដោយ ហើយសង្កេតពិនិត្យឃើញមានប្រយោគនិងវេយ្យាករណ៍

និងការសម្ពន្ធអាចប្រព្រឹត្តទៅបាន មិនទាស់ខុសត្រូវចងចាំទុកឱ្យច្បាស់ថា **នេះជាប្រយោគ កិរិយាបរាមាស** ។

**ប្រយោគកិរិយាបរាមាស**

**ចប់ដោយសង្ខេប**

# ប្រយោគនាគសោណ្ឌិគតិ

(ដំណើរដូចដំរីយោលដៃ)

ប្រយោគនេះមានទំនងហាក់ដូចជាប្រយោគកិរិយាបរាមាសដែរ ទើបខ្ញុំរៀបឡើងតាមលំដាប់នៃប្រយោគកិរិយាបរាមាសនោះ ព្រោះថាប្រយោគនេះក៏ប្រើ**យស្មា តស្មា ,ហិ តស្មា** ដែរ តែប្រយោគនេះផ្សេងពីកិរិយាបរាមាសនោះគឺការសំដែងឡើងនូវហេតុ ហើយការទទួលក៏ជាហេតុ , វេលាសម្ពន្ធថា ហេតុ ទាំងពីរចំណែក, ចំណែកកិរិយាបរាមាសវិញ សំដែងឡើងនូវកិរិយារបស់ប្រយោគទាំងមូលមិនមែនជាវិសេសនៈរបស់នាមនាមណាមួយឡើយហើយក៏មិនមែនជាការសំដែងនូវហេតុដែរ ព្រោះហេតុនោះ សូម្បីមាន **យស្មា តស្មា , ហិ តស្មា** , ដូចកិរិយាប-រាមាសក៏ដោយ តែមិនហៅថា កិរិយាបរាមាសទេ ។ ចំណែកឈ្មោះថា នាគសោណ្ឌិគតិ នេះមិនមានប្រាកដក្នុង អដ្ឋកថា ដីកា យោជនាឡើយ តែបណ្ឌិតបោរាណាចារ្យលោកបានចងក្រងការប្រែប្រយោគនេះឱ្យមានការប្រែត្រឡប់ចុះ ហើយត្រឡប់ឡើងវិញ ឱ្យស្តាប់សេចក្តីបានងាយស្រួល, ទើបលោកពោលដំណើរនៃប្រយោគទុកក្នុងគម្ពីរ " គតិប្ប-ករណ៏" ឡើង ។ ចំណែកបណ្ឌិតជំនាន់តមកក្រោយឃើញថា ប្រយោគនេះមានខ្លឹមសារគួររៀនសូត្រដល់កុលបុត្រទាំងឡាយ ទើបនាំត ៧ គ្នា

មករហូតមកដល់សព្វថ្ងៃនេះ ។ សូមចំណាំនាគសោណ្ឌិគតិនេះ មានការចែកជាពីរគឺ លោកសំដែងផលជាមុនទើបសំដែងហេតុជាខាងក្រោយ ហើយនាគសោណ្ឌិនេះជាឈ្មោះចំណែកខាងក្រោយ ព្រោះបញ្ជូនសេចក្ដីត្រឡប់ទៅចំណែកលើវិញ ។ម្យ៉ាងទៀត ទោះបីនៅក្នុងគាថាមិនដាក់ ហិ ស័ព្ទ មកក៏ដោយ តែអដ្ឋកថាកែអត្ថប្រាកដជាដាក់ ហិ ស័ព្ទមកដើម្បីបញ្ជាក់ដល់ប្រយោគហេតុមិនខាន ។ ចំពោះនាគសោណ្ឌិនេះមិនមែនជាឈ្មោះសម្ពន្ធទេ សម្ពន្ធហៅតាមអត្ថដែលប្រែ ។ លើកឧទាហរណ៍បាលីសំដែងផលខាងដើម ហេតុខាងចុងដូចជា ៖

**សន្តិមគ្គមេវ ព្រូហយ**

**និព្វានំ សុគតេន ទេសិតំ ។**

សេចក្ដីចំណែកដើមគឺ "**សន្តិមគ្គមេវ ព្រូហយ**" អ្នកចូរញុំាងនូវសេចក្ដីស្ងប់ឱ្យចំរើនមែនពិត , ពាក្យនេះពោលផល , ឯសេចក្ដីចំណែកក្រោយគឺ "**និព្វានំ សុគតេន ទេសិតំ** " និព្វានដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ , ពោលហេតុ តែមិនបានដាក់ការណជោតកនិបាតទុកទេ , ដើម្បីសំដែងអធិប្បាយឱ្យច្បាស់គប្បីប្រកបយ៉ាងនេះ ៖

**សន្តិមគ្គមេវ ព្រូហយ**

**និព្វានំ ហិ សុគតេន ទេសិតំ ។**

ការប្រកបសេចក្តីទាំងពួងនោះ កន្លែងខ្លះពោលហេតុមុនឱ្យហេតុអនុលោមដល់ផល នេះជាប្រយោគធម្មតា , កន្លែងខ្លះពោលផលមុនហេតុឱ្យហេតុអនុលោមចំពោះផល នេះជានាគសោណ្ឌិ , នាគ-សោណ្ឌិនេះមានក្នុងគម្ពីរធម្មបទច្រើនកន្លែង ព្រះអដ្ឋកថាចារ្យកែអត្ថជា **យស្មា តស្មា , ហិ តស្មា** ក៏មាន ឬដាក់តែ **យស្មា , ហិ** ក៏មាននឹងសំដែងឧទាហរណ៍ដូចតទៅ ៖

ឧ.ទី ១ **និព្វានំ ហិ សុគតេន ទេសិតំ , តស្មា តស្ស មគ្គំ ភាវេហិ** ( ធម្ម. សារីបុត្តត្ថេរស្ស សទ្ធិវិហារិកវត្ថុ ៧/១២១-១២២ ) ។ ប្រែ. **និព្វានំ** រីព្រះនិព្វាន **សុគតេន** គឺព្រះសុគត **ទេសិតំ** ទ្រង់សំដែងហើយ **ហិ** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **ត្វំ** រីអ្នក **មគ្គំ** ញុំាងមគ្គ **តស្ស និព្វានស្ស** នៃព្រះនិព្វាននោះ **ភាវេហិ** ឱ្យចំរើន ។ សម្ពន្ធ **ហិ** ស័ព្ទ ហេតុ ក្នុង **ទេសិតំ , និព្វានំ** វុត្តកម្មក្នុង **ទេសិតំ** ៗ អាខ្យាតបទ កម្មវាចក **សុគតេន** អនភិហិតកត្តាក្នុង **ទេសិតំ , តស្មា** ហេតុក្នុង **ភាវេហិ , ត្វំ** សយកត្តាក្នុង **ភាវេហិ**ៗ អាខ្យាតបទ កត្តុវាចក , **តស្ស** វិសេសនៈរបស់ **និព្វានស្ស** ៗ សាមិ-សម្ពន្ធក្នុង **មគ្គំ** ការិត្តកម្ម ក្នុង **ភាវេហិ** ។

ឧ.ទី ២ **បុញ្ញស្ស ហិ ឧច្ចយោ វុឌ្ឍិ ឥធលោកបរលោ-**

**កសុខាវហនតោ សុខោ** (ធម្ម. លាជទេវធីតាវត្ថុ ៥/១៤) ។ នេះជាអដ្ឋកថាកែអត្ថ "**សុខោ បុញ្ញស្ស ឧច្ចយោ**" ដែលពោលហេតុចំណែកដើមគឺ "**តម្ហិ ឆន្ទំ កយិរាថ**" លោកតែងប្រយោគកែអត្ថថា **កឹការណា ? សុខោ បុញ្ញស្ស ឧច្ចយោតិ បុញ្ញស្ស ហិ ឧច្ចយោ វុឌ្ឍិ ឥធលោកបរលោកសុខាវហនតោ សុខោតិ** ។ សួរថា (បុគ្គលគប្បីធ្វើនូវសេចក្ដីពេញចិត្តក្នុងបុណ្យនោះ) ព្រោះហេតុអ្វី ? (កែថា) **ឧច្ចយោ** វិការសន្សំ **បុញ្ញស្ស** នូវបុណ្យ **សុខោ ហោតិ** ជាសភាវៈនាំមកនូវសេចក្ដីសុខ **ហិ** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ**បុគ្គលោ** វិបុគ្គល **កយិរាថ** គប្បីធ្វើ **ឆន្ទំ** នូវសេចក្ដីពេញចិត្ត **តម្ហិ បុញ្ញស្មឹ** ក្នុងបុណ្យ នោះ , **អត្ថោ** វិសេចក្ដីអធិប្បាយ **បុញ្ញស្ស ។ ល ។ សុខោ ឥតិ** ថាដូច្នេះ **ឧច្ចយោ** វិការសន្សំ **ឧច្ចយោ** គឺថា **វុឌ្ឍិ** ៗ វិការចំរើន **បុញ្ញស្ស** នូវបុណ្យ **សុខោ** ឈ្មោះថាឱ្យកើតសុខ **ឥធលោកបរលោកសុខាវហនតោ** ព្រោះជាគ្រឿងនាំមកនូវសេចក្ដីសុខក្នុងលោកនេះនិងលោកខាងមុខ **ហិ** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **បុគ្គលោ** វិបុគ្គល **កយិរាថ** គប្បីធ្វើ **ឆន្ទំ** នូវសេចក្ដីពេញចិត្ត **តម្ហិ បុញ្ញស្មឹ** ក្នុងបុណ្យនោះ ។ ការសម្ពន្ធមិនជាការលំបាកទេ សូមពិនិត្យមើលរបៀបសម្ពន្ធខាងលើហើយ

សម្ពន្ធចុះ ។

ឧ.ទី ៣ **ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ ។** នៅក្នុងអដ្ឋកថាខែថា **កឹការណា, មរណន្តំ ហិ ជីវិតំ ។ យស្មា សព្វសត្តានំ ជីវិតំ មរណបរិយោសានមេវាតិ វុត្តំ ហោតិ** ( ធម្ម. ឧត្តរាថេរីវត្ថុ ៥/១៥៦ ) ។ **ភិជ្ជតិ បូតិ សន្ទេហោ** នេះជាផល , ចំណែក **មរណន្តំ ហិ ជីវិតំ** នេះពោលហេតុជាចំណែកដើម, **ហិ** នោះព្រះអដ្ឋកថាបានខែថា ស្មើនឹងពាក្យ **យស្មា** ព្រោះហេតុនោះ ប្រយោគនេះជានាគសោណ្ឌិ ។ **សន្ទេហោ** រីកាយ **បូតិ** ដ៏ស្អុយ **ភិជ្ជតិ** តែងបែកធ្លាយ **ជីវិតំ** រីជីវិត **មរណន្តំ** ដែលមានសេចក្តីស្លាប់ក្នុងទីបំផុត **ហិ** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **សន្ទេហោ** រីកាយ **បូតិ** ដ៏ស្អុយ **ភិជ្ជតិ** តែងបែកធ្លាយ ។ តាមបោរាណាចារ្យខ្លះប្រែថា **ហិ** ព្រោះថា **ជីវិតំ** រីជីវិត **មរណន្តំ** មានសេចក្តីស្លាប់ក្នុងទីបំផុត ប្រែយ៉ាងនេះ **ហិ** ជាការណជោតកៈ បំភ្លឺដល់ផល , តែចំពោះ **ហិ** ក្នុងទីនេះ បោរាណបណ្ឌិតឱ្យប្រែបែបជានាគសោណ្ឌិ ( បែបដំរីយោលដៃ គឺប្រែទៅហើយត្រឡប់មកវិញ ) ។

ឧ.ទី ៤ **មញ្ញាមិ តុវំ មរិស្សសិ ន ហិ ត្វំ លច្ឆសិ ចន្ទិមសុរិយេ** ( ធម្ម.មដ្ឋកុណ្ឌលិ. ១/៤២) ។ នៅក្នុងគម្ពីរធម្មបទដ្ឋ-

កថាគាថាយោជនា ទំព័រ ១០ខែថា **ហិ យស្មា តុវំ , ចន្ទិមសុរិយេ ចន្ទសុរិយេ , ន លច្ឆសិ ន លភិតោ អសិ , តស្មា ត្វំ តុវំ មរិស្សសិ មរណំ ភវិស្សតីតិ មញ្ញាមិ ចិន្តេមីតិ ។** តាមក្នុងយោជនាលោកខែពន្យល់ឃើញថា **ហិ** ស្មើ **យស្មា** , ហើយលោកបន្ថែម **តស្មា** ទទួលមកឱ្យទៀតដើម្បីឱ្យច្បាស់ថា នេះប្រែបែបនាគសោណ្ឌិ ។ ប្រែ. **អហំ** វីខ្ញុំ **មញ្ញាមិ** សំគាល់ **តុវំ មរិស្សសិ ឥតិ** ថាវីអ្នកនឹងស្លាប់ដូច្នេះ **ត្វំ** វីអ្នក **ន លច្ឆសិ** មិនបាន **ចន្ទិម-សុរិយេ** នូវព្រះច័ន្ទនិងព្រះអាទិត្យ **ហិ** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **តុវំ** វីអ្នក **មរិស្សសិ** នឹងស្លាប់ ។ សម្ពន្ធ **ហិ** ហេតុ ក្នុង **ន លច្ឆសិ** , **តស្មា** ហេតុក្នុង **មរិស្សសិ** ។

ឧ.ទិ ៥ **សយមានោ ន គច្ឆាមិ នត្ថិ ពាលេ សហាយតា** (ធម្ម. ចក្ខុបាលត្ថេរ. ១/២៣) ។ **អហំ** វីអញ **សយមានោ** កាលដេក **អរញ្ញេ** ក្នុងព្រៃ **ឥមស្មឹ** នេះ **ន គច្ឆាមិ** មិនព្រមទៅ **សទ្ធឹ** ជាមួយ **តយា** នឹងអ្នក , **សហាយតា** វីសហាយតាគុណ **នត្ថិ** មិនមាន **ពាលេ** និមិត្តពាល **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **អហំ** វីអញ **ន គច្ឆាមិ** មិនព្រមទៅ **សទ្ធឹ** ជាមួយ **តយា** នឹងអ្នកឡើយ ។ ការសម្ពន្ធសូមមើលឧទាហរណ៍ខាងលើ ។

ឧ.ទី ៦ **អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**

**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។**

(ធម្ម. ចុល្លកាឡមហាកាឡ.១/១០១) ប្រែ.**សង្ខារា** វិសង្ខារទ. **អនិច្ចា វត** មិនទៀងទេហ្ន៎**ឧប្បាទវយធម្មិនោ** មានកិរិយាកើតឡើងនិងវិនាសទៅវិញជាធម្មតា **ឧប្បជ្ជិត្វា** កើតឡើងហើយ **និរុជ្ឈន្តិ** តែងរលត់ទៅ **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **សង្ខារា** វិសង្ខារទ. **អនិច្ចា វត** មិនទៀងទេហ្ន៎, **វូបសមោ** វិការស្ងប់រម្ងាប់ **តេសំ សង្ខារានំ** នៃសង្ខារទ.នោះ **សុខោ ហោតិ** ទើបជាសុខ ។ ប្រយោគនៅក្នុងផ្ទៃរឿងច្រើនមានពាក្យនិយាយគ្នា អ្នកសួរដល់ហេតុនោះថា ព្រោះហេតុអ្វី ? អ្នកឆ្លើយក៏ឆ្លើយដល់ហេតុនោះភ្លាម តែមិនបានប្រើស័ព្ទដែលប្រកបដោយវិភត្តិ ដែលអាចចេញសំឡេង អាយ-តនិបាតថា "ព្រោះ" ដូចគ្នាផងឡើយ ដូចជា ៖

ព្រះរាជាទ្រង់សួរថា **ភោ ឧបាសក កិន្តេ ឆត្តបាហនា អបនីតា** ។ **ឧបាសក** នែ៎ឧបាសក **ភោ** ដ៏ចំរើន **ឆត្តុបាហនា** វិឆ័ត្រនិងស្បែកជើង **តេ** គឺលោក **អបនីតា** ដម្លោះ-ដោះហើយ **កឹ** ព្រោះហេតុអ្វី ? ។ ឆត្តបាណិឧបាសកឆ្លើយថា **រាជា បក្កោសតីតិ សុត្វា អបនេត្វា អាគតោម្ហិ** (ធម្ម.ឆត្តបាណិឧបាសក. ៣/៧០) ។ **អហំ** វិខ្ញុំព្រះអង្គ **សុត្វា** ឮហើយ **រាជា បក្កោសតិ ឥតិ** ថា

ព្រះរាជាត្រាស់ហៅដូច្នេះ **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **អបនេត្វា** ដម្លោះ-ដោះហើយ **ឆត្តុបាហនំ** នូវឆ័ត្រនិងស្បែកជើង **អាគតោ អម្ហិ** ជាអ្នកមកហើយ ។

អាចារ្យខ្លះបានឱ្យឈ្មោះសម្ពន្ធប្រយោគបែបនេះថា**កិរិយាបរា-មាស** តែយើងជាអ្នកសិក្សាត្រូវពិចារណាមើលថា កិរិយាបរាមាសសំដៅលើអ្វី ហើយនាគសោណ្ឌិនេះសំដៅលើអ្វី តាមពិតកិរិយាបរាមាសលោកចង់សំដែង **យំ យស្មា ហិ** ដែលជាវិសេសនៈរបស់ពាក្យរហូតដល់កិរិយា ទើបជាកិរិយាបរាមាស បើមិនដូច្នោះទេ ទោះបីមាន **យំ យស្មា ហិ** ក៏ដោយ មិនឈ្មោះ កិរិយាបរាមាសឡើយ តែចំពោះនាគសោណ្ឌិនេះសំដៅដល់ **យស្មា ហិ** ដែលពោលឡើងនូវហេតុហើយបញ្ជូនសេចក្តីទៅផល ព្រោះលោករៀងបាលីផលនៅខាងដើម ទើបរៀងបាលីហេតុនៅខាងក្រោយ ដូច្នេះ **យស្មា ហិ** ក្នុងទីនេះគឺសំដែងឡើងនូវហេតុផ្សេងពីកិរិយាបរាមាសទាំងស្រុង ដូច្នេះ ត្រូវតែសម្ពន្ធថាហេតុ , ចំណែកពាក្យទទួលនោះក៏ត្រូវសម្ពន្ធថា ហេតុ ដូចគ្នា ព្រោះសំដែងនូវហេតុដែរ ដូចនៅក្នុងគម្ពីរជាន់ អដ្ឋកថា ដីកា យោជនាលោកបញ្ជាក់ថា ៖

**អបរភាគេ ហិ វិនយបញ្ញត្តិយាចនហេតុភូតោ អាយស្ម-តោ សារីបុត្តស្ស បរិវិតក្កោ សិទ្ធោ ។ តស្មា យេន**

**សមយេន សោ បរិវិតក្កោ ឧទបាទិ តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ** (សមន្តប្បាសាទិកា ១/១៨១។ ប្រែ. **អបរភាគេ** ក្នុងចំណែកជាខាងក្រោយមក **បរិវិតក្កោ** វីបរិវិតក្កៈ **វិនយប្បញ្ញត្តិយាចនហេតុភូតោ** ដែលជាហេតុសូមបញ្ញត្តិនូវព្រះវិន័យ **សារីបុត្តស្ស** របស់ព្រះសារីបុត្រ **អាយស្មតោ** ដ៏មានអាយុ **សិទ្ធោ** សម្រេចហើយ **ហិ** ព្រោះហេតុណា ។ **តស្មា** ព្រោះហេតុនោះ **បរិវិតក្កោ** វីបរិវិតក្កៈ **សោ** នោះ **ឧទបាទិ** កើតឡើងហើយ **សមយេន** ក្នុងសម័យ **យេន** ឯណា **សមយេន** ក្នុងសម័យ **តេន** នោះ **ពុទ្ធោ** វីព្រះពុទ្ធ **ភគវា** ដ៏មានព្រះភាគ **វិហរតិ** ទ្រង់គង់នៅ **វេរញ្ជាយំ** ក្នុងស្រុកវេរញ្ជា ។ នៅក្នុងគម្ពីរសារត្ថទីបនីដីកា ១/២៤១ ខែពន្យល់ថា **អបរភាគេ ហីតិ ឯត្ថ ហិ-សទ្ទោ ហេតុម្ហិ , យស្មាតិ អត្ថោ** ។ ប្រែ វិនិច្ឆ័យក្នុងពាក្យថា **អបរភាគេ ហិ** ដូចតទៅ **ហិ** ស័ព្ទប្រព្រឹត្តទៅក្នុងហេតុ , អធិប្បាយថា ព្រោះហេតុណា ដូច្នេះ ។ ចំណែក**តស្មា** យោជនា ១/៩៩ខែពន្យល់ថា **តស្មាតិ បទំ វេទិតព្វោតិ បទេ ហេតុ** ។ បទថា **តស្មា** ជា ហេតុ ក្នុងបទថា **វេទិតព្វោ** ។ ដូច្នេះនៅក្នុងដីកា សម្ពន្ធ **ហិ** ថាជា ហេតុ **តស្មា** យោជនាក៏សម្ពន្ធថា ហេតុ ដែរ សរុបមកនៅក្នុងប្រយោគសោណ្ឌិនេះ សម្ពន្ធថា ហេតុ ទាំងពីរចំណែក ។

៨៩

សូមអ្នកសិក្សាពិចារណាឱ្យបានល្អិតល្អន់ថែមទៀតផង ។

**ចប់នាគសោណ្ឌិគតិ**

**ដោយសង្ខេប**

## ប្រយោគកិរិយាបធានន័យ

(១) បទកិរិយា ត្វា បច្ច័យដែលដាក់ទុកក្នុងទីបំផុតសេចក្ដីហៅឈ្មោះថា **កិរិយាបធាននយោ** ។ កិរិយាបធានន័យនេះ លោកដាក់ទុកក្នុងទីបំផុតសេចក្ដីមុខខ្លះ ក្រោយខ្លះ ក្នុងសេចក្ដីច្រើនចំណែកដែលពោលរួមហើយបែក ឬបែកហើយរួម , តែក្នុងទីបំផុតក៏មានកិរិយាក្នុងពាក្យស្មើឧ.**ឥមេសំ សត្តានំ ជាតិអាទយោ នាម ទណ្ឌហត្ថ-គោបាលកសទិសា ជាតិ ជរាយ សន្តិកំ បេសេត្វា ជរា ព្យាធិនោ សន្តិកំ ព្យាធិ មរណស្ស សន្តិកំ មរណំ កុធារិយា ឆិន្ទន្តា វិយ ជីវិតំ ឆិន្ទតិ ។**

អធិប្បាយ : (១) ឈ្មោះថា កិរិយាបធានន័យនេះ ប្រើហៅបទ **ត្វា** បច្ច័យ ដែលដាក់ទុកក្នុងទីបំផុតសេចក្ដី , នឹងពោលថា បទកិរិយាតូនាទិបច្ច័យ ដូច្នេះក៏បាន តែជួបតែកិរិយា ត្វា បច្ច័យជាផ្ទៃ ។ ប្រយោគដែលដាក់បទកិយា ត្វា បច្ច័យទុកជាទីបំផុតនេះនឹង ហៅថាពាក្យក៏មិនស្និទ្ធព្រោះជំទាស់ដោយកិរិយាក្នុងទីបំផុតជាកិរិយា ត្វា បច្ច័យដែលជាជាន់កិរិយាក្នុងព្យាង្គ , នឹងចាត់ចូលក្នុងកិរិយាព្យាង្គលិង្គត្ថៈក៏មិនសម ព្រោះក្នុងព្យាង្គលិង្គត្ថៈសូម្បីមានបទកិរិយាក្នុងទីបំផុត ក៏ជាបទកិរិយាដែលប្រើជាវិសេសនៈរបស់បទប្រធានបាន (កិរិយា អន្ត មាន បច្ច័យ), នឹងហៅបទប្រធានថា លិង្គត្ថៈ តែក្នុងទីនេះបទកិរិយា ត្វា

បច្ច័យ ត្វា បច្ច័យ ដែលដាក់ទុកមិនមែនជាវិសេសនៈរបស់បទប្រធាន ពោលដោយរូបក៏ជារូបរបស់ពាក្យនោះឯង តែដែលដាក់កិរិយាក្នុងពាក្យ ទុកក្នុងទីបំផុត ត្រឡប់ដាក់ ត្វា បច្ច័យទុក , គួរមានយ៉ាងនេះ ទើប តាំងឈ្មោះបទកិរិយានោះថ្មីថា កិរិយាបធានន័យ គឺចាត់ជាកិរិយាដែល ជាប្រធាន គឺកិរិយាធំ , ចំណែកបទប្រធានដែលជាកត្តា ហៅឈ្មោះ កត្តា តាមកិរិយាក្នុងពាក្យនិងចាត់ជាជាន់ព្យាង្គ ប្រភេទដែលជាចំណែក មួយអំពីពាក្យ ( មិនមែនមួយចំណែក ៧ របស់ពាក្យ ) ព្រោះតាំងជា ប្រយោគរបស់ខ្លួនផ្សេង ដូចគ្នានឹងព្យាង្គលិង្គត្ថៈ ។

(២) ព្រោះហេតុអ្វីលោកទើបដាក់កិរិយា ត្វា បច្ច័យទុកក្នុងទី បំផុតសេចក្តី , បញ្ហានេះតបបានពីការសង្កេតតួយ៉ាងដែលលោកប្រើ , ពោលដោយសង្ខេប លោកប្រើក្នុងសេចក្តីដែលពោលរួម ៧ ញែក ៧ ដែលត្រូវចែកប្រយោគចេញច្រើនចំណែក គួរមានព្រោះហេតុនេះ ទើប ដាក់កិរិយា ត្វា បច្ច័យក្នុងទីបំផុតសេចក្តីដែលពោលចំណែករួម ឬពោល ញែក , នៅក្នុងចំណែកទីបំផុតក៏គង់ប្រើកិរិយាក្នុងពាក្យនោះឯង , ការ ដាក់កិរិយា ត្វា បច្ច័យទុកក្នុងទីបំផុតនោះ ទើបមានដូចអនុប្រយោគ ។

(៣) ក្នុងសេចក្តីដែលពោលរួម ៧ ញែក ៧ នោះដាក់កិរិយា ត្វា បច្ច័យទុកក្នុងចំណែកណា សង្កេតបានដោយលោកប្រើដូចតទៅនេះ ៖

ក. រួម-ញែក ក្នុងសេចក្តីច្រើនចំណែក ចំណែកដើមពោលរួម ចំណែកក្រោយពោលញែក , ដាក់ ត្វា បច្ច័យទុកក្នុងទីបំផុតនៃចំណែកពោលញែក ឧ. **ឥមេសំ សត្តានំ ជាតិអាទយោ នាម ទណ្ឌហត្ថគោបាលកសទិសា ជាតិ ជរាយ បេសេត្វា ជរា ព្យាធិនោ សន្តិកំ (បេសេត្វា) ព្យាធិ មរណស្ស សន្តិកំ (បេសេត្វា ) មរណំ កុធារិយា ឆិន្ទន្តា វិយ ជីវិតំ ឆិន្ទតិ** ( ធម្ម.ឧបោសថកម្ម. ៥/៨៤) ។ ប្រែ.**ជាតិអាទយោ សភាវធម្មា នាម** ឈ្មោះថា វិសភាវធម៌ទ. មានជាតិជាដើម **សត្តានំ** របស់សត្វទ. **ឥមេសំ** នេះ **ទណ្ឌហត្ថគោបាលកសទិសា ហោន្តិ** ប្រាកដស្មើដោយនាយឃ្វាលគោលមានដំបងក្នុងដៃ , **ជាតិ** វីជាតិ **បេសេត្វា** បញ្ជូនទៅ **សន្តិកំ** កាន់សំណាក់ **ព្យាធិនោ** នៃព្យាធិ , **ព្យាធិ** វីព្យាធិ **បេសេត្វា** បញ្ជូនទៅហើយ **សន្តិកំ** កាន់សំណាក់ **មរណស្ស** នៃមរណៈ **មរណំ** វីមរណៈ **ឆិន្ទតិ** កាត់ផ្តាច់ **ជីវិតំ** នូវជីវិត **កុធារិយា (រុក្ខំ ) ឆិន្ទន្តា វិយ** ដូចជាវីមនុស្សទ.កាលកាត់ផ្តាច់ ( នូវដើមឈើ) ដោយប៉ូថៅ ( ដូច្នោះ) ។

( ខ) រួម-ញែក ក្នុងសេចក្តីច្រើនចំណែកដូច ( ក) តែដាក់កិរិយា ត្វា បច្ច័យទុកក្នុងចំណែករួម ( ដាក់ត្រឡប់ពីឧ. ក .) ឧ. ៖

ឧ.ទី ១

**តេន កថិតំ សុត្វា ការកបុគ្គលា យថានុសិដ្ឋំ បដិ-បជ្ជិត្វា កេចិ បឋមជ្ឈានាទីនិ បាបុណន្តិ កេចិ វិបស្សនំ វឌ្ឍេត្វា មគ្គផលានិ បាបុណន្តិ** ( ធម្ម.ទ្វេសហាយកភិក្ខុ. ១/២៣០។ ប្រែ. **ការកបុគ្គលា** វិការកបុគ្គលទ. **សុត្វា** ស្តាប់ហើយ **ធម្មំ** នូវធមិ **តេន ភិក្ខុនា កថិតំ** ដែលភិក្ខុនោះសំដែងហើយ **បដិបជ្ជិត្វា** បដិបត្តិហើយ **យថានុសិដ្ឋំ** តាមការបង្រៀន , **កេចិ ភិក្ខូ** វិភិក្ខុទ. ពួកខ្លះ**បាបុណន្តិ** សម្រេច **បឋមជ្ឈានាទីនិ** នូវគុណជាតទ.មាន បឋមជ្ឈានជាដើម , **កេចិ ភិក្ខូ** វិភិក្ខុទ.ពួកខ្លះ **វឌ្ឍេត្វា** ចំរើនហើយ **វិបស្សនំ** នូវវិបស្សនា **បាបុណន្តិ** សម្រេច **មគ្គផលានិ** នូវមគ្គនិង ផលទ. ។

ឧ.ទី ២

**តេ ឯកមគ្គេនាបិ អគន្ត្វា ឯកោ បច្ឆិមទ្វារេន មគ្គំ គណ្ហិ ឯកោ បុរត្ថិមទ្វារេន** ( ធម្ម.សូករបេត.៧/១០៤ ) ។ ប្រែ. **អបិ** ក៏ **តេ ថេរា** វិព្រះថេរៈទ.នោះ **អគន្ត្វា** មិនទៅហើយ **ឯកមគ្គេន** តាមផ្លូវជាមួយគ្នា , **ឯកោ ថេរោ** វិព្រះថេរៈមួយអង្គ **គណ្ហិ** កាន់យក ហើយ **មគ្គំ** នូវផ្លូវ **បច្ឆិមទ្វារេន** តាមទ្វារខាងលិច , **ឯកោ ថេរោ**

រីព្រះថេរៈមួយអង្គ **គណ្ហិ** កាន់យកហើយ **មគ្គំ** នូវផ្លូវ **បុរត្ថិមទ្វារេន** តាមទ្វារខាងកើត ។

ឧ.ទី ៣

**ឯវំ ខាទន្តា បញ្ចសុ អត្តភាវសតេសុ អញ្ញមញ្ញស្ស ទុក្ខំ ឧប្បាទេត្វា អវសានេ ឯកា យក្ខិនី ហុត្វា និព្វត្តិ ឯកា សាវត្ថិយំ កុលធីតា ហុត្វា និព្វត្តិ** ( ធម្ម. កក្កុដណ្ឌខាទិកាវត្ថុ ៧/ ១៥០ ) ។ រីស្ត្រីទ.ពីរនាក់នោះ ញុំាំងទុក្ខឱ្យកើតដល់គ្នានិងគ្នា ក្នុងរយៈនៃអត្តភាពទ. ៥ ( ៥00 អត្តភាព) យ៉ាងនេះ , ក្នុងទីបំផុត រីស្ត្រីម្នាក់ កើតជាយក្ខិនី , ស្ត្រីម្នាក់ទៀត កើតជាកុលធីតា ក្នុងក្រុងសាវត្ថី ។ ក្នុងឧ.នេះ **ឥត្ថិយោ** ជាហេតុកត្តាក្នុង **ឧប្បាទេត្វា** , ព្រោះជា ហេតុកត្តុវាចក ។

គ. ញែក-រួម ក្នុងសេចក្ដីច្រើនចំណែក ៖ ចំណែកដើមពោលញែក ចំណែកក្រោយពោលរួមត្រូវគ្នានឹង ក-ខ ដាក់កិរិយា ត្វា បច្ច័យក្នុងចំណែកញែក ឧ. ៖

**ឯវំ សត្ថារា ទេសិតាសុ ឥមាសុ គាថាសុ ឯកមេកិស្សា គាថាយ បរិយោសានេ ឯកមេកំ ភិក្ខុសតំ និសិន្ននិសិន្នដ្ឋានេយេវ សហ បដិសម្ភិទាហិ អរហត្តំ បត្វា វេហាសំ អព្ភុគ្គន្ត្វា សព្វេបិ តេ ភិក្ខូ អាកាសេនេវ វិសយោជ-**

**នសតិកំ កន្តារំ អតិក្កមិត្វា តថាគតស្ស សុវណ្ណវណ្ណំ សរីរំ វណ្ណេន្តា បាទេ វន្ទឹសុ ។** ប្រែ នាកាលគាថាទ. ដែលព្រះសាស្តា ទ្រង់សំដែងហើយ យ៉ាងនេះ វិរយនៃភិក្ខុទ. នីមួយ១ បន្ទុះហើយ នូវព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទ.ក្នុងទីជាទីគង់១ នោះឯង ហោះហើយឡើងកាន់អកាស , វិភិក្ខុទ.នោះ សូម្បីទាំងអស់ កន្លងហើយ នូវកន្តារៈដែលមានរយនៃយោជន៏ម្ភៃ(១២០យោជន៏)តាមអកាសមែនពិត កាលសរសើរនូវសរីរៈដែលមានពណ៌ដូចជាពណ៌នៃមាស ថ្វាយបង្គំហើយ នូវបាទាទ. ។

រួមសេចក្តីថា ក្នុងសេចក្តីច្រើនចំណែក ដែលពោលរួមហើយ ញែកឬញែកហើយរួមដាក់កិរិយាបធានន័យទុកក្នុងចំណែកដើមខ្លះ ក្នុងចំណែកក្រោយខ្លះ ក្នុងចំណែកដែលពោលរួមខ្លះ ក្នុងចំណែកដែលពោលញែកខ្លះ តែក្នុងទីបំផុតក៏ដាក់កិរិយាក្នុងពាក្យស្មើគ្នា ។

(៤)គប្បីសង្កេតប្រយោគប្លែក១តាមឧទាហរណ៏ដូចតទៅនេះ ៖

រូបប្រយោគ ទី ១

**តេបិ ទេវលោកតោ ចវិត្វា ពន្ធុមតិយំ ឯកស្មឹ កុលគេហេ ជេដ្ឋោ ជេដ្ឋោ វ ហុត្វា កនិដ្ឋោ កនិដ្ឋោ វ ហុត្វា បដិសន្ធឹ គណ្ហឹសុ ។** វិកុដុម្ពិក៏បងប្អូនសូម្បីនោះ ច្យុត

ហើយ អំពីទេវលោក បងកាន់បដិសន្ធិជាបងនោះឯង ប្អូនកាន់បដិសន្ធិជាប្អូននោះឯង ក្នុងផ្ទះនៃត្រកូលមួយ ក្នុងពន្ធុមតីនគរ ។

ឧ.នេះគួរឃើញថា រមែងមកពី **តេបិ ទេវលោកតោ ចវិត្វា ពន្ធុមតិយំ ឯកស្មឹ កុលគេហេ ជេដ្ឋោ ជេដ្ឋោ វ ហុត្វា បដិសន្ធឹ គណ្ហិ, កនិដ្ឋោ កនិដ្ឋោ វ ហុត្វា បដិសន្ធឹ គណ្ហិ** (ធម្ម. ជោតិកត្ថេរ.៨/២៣១) ។ ដើម្បីមិនឱ្យរៀង **បដិសន្ធឹ គណ្ហិ** ពីរដង ទើបប្រើ **គណ្ហឹសុ** តែម្តង ។ កាលមើលរូបពេញដូច្នេះ ហើយក៏នឹងឃើញច្បាស់ថា **ចវិត្វា** ជាកិរិយាបធានន័យ ចូលក្នុង ប្រភេទ រួម-ញែក (ពួក ខ) ដែលពោលមកហើយ ។ ឯ **ជេដ្ឋោ** (បទដើម ) និង **កនិដ្ឋោ** (បទដើម) ជាកត្តា ក្នុង **គណ្ហឹសុ** ដូចយ៉ាងកត្តាឯកវចនៈតាំងតែ ២ បទឡើងទៅ ប្រើកិរិយារួមគ្នាជាពហុវចនៈ ។

ឧ.ទី ២

**តេ... ថេរំ ខមាបេត្វា ចោរជេដ្ឋកេន អហំ អយ្យស្ស សន្តិកេ បព្វជិស្សាមីតិ វុត្តេ សេសា មយំបិ បព្វជិស្សាមាតិ វត្វា សព្វេ វ ឯកច្ឆន្ទា ហុត្វា ថេរំ បព្វជ្ជំ យាចឹសុ ។** (ធម្ម.ខានុកោណ្ឌញ្ញត្ថេរ.៤/២០០) វីចោរទាំងនេះ ញុំាងព្រះថេរៈឱ្យអត់ទោសឱ្យហើយ នាកាលចោរជាប្រធានពោលថា ខ្ញុំនឹងបួសក្នុង

សំណាក់លោកម្ចាស់ , ចោរទ.ដ៏សេស ពោលថា សូម្បីរីយើងទ. នឹងបួសដែរ ,រីចោរទាំងអស់នោះឯង ជាអ្នកមានឆន្ទៈតែមួយ សូមនូវបព្វជ្ជានឹងព្រះថេរៈហើយ ។

**សេសា មយំបិ បព្វជិស្សាមាតិ វត្វា** ដូចជាប្រយោគជ្រែកហៅសម្ពន្ធថា **(សេសា) ចោរា** សយកត្តា ក្នុង **វត្វា** ៗ កិរិយាបធាន-ន័យ , ចំណែក **ខមាបេត្វា** បុព្វកាលកិរិយាក្នុង **យាចឹសុ** ។

ប្រយោគកិរិយាបធានន័យនេះ មានសេចក្តីពោលញែកជ្រែកចូលមកក្នុងរវាងដែលពោលរួម ។

ឧ.ទី ៣

**គាមវាសិនោ តស្សា នយេ ឋត្វា ឯកេកោ ឯកេកំ កត្វា សទ្ធឹ រត្តិដ្ឋានទិវាឋានេហិ បណ្ណសាលាសហស្សំ ការេត្វា ... ឧបដ្ឋហឹសុ** (ធម្ម. មហាកប្បិនត្ថេរ.៤/១៤-១៥) ។ រីអ្នកស្រុក ទ.តាំងនៅហើយ ក្នុងន័យរបស់នាង មនុស្សម្នាក់ៗ ធ្វើកន្លែងមួយៗ ហើយឱ្យធ្វើបណ្ណសាលាមួយពាន់ មួយអន្លើ ដោយទីសម្រាក់កណ្តាលយប់និងទីសម្រាក់កណ្តាថ្ងៃ ទំនុកបំរុងហើយ ...។

ឧ.នេះ **ឯកេកោ ឯកេកំ កត្វា** ប្រហែលជ្រែកចូលមកដូចឧ.ទី ២ តែផ្សេងគ្នា ព្រោះ **ឯកេកោ** ពោលដល់ "តែមួយនាក់ៗ" របស់មនុស្សទាំងអស់ មិនដូច សេសា (ចោរា) ហេតុដូច្នេះ កត្វា ទើបជា

កិរិយារបស់មនុស្សគ្រប់រូប, មិនដូច វត្វា ដែលជាកិរិយារបស់ សេសា ចោរា ប៉ុណ្ណោះ មិនរួមទាំងប្រធានចោរផង ។ លោកប្រាប់ថា ឯកេ-កោ ជាវិកតិកត្តា ក្នុង ហុត្វា ,កត្វា ជាសមានកាលកិរិយាក្នុង ការេត្វា។

ឧ.ទី ៤ ខ.**ទារកា មយំ ឥទានិ គហេតុំ ន សក្ខិស្សាម ស្វេ អាគន្ត្វា គណ្ហិស្សាមាតិ ឯកេកោ ឯកេកំ សាខាភង្គ-មុដ្ឋិមាទាយ សត្តបិ ជនា សត្ត ឆិន្នានិ បិទហិត្វា បក្កមឹសុ** (ធម្ម. តយោជនវត្ថុ ៥/៦១-៦២) ។ វីក្មេងប្រុសទ. គិតថា ក្នុងកាលឥឡូវនេះយើងទ. មិនអាចចាប់បានទេ ក្នុងថ្ងៃស្អែកយើងទ. មកហើយនឹងចាប់យក , ក្មេងប្រុសម្នាក់ៗ កាន់យកនូវមែកឈើបាក់មួយកំណាត់ៗវីជនសូម្បីទាំង ៧ នាក់បិទនូវប្រហោងទ. ៧ ហើយចៀសចេញទៅ ។

ឯកេកោ វិកតិកត្តា ក្នុង ហុត្វា...អាទាយ បុព្វកាលកិរិយាក្នុង បិទហិត្វា ...(ជនា វិកតិកត្តា ក្នុង ហុត្វា សត្ត វិសេសនៈរបស់ ជនា ។

[៥] ក្នុងទីបំផុតសេចក្ដីដែលមិនត្រូវដោយលក្ខណៈដូចពោលហើយ ដាក់កិរិយា ត្វា បច្ច័យ ទុកក៏មាន ឧ. ៖

ឧ.ទី ១

**ឯកំ កិរ ពុទ្ធន្តរំ អវីចិនិរយេ បចិត្វា តតោ ចុតា សញ្ជីវឃោជនិកាយ លោហកុម្ភិយា និព្វត្តិត្វា តត្ថ សញ្ជីវស្ស-សហស្សានិ បចិត្វា ឯវំបិ តេសំ ទុក្ខា មុច្ចនកាលោ ន**

**បញ្ញាយតិ អហម្បិ... និទ្ទំ ន លភិ** (ធម្ម. អញ្ញតរបុរិស. ៣/១៨៣)។ បានឮថា វីប្រេតទាំងនោះ ឆេះហើយ ក្នុងអវិចីនរក អស់ពុទ្ធន្តរ ១ ច្យុតពីអវិចីនរកនោះ ហើយកើតក្នុងលោហកុម្ភីនរក ប្រកបដោយ យោជន៍ ៦០ ឆេះក្នុងលោហកុម្ភីនរកនោះ អស់ ៦0000 ឆ្នាំ សូម្បី យ៉ាងនេះ វីកាលរួចផុត អំពីទុក្ខរបស់សត្វប្រេតទ.នោះ តែងមិនប្រាកដ សូម្បីវីយើង...មិនបាននូវការលក់ ។

ឧ.ទី ២

**រាជា កិន្នុ ខោ ឯតន្តិ ចិន្តេត្វា ភន្តេ ឥតោ តាវ និក្ខមាថាតិ វត្វា ថេរេ តតោ និក្ខមិត្វា បមុខេ ឋិតេ បុន សា ថេរស្ស បិដ្ឋិបស្សេ អដ្ឋាសិ** (ធម្ម.កោណ្ឌធានត្ថេរវត្ថុ ៥/៧៩)។ វីព្រះរាជាទ្រង់គិតហើយយ៉ាងនេះថា វីហេតុនេះ យ៉ាងណាហ្ន៎ ត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តចេញអំពីទីនេះសិន នាកាលព្រះថេរៈចេញអំពីទីនោះ ស្ថិតនៅក្នុងទីចំពោះមុខ វីស្រីនោះឈរនៅខាងក្រោយព្រះថេរៈទៀត ។

[ ៦ ] កិរិយាបធានន័យនេះ អ្នកខ្លះឃើញថា លោកទុកដោយសេចក្តីភ្លាំងភ្លាត់ តែការពិចារណាមើល ក៏នឹងឃើញបានថា មិនមែនដោយភ្លាំងភ្លាត់ទេ លោករៀងដោយមានគោលកេណ្ឌយ៉ាងច្បាស់លាស់

ដូចពោលហើយអំពីការសង្កេត វៀរតែកន្លែងខ្លះដូចដែលលើកមកជាតួយ៉ាងក្នុងខ [ ៥ ] ។

ម្យ៉ាងទៀត ក្នុងសេចក្ដីដែលពោលរួមៗញែកៗ ដែលគួរដាក់កិរិយា ត្វា បច្ច័យក្នុងទីបំផុត លោកដាក់កិរិយាដទៃក៏មាន ឧ. ៖

**តា គេហេ ឈាយន្តេ វេទនាបរិគ្គហកម្មដ្ឋានំ មន-សិករោន្តិយោ កាចិ ទុតិយផលំ កាចិ តតិយផលំ បាបុ-ណឹសុ** ( ធម្ម.សាមាវតីវត្ថុ ២/១០២) ។ នាកាលផ្ទះ ដែលភ្លើងកំពុងឆេះ ស្រ្តីទ.នោះ ធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋានកំណត់វេទនាជាអារម្មណ៍ ស្រ្តីពួកខ្លះ បានសម្រេចនូវផលទី ២ , ស្រ្តីពួកខ្លះបានសម្រេចនូវផលទី ៣ ។

**មនសិករោន្តិយោ** គួរហៅថា កិរិយាបធានន័យ តែកាលមិនហ៊ានហៅ ក៏ត្រូវហៅថា វិសេសនៈ ,( កាលហៅអព្ភន្តរកិរិយាក៏ជំទាស់ ព្រោះមិនមែនជាកិរិយាខាងក្នុង គឺក្នុងរវាងៗ តែជាកិរិយាក្នុងទីបំផុត ) បើនឹងឱ្យជាកិរិយាបធានន័យក៏ត្រូវបន្ថែម ហុត្វា ឱ្យ ករោន្តិយាជាវិកតិ-កត្តា ក្នុង ហុត្វា ៗ កិរិយាបធានន័យ ( បទកិរិយា អន្ត មាន បច្ច័យជាវិកតិកត្តា បាន ) តែពិនិត្យមើលមិនគួរបន្ថែម ព្រោះលោកដាក់ទុកល្មមល្អហើយ ។

សរុបអធិប្បាយ កិរិយាបធានន័យ គឺកិរិយា ត្វា បច្ច័យដែលដាក់ទុកក្នុងទីបំផុតសេចក្ដី ដែលពោលរួមខ្លះ ពោលញែកខ្លះ ក៏សេចក្ដីច្រើនចំណែកដែលពោលរួម ៗ ញែក១ នឹងដាក់ទុកក្នុងចំណែកដើមខ្លះ ចំណែកក្រោយខ្លះមិនប្រាកដ , តែទីបំផុតមានកិរិយាក្នុងពាក្យស្មើ ។ បទកត្តា ហៅថា កត្តា ខ្លះ សយកត្តា ខ្លះ ហេតុកត្តា ខ្លះ តាមគួរដល់ការប្រកប ។ សូមអ្នកសិក្សាពិចារណានូវប្រយោគកិរិយា-បធានន័យនេះឱ្យបានច្បាស់លាស់ ហើយសសង្កេតពិនិត្យឱ្យបានល្អចងចាំថា **នេះជាប្រយោគកិរិយាបធានន័យ** ។

**ចប់កិរិយាបធានន័យ**

**ដោយសង្ខេប**

# ប្រយោគវិកតិកត្តា

វិកតិកត្តានេះ ជាពាក្យសម្រាប់ហៅ គុណនាម ឬនាមនាម ដែលយកមកប្រើដូចជា គុណនាម , ដែលចូលនឹងកិរិយាថា "កើត" ថា "មាន" ថា "ជា" គឺ ភូ ហុ អស ជន ធាតុ តែវេលាប្រែត្រូវយកទៅដាក់ខាងចុងគុណនាម ឬនាមនាម ហើយមិនចេញពាក្យថា កើត មាន ជា ទៀតទេ បើជាប់ទាក់ទងដោយមនុស្ស ត្រូវប្រើពាក្យសម្រួលថា "ជា" "ជាអ្នក" បើស្រីថា "ជាស្រី" បើជានបុំសកលិង្គច្រើនប្រើពាក្យអែបសម្រួលថា "ជារបស់" ថា "ជាវត្ថុ" ឬ "ជាធម្ម-ជាត" ជាដើម, បុំលិង្គ "ជាសភាព" "ជាសភាវៈ" "ជាអាការៈ" ជាដើម ឥត្ថីលិង្គ "ជាធម្មជាតិ" "ជាសទ្ទជាតិ" ជាដើម តាមសមគួរដល់សេចក្តី, គុណនាមនេះផ្សេងពីវិសេសនៈ ព្រោះថា វិសេសនៈ លោករៀងទុកខាងដើម នាមនាម, ឯគុណនាមបទនេះ លោករៀងទុកខាងចុងនាមនាមវិញ វៀរលែងតែមានតួវិកតិកត្តាច្រើនតួ តាំពីពីរតួឡើងទៅលោកច្រើនតែរៀងទុកខាងដើមកិរិយាមួយបទ (មានកិរិយារៀងទុកខាងដើមគុណនាមក៏មាន តែមានតិចតួចមិនច្រើនទេ វិកតិកត្តាក្រៅពីនោះ លោករៀងទុកខាងចុងកិរិយា ដែលប្រកបដោយ ភូ ហុ អស ជន ធាតុ ដោយច្រើន ដូចឧ.ថា **មហាសុវណ្ណោ នាម កុដុម្ពិកោ**

**អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ** (ធម្ម.ចក្ខុបាល.១/៣) ។ នៅក្នុងប្រយោគនេះមានវិកតិកត្តាច្រើនតួ ព្រោះហេតុនោះ ព្រះគន្ថរចនាចារ្យទើបដាក់វិកតិកត្តាមួយនៅខាងដើម **ហុ** ធាតុ ដែលសម្រេចរូប មកជា **អហោសិ** វិកតិកត្តាក្រៅពីនោះនៅខាងចុងទាំងអស់ ។ ម្យ៉ាងទៀត បើសិនជាយក **កុដុម្ពិកោ** ជាប្រធាននោះ វាមិនសមទំនងនឹង បាលីខាងក្រោមនៅត្រង់ទំព័រទី ៤ ថា **សេដ្ឋី...អកាសិ** នៅទីនេះយក **សេដ្ឋី**ជាប្រធានមិនមែនយក កុដុម្ពិកោ ជាប្រធានទេ រហូតដល់លោកអាចារ្យខ្លះមិនបានត្រួតពិនិត្យមើលឱ្យបានច្បាស់លាស់ ស្រាប់តែប្រែ **កុដុម្ពិកោ** ថា វីកុដុម្ពីក៏ ។ តែសូមជ្រាបថា តាមច្បាប់វេយ្យាករណ៍ លោក បានបញ្ជាក់ថា របៀបនេះជាប្រយោគវិកតិកត្តា ។ នៅក្នុងប្រយោគធម្មតា បទប្រធានដែលប្រែថា "វី" សម្ពន្ធថា សយកត្តា លុះមកក្នុងប្រយោគវិកតិកត្តា ត្រឡប់ឱ្យសម្ពន្ធថា បកតិកត្តា វិញ ។ សូមបញ្ជាក់ផងដែរថា ប្រយោគវិកតិកត្តានេះមានប្រើច្រើនក្នុងគម្ពីរ ចាប់តាំងពីធម្មបទដ្ឋកថាឡើងទៅស្ទើរគ្រប់សន្លឹកហេតុដូច្នោះ សូមអ្នកសិក្សាព្យាយាម រៀនឱ្យបានចេះស្ទាត់ដើម្បីឈានចូលទៅប្រែគម្ពីរទាំងនោះ ងាយស្រួលមិនលំបាកស្មុគស្មាញ ។ សង្កេតមើលវិកតិកត្តារៀងកិរិយាទុកទី ២ ។

ឧ.ទី ១

**មហាសុវណ្ណោ នាម កុដុម្ពិកោ អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ** ( ធម្ម. ចក្ខុបាល. ១/៣) ។ ប្រែ. **សេដ្ឋី** វិសេដ្ឋី **មហាសុវណ្ណោ នាម** ឈ្មោះ មហាសុវណ្ណ **កុដុម្ពិកោ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ អហោសិ** ជាអ្នកមានសម្បត្តិ ជាអ្នកស្តុកស្តម្ភ ជាអ្នកមានទ្រព្យច្រើន ជាអ្នកមានភោគៈច្រើន ជាអ្នកមិនមានកូន ។ សម្ពន្ធ **នាម** ស័ព្ទ សញ្ញាជោតកៈ,**មហាសុវណ្ណោ** សញ្ញាវិសេសនៈរបស់**សេដ្ឋី** ៗ សញ្ញិវិ-សេសយៈនិងជាបកតិកត្តាក្នុង **អហោសិ** ៗ អាខ្យាតបទ កត្តុវាចក , **កុដុម្ពិកោ** ក្តី **អឌ្ឍោ** ក្តី **មហទ្ធនោ** ក្តី **មហាភោគោ** ក្តី **អបុត្តកោ** ក្តី វិកតិកត្តាក្នុង **អហោសិ** ។

ឧ.ទី ២

**ឯកស្មឹ ហិ សមយេ វេសាលី ឥទ្ធា អហោសិ ផីតា ពហុជនា អកិណ្ណមនុស្សា** ( ធម្ម. អត្តនោ បុព្វកម្ម. ៧/១៣១) ។ ប្រែ. **ហិ** សេចក្តីពិស្តារថា **សមយេ** ក្នុងសម័យ **ឯកស្មឹ** មួយ **វេសាលី** វិក្រុងវេសាលី **ឥទ្ធា ផីតា ពហុជនា អកិណ្ណមនុស្សា អហោសិ** ជាក្រុងមាំទាំ ធំទូលាយ មានមនុស្សច្រើន មនុស្សកុះករ ។

សង្កេតបទវិកតិកត្តាតាំងពីពីរបទឡើងទៅ រៀងកិរិយាទុកមុខបំផុតក៏មាន ឧ. ៖

**តស្សេវកបុត្តកោ អហោសិ បិយោ មនាបោ** ( ធម្ម. មដ្ឋកុណ្ឌលិវត្ថុ ១/៣៥ ) ។ **ឯកបុត្តកោ** វិកូនតែមួយ **បិយោ មនាបោ អហោសិ** ជាទីស្រលាញ់ ជាទីពេញចិត្ត **តស្ស ព្រាហ្មណស្ស** នៃព្រាហ្មណ៍នោះ ។

**សេដ្ឋិនោ បនេកា ធីតា អត្ថិ បណ្ណរសសោឡស-វស្សុទ្ទេសិកា អភិរូបា បាសាទិកា** ( ធម្ម. សាមាវតី . ២/៤០ ) ។ ប្រែ. **បន** ក៏ **ធីតា** វិធីតា **ឯកា** ម្នាក់ **សេដ្ឋិនោ** របស់សេដ្ឋី **បណ្ណរ-សសោឡសវស្សុទ្ទេសិកា អភិរូបា បាសាទិកា អត្ថិ** ជាអ្នកមានអាយុរាប់បាន ១៥-១៦ ឆ្នាំ ជាអ្នកមានរូបស្អាត គួរជាទីស្រលាញ់ ។ សូមចំណាំថា ដោយច្រើនលោករៀង ភូ ហុ អស ជន ធាតុទុកនៅខាងក្រោយ ចំណែកឧទាហរណ៍ខាងលើមានមួយ ៗ ប៉ុណ្ណោះ ។

លោករៀង ភូ ហុ អស ជន ធាតុនៅខាងក្រោយ ដូចជា ៖

ទី ១ **អយំ មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** ( ធម្ម. ចក្ខុបាល. ១/៣ ) ។ ប្រែ **អយំ វនប្បតិ** វិដើមឈើជាម្ចាស់នៃព្រៃនេះ **មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** ជាដើមឈើ គឺទេវតាមានស័ក្តិដ៏ធំ ហួងហែងរក្សាហើយ ។ សម្ពន្ធ

**អយំ** វិសេសនៈរបស់ **វនប្បតិ** ៗ បកតិកត្តាក្នុង **ភវិស្សតិ** ៗ អាខ្យាតបទ កត្តុវាចក , **មហេសក្ខាយ** វិសេសនៈរបស់ **ទេវតាយ ៗ** អនភិហិកត្តា ក្នុង **បរិគ្គហិតោ** ៗ វិកតិកត្តាក្នុង **ភវិស្សតិ** ។

ទី ២ **សត្ថា ចូឡបន្ថកស្ស អវស្សយោ ជាតោ** (ធម្ម. ២/១៤៩) ។ ប្រែ. **សត្ថា** រីព្រះសាស្ដា **អវស្សយោ ជាតោ** ជាទីពឹង **ចូឡបន្ថកស្ស** នៃចូឡបន្ថក ។

ម្យ៉ាងទៀត សូមអ្នកសិក្សាចាំថា ក្នុងប្រយោគកត្តុវាចក បទវិកតិកត្តា ប្រកបដោយបឋមាវិភត្តិ ចំណែកក្នុងប្រយោគកម្មវាចកនិងភាវវាចក ប្រកបដោយតតិយាវិភត្តិ គប្បីជ្រាបឧ.ដូចតទៅនេះ ៖

ទី ១ **ពហុស្សុតោ ហោតិ** ជាអ្នកមានសុតៈច្រើន ។

ទី ២ **កុសីតេន ន ភវិតព្វំ អារទ្ធវីរិយេន** (ធម្ម. ចុល្លកាឡ. ១/៩៩) ។ ប្រែ. **អយ្យេន** គឺលោកម្ចាស់ **ន កុសីតេន ភវិតព្វំ** ជាអ្នកមិនខ្ជិលច្រអូស **អារទ្ធវីរិយេន ភវិតព្វំ** ជាអ្នកមានព្យាយាមប្រារព្ធហើយ ។ **កុសីតេន** ក្តី **អារទ្ធវីរិយេន** ក្តី ជាវិកតិកត្តាក្នុង **ភវិតព្វំ** ។

ប្រយោគវិកតិកត្តានេះមានប្រើច្រើនក្នុងគម្ពីរទាំងឡាយខ្ញុំលើកយកឧទាហរណ៍ខ្លះ ៗ មកដាក់ក្នុងទីនេះអាចល្មមជាជំនួយដល់ការសិក្សា

បាន  សូមអ្នកសិក្សាត្រួតពិនិត្យឱ្យច្បាស់លាស់ហើយចងចាំទុកនូវឧទាហរណ៏ដែលខ្ញុំបានលើកយកមកអធិប្បាយក្នុងសៀវភៅនេះ ហើយរៀនប្រែឱ្យបានចាំយ៉ាងល្អដើម្បីជាអ្នកស្ទាត់ជំនាញក្នុងប្រយោគ **ទិគតិគត្ថា** នេះឯង ។

**ចប់ប្រយោគទិគតិគត្ថា**

**ដោយសង្ខេប**

# កិមង្គំ បន

ស័ព្ទនេះជាស័ព្ទពិសេស ចុះដើមសេចក្តីចំណែកក្រោយ ដែលបញ្ច្រាសចំណែកដើម ពោលសួរសេចក្តីចំណែកក្រោយនោះ ឱ្យត្រឡប់តាមសេចក្តីចំណែកដើម, **កិមង្គំ** (ប្រែថា មានអ្វីជាហេតុ) ហៅឈ្មោះថា កិរិយាវិសេសនៈ ឬ (ប្រែថា ព្រោះហេតុអ្វី) ហៅឈ្មោះថាហេតុ បើប្រែថា ចាំបាច់ពោលទៅថ្វី ដែលប្រែយ៉ាងនេះ ហៅថា លិង្គត្ថៈ ។ **បន** (ក៏) ហៅឈ្មោះថា បុច្ឆនត្ថៈ, ក្នុងសេចក្តីចំណែកក្រោយ លោកមិនរៀងកិរិយាទុក គប្បីប្រកបឱ្យមានធាតុដូចគ្នាក្នុងចំណែកដើមដោយភវិស្សន្តិ វិភត្តិ, បើក្នុងចំណែកដើមមានបដិសេធ ក៏ត្រូវមិនមានបដិសេធ, បើក្នុងចំណែកដើមមិនមានបដិសេធ ក៏ត្រូវមានបដិសេធ ឧ. **តាត មហល្លកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ ន វសេ វត្តន្តិ កិមង្គំ បន ញាតកា** ។ ប្រកបសេចក្តីចំណែកក្រោយឱ្យពេញថា **កិមង្គំ បន ញាតកា អស្សវា ភវិស្សន្តិ វសេ វត្តិស្សន្តិ ។**

អធិប្បាយ **កិមង្គំ បន** ដោយប្រក្រតីប្រើជាគូនឹងគ្នា មានអត្ថនិងរូបប្រយោគដូចសំដែងមកហើយ ឧ. ៖

ឧ.១ **តាត មហល្លកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ ន វសេ វត្តន្តិ កិមង្គំ បន ញាតកា** ( ធម្ម. ចក្ខុបាល. ១/៩ ។ ប្រែ **តាត** ម្នាលប្អូនសម្លាញ់ **ហិ** ក៏ឯ **ហត្ថបាទាបិ** វិសូម្បីដៃនិងជើងទ. **អត្តនោ** របស់ខ្លួន **មហល្លកស្ស** នៃមនុស្សចាស់ **អនស្សវា ហោន្តិ** ជាអវយវៈមិនស្តាប់បង្គាប់ **ន វត្តន្តិ** មិនប្រព្រឹត្តទៅ **វសេ** ក្នុងអំណាច **កិមង្គំ បន** ក៏រីបាច់ពោលទៅថ្វី **ញាតកា** វិញាតទ. **អស្សវា ភវិស្សន្តិ** នឹងជាញាតិស្តាប់បង្គាប់ **វត្តិស្សន្តិ** នឹងប្រព្រឹត្តទៅ **វសេ** ក្នុងអំណាច ។ **កិមង្គំ បន** ប្រែថា វីបាច់ពោលទៅថ្វី សម្ពន្ធថា លិង្គត្ថៈ ។ តែបើប្រែថា **ញាតកា** វិញាតិទ. **អស្សវា ភវិស្សន្តិ** នឹងជាញាតិស្តាប់បង្គាប់ **វត្តិស្សន្តិ** នឹងប្រព្រឹត្តទៅ **វសេ** ក្នុងអំណាច **កិមង្គំ បន** មានអ្វីជាហេតុ សម្ពន្ធថា កិរិយា-វិសេសនៈក្នុង **ភវិស្សន្តិ** ,និង **វត្តិស្សន្តិ** ។

ឧ.ទី ២ **អយ្យោ ហិ ភវេសី សីលេសុ បរិបូរិការី ភវិស្សតិ កិមង្គំ បន មយំ** ( អង្គុត្តរនិកាយ បញ្ចក.៤៥/១៧៥ ) ។ **ហិ** ក៏ **ភវេសី** វិភវេសីឧបាសក **អយ្យោ នាម** ឈ្មោះថាជាម្ចាស់ **សីលេសុ បរិបូរិការី ភវិស្សតិ** ជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទ. **បន** ក៏ **មយំ** វីយើងទ. **សីលេសុ បរិបូរិការិនោ ន ភវិស្សាម** នឹងជាអ្នកមិនធ្វើឱ្យបរិបូណ៌ក្នុងសីលទ. **កិមង្គំ** ព្រោះហេតុអ្វី ។

នៅក្នុងគម្ពីរអដ្ឋកថា មនោរថបូរណីខែថា **កិមង្គំ បន មយន្តិ មយំ បន កេនេវការណេន បរិបូរិការិនោ ន ភវិស្សាម** ។ កិមង្គំ ក្នុងទីនេះ សម្ពន្ធថា **ហេតុ** ក្នុង **ន ភវិស្សាម** ។

សូមអ្នកសិក្សាសាកប្រែប្រយោគនេះមើល ហើយប្រៀបធៀបគ្នានឹងប្រយោគខាងដើមនេះ គឺ **អយ្យោ ហិ នាម ភវេសី ព្រហ្មចារី ភវិស្សតិ អាចារី វិរតោ មេថុនា គាមធម្មា កិមង្គំ បន មយំ** (អង្គុត្ត. បញ្ចក. ៤៥/១៧៦-១៧៧) ។

ឧ.ទី ៣

**ខណ្ឌោ ច នាម រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ កេសមស្សុំ ឱហារាបេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សន្តិ កិមង្គំ បន ន មយំ** (សុត្តន្ត.មហាវគ្គ មហាបទានសូត្រ ១៦/៨៩) ។ រីព្រះរាជបុត្រព្រះនាមខណ្ឌៈនិងបុត្ររបស់បុរោហិតព្រះនាមតិស្សៈផង ដាក់សក់និងពុកមាត់ ស្លៀកសំពត់កាសាយៈ ចេញអំពីផ្ទះបួសជាអ្នកមិនមានផ្ទះ រីយើងទាំងឡាយ ជាអ្នកមិនដាក់សក់និងពុកមាត់...ជាអ្នកមិនបួស ព្រោះហេតុអ្វី ។

ឧ.ទី ៤

**កិមង្គំ បន មយ្ហំ ឧបរិ ន បតិស្សតិ** ( វិសុទ្ធិមគ្គ អនុស្សតិកម្មដ្ឋាននិទ្ទេស ២/៤៥០) ។ ក៏រីបាច់ពោលទៅថ្វី ( ថា) មរណៈនឹងមិនធ្លាក់មក ឰដ៏ខាងលើអញ ។

**កិមង្គំ បន អរូបធម្មេសុ** (វិសុទ្ធិមគ្គ-មហាដីកា ខន្ធនិទ្ទេស ២/៨៤) ។ រីបាច់ពោលទៅថ្វី ក្នុងអរូបធម៌ទាំងឡាយ ។

**កិមង្គំ បន ចិត្តចេតសិកានំ** (វិភង្គ មូលដីកា-អនុដីកា ) ។ រីបាច់ពោលទៅថ្វី ដល់ចិត្តនិងចេតសិកទាំងឡាយ ។

**កិមង្គំ** នេះនៅក្នុងគម្ពីរធម្មបទមហាដីកា ទំព័រ ១១ ថែថា **កិមង្គន្តិ បគេវ , បាចេវ , កោ បន វាទោ , កិមេវ វត្តព្វន្តិ** ។ **កិមង្គំ** នេះស្មើនឹង **បគេវ , បាចេវ , កោ បន វាទោ , កិមេវ វត្តព្វំ** ។

## កោ បន វាទោ

ប្រយោគទី ១

**អច្ឆរាសង្ឃាតម្បិ ច ភិក្ខវេ ភិក្ខុ មេត្តចិត្តំ ភាវេតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ**

**ឱវាទបដិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ កោ បន វាទោ យេ នំ ពហុលីករោន្តិ** ( អង្គុត្ត.ឯក.៤០/៩៤ ) ។ ម្នាលភិក្ខុទ. បើវីភិក្ខុចម្រើននូវមេត្តចិត្ត សូម្បីត្រឹមមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទ. វីភិក្ខុនេះតថាគតហៅថា ជាអ្នកមិនឆ្ងាយអំពីឈាន ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ជាអ្នកធ្វើតាមឱវាទ វីភិក្ខុនោះ រមែងបរិភោគនូវដុំបាយរបស់ដែន( អ្នកស្រុក ) មិនទទេ វីបាច់ពោលទៅថ្វី វីភិក្ខុទ.ឯណា ធ្វើនូវមេត្តចិត្តនោះឱ្យច្រើន ។

នៅក្នុងអដ្ឋកថា មនោរថបូរណី អច្ឆរាសង្ឃាតវគ្គ ខែថា ៖

**កោ បន វាទោ ... វត្តព្វមេវ កឹ ។** ឱ្យប្រែថា វីបាច់ពោលថាម៉េចទៅ ។

នៅក្នុងគម្ពីរអង្គុតរដីកា ឈ្មោះ សារត្ថមញ្ជូសា ខែថា ៖

**កោ បន វាទោ... ពហុលីការេ ឯត្ថ វត្តព្វមេវ នត្ថិ ។** ( វីពាក្យដែលត្រូវពោលមិនមាន ) ។

នៅក្នុងអដ្ឋកថា អង្គុត្តរ. បញ្ចក. មច្ឆពន្ធសូត្រ សារាណីយវគ្គ ថា **កិមេវ វត្តព្វំ** ។

សូមអ្នកសិក្សាសាកល្បងរៀនប្រែប្រយោគទាំងនេះ ដោយខ្លួនឯងលមើល ដូចតទៅ ៖

ឧ.ទី ១

**-បរិនិព្វុតម្បិ ច ភគវន្តំ ឧទ្ទិស្ស ឆន្នវុតិកោដិធនំ វិសជ្ជេត្វា អសោកមហារាជា សកលជម្ពុទីបេ ចតុរាសីតិវិហា-រសហស្សានិ បតិដ្ឋាបេសិ កោ បន វាទោ អញ្ញេសំ បូជាវិ-សេសានន្តិ បច្ចយាទីនំ អរហត្តាបិ អរហំ** (សមន្ត.១/២០២ វិសុទ្ធិមគ្គ ១/៣៩០) ។

នៅក្នុងគម្ពីរសារត្ថទីបនីដីកា ១/២៨០ ខែថា៖

**កោ បន វាទោ អញ្ញេសំ បូជាវិសេសនន្តិ យថាវុត្តោ អញ្ញេសំ អមហេសក្ខេហិ ទេវមនុស្សេហិ ករិយាមានំ នាតិឧ-ឡារំ បូជាវិសេសានំ អរហភាវេ កា នាម កថា ។**

ទី ២

**-សចេបិ មញ្ចប្បមាណោ ភិសិច្ឆវិ ហោតិ វដ្ដតិយេវ ។ កោ បន វាទោ បត្តត្ថវិកាទីសុ** (សមន្ត. តីសកកណ្ឌវណ្ណនា មហាវិភង្គ ៣/២៩៤-២៩៥) ។

នៅក្នុងគម្ពីរវិមតិវិនោទនីដីកា ១/៤១៨ ខែថា៖

**កោ បន វាទោ បត្តត្ថកាវិទីស្វតិ មហតិយាបិ តាវ ភិសិច្ឆវិយា អនធិដ្ឋានុបគត្តា អនាបត្តិ , វិកប្បនុបគបច្ឆិមប្បមា-ណវិរហិតតាយ អនធិដ្ឋាតព្វេសុ កិមេវ វត្តព្វន្តិ ទស្សេតិ ។**

ទី ៣

**- តត្ថ ឯកទិវសមេវ បុនប្បុនំ គន្ត្វា ទ្វាទសក្ខត្តុំ តិដ្ឋតិ, សកិមេវ គន្ត្វា តត្រ តត្រ ឋានេ តិដ្ឋតិ , សោបិ សព្វចោទ- នាយោ សព្វដ្ឋានិ ច ភញ្ញតិ , កោ បន វាទោ នានាទិវសេសុ**

( វិនយសង្គហដ្ឋកថា ឈ្មោះ បាឡិមុត្តកវិនិច្ឆ័យ ទំព័រ ៧៣) ។

នៅក្នុងគម្ពីរវិនយាលង្ការដីកា ១/១១៧ ថែថា ៖

**កោ បន វាទោ នានាទិវសេសូតិ នានាទិវសេសុ ឯវំ ករោន្តស្ស កោ បន វាទោ , វត្តព្វមេវ នត្ថីតិ អធិប្បាយោ ។**

ទី ៤

**ឆត្តឹសក្ខត្តុំ ខោ បនាហំ ភិក្ខវេ សក្កោ អហោសឹ ទេវានមិន្ទោ , អនេកសតក្ខត្តុំ រាជា អហោសឹ ចក្កវត្តី ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ , កោ បន វាទោ បទេសរជ្ជស្ស**

( នេត្តិប្បករណ៍ ទំព័រ ១៨២ ) ។

នៅក្នុងគម្ពីរ នេត្តិវិភាវនីដីកា ទំព័រ ៤១៦ ថា៖

**ភិក្ខវេ អហំ ទេវានមិន្ទោ សក្កោ...អនេកសតក្ខត្តុំ អហោសឹ , បទេសរជ្ជស្ស រាជភាវេ កោ បន វាទោ ។**

ទី ៥

**កោ បន វាទោ តេភូមកធម្មានន្តិ ទស្សេតិ** (គម្ពីរនេត្តិអដ្ឋកថា ទំព័រ ៧៦) ។

ទី ៦

**សុខេវត្តេបីតិ បិ-សទ្ទេន កោ បន វាទោ ឧសភាទិទោស-ទុជ្ជេស ខេត្តេសូតិ ទស្សេតិ** (នេត្តិដីកា ទំព័រ ១៥៧) ។

ទី ៧

**សត្តហង្គេហិ សមន្នាគតា ខោ ភិក្ខុ អបិ ហិមវន្តំ បព្វតរាជានំ ចាលេយ្យ , កោ បន វាទោ ឆវំ អវិជ្ជំ សត្តកេសុ វេយ្យាករណំ កាតព្វំ** (ក្នុងគម្ពីរ បេដកោបទេសបករណ៏ ទំព័រ ២២៧) ។

ប្រយោគទី ២

**ឥមេសម្បិ ចន្ទិមសុរិយានំ ឯវំ មហិទ្ធិកានំ ឯវំ មហានុភាវានំ តេជសា តេជំ បរិយាទិយេយ្យាថ កោ បន វាទោ អញ្ញតិត្ថិយានំ បរិព្វាជកានំ** (អង្គុត្ត. ទសក.៥០/២៨២) ។

វិអ្នកទ.គ្របសង្កត់នូវតេជៈនៃព្រះច័ន្ទនិងព្រះអាទិត្យ ដែលមានអានុភាពច្រើនយ៉ាងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ សូម្បីនេះ ដោយតេជៈ វិបាច់ពោលទៅថ្វី ដល់បរិព្វាជកដែលជាអន្យតិរ្ថិយឡើយ ។

ប្រយោគទី ៣

**ចិត្តុប្បាទម្បិ ខោ អហំ ចុន្ទ កុសលេសុ ធម្មេសុ ពហុការំ វទាមិ កោ បន វាទោ កាយេន វាចាយ អនុវិធិយនាសុ** (មជ្ឈិម.មូលបណ្ណាសក មូលបរិយាយវគ្គ សល្លេខសូត្រ ២០/១៤០) ។ ម្នាលចុន្ទៈ រីតថាគតពោល សូម្បីការកើតឡើងនៃចិត្ត នោះឯង ក្នុងធមិទ.ដែលជាកុសល ថាមាន ឧបការៈច្រើន រីបាច់ពោល ទៅថ្វី ក្នុងការធ្វើរឿយៗ (ឬការតាក់តែង) ដោយកាយ ដោយវាចា ។

**កោ បន វាទោ** នេះមានច្រើនក្នុងគម្ពីររហូតទៅដល់ ៦៨ គម្ពីរ បើលើកឧទាហរណ៍មកច្រើនពេកនាំឱ្យវែងឆ្ងាយណាស់ សូម អ្នកសិក្សាពិនិត្យហើយប្រែតាមន័យពន្យល់មកចុះ ។

បើសិនជាយើងចងស័ព្ទ **កោ បន វាទោ** ក៏នឹងឃើញថា ស្មើនឹង **កិមង្គំ បន** ឧទាហរណ៍ចងបែបប្រយោគ ទី ១ ៖

*តាត មហាលុកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ ន វសេ វត្តន្តិ កោ បន វាទោ យេ ញាតកា ។ (យេ ញាតកា ជាប្រយោគចំណែក យ មួយ ចំណែក ញាតកា ជាលិង្គត្ថៈឬ សយកត្តាក្នុង ហោន្តិ ក៏បាន ត្រូវបន្ថែម ត ស័ព្ទទទួលប្រយោគ កោ បន វាទោ ប្រកប ជា តេសំ ( ញាតកានំ) ឬតេសុ (ញាតិកេសុ)ក៏បាន ។*

**បគេវ**

*(៣) បគេវ ចុះដើមសេចក្តីចំណែកក្រោយដែលឧបត្ថម្ភ* ដល់សេចក្តីចំណែកដើម តែសំដែងសេចក្តីខ្លាំងក្លាជាង ហៅ កិរិយាវិសេ-សនំ , ស័ព្ទនេះអដ្ឋកថាកែអត្ថថា បឋមញ្ញេវ (មុននោះឯង សេចក្តីថា ក្រៃលែង) ដោយសរសើរថា អតិរិយ (លើសប្រៀប)ខ្លះ ឧ. **សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា** ។ សេចក្តីចំណែកដើមសំដែងថា បើព្រះរាជាប្រព្រឹត្តអធមិ , សេចក្តីចំណែកក្រោយបញ្ជូនសេចក្តីឱ្យក្រៃលែងឡើងថា ប្រជានុរាស្ត្រក្រៅនេះ រមែងប្រព្រឹត្តធ្ងន់តែម្តង ។

អធិប្បាយ : (១) **បគេវ** ជាកិរិយាវិសេសនៈចុះក្នុងសេចក្តីចំណែកក្រោយ ដើម្បីអត្ថដូចសំដែងមកហើយ ឧ. ៖

ឧ.ទី ១ **សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា ។**

(ខុទ្ទក.ចតុក្កនិបាត រាជោវាទជាតក ៥៨/២២២ ខុទ្ទក.បញ្ញាសជាតក ឧម្មាទន្តីជាតក ៦១/២៦ . នេត្តិប្បករណ៍ សាសនប្បដ្ឋាន សំកិលេស-ភាគិយសូត្រ ទំព័រ ១២៦ .នេត្តិវិភាវិនីដីកា ទំព័រ ៣៤៧) ។

**ចេ** បើ **សោ រាជា** រីព្រះរាជាអង្គនោះ **ចរតិ** ប្រព្រឹត្ត **អធម្មំ** នូវអធមិ **បជា** រីប្រជានុរាស្ត្រ **ឥតរា** ក្រៅនេះ **ចរតិ** រមែងប្រព្រឹត្តិ **អធម្មំ** នូវអធមិ **បគេវ** ពិតប្រាកដ ។ **បគេវ** ជាកិរិយាវិសេសនៈ

របស់ **ចរតិ** ។ ជាតកដ្ឋកថា (៨/៥១) ថា **បគេវាតិ តស្មឹ អធម្មំ ចរន្តេ ឥតរា បជា បគេវ ចរតិ អតិវិយ ករោតីតិ អត្ថោ ។**

ឧ.ទី ២

**ចក្ខុសុ បន ទីបេសុ ចក្កវត្តិសិរឹ ទាតុំ សមត្ថា មាតាបិតរោ នាម បុត្តានំ នត្ថិ , បគេវ ទិព្វសម្បត្តឹ វា បឋមជ្ឈានាទិសម្បត្តឹ វា** (សោរេយ្យត្ថេរវត្ថុ ២/២៦៣) ។ **បន** ក៏ **ចក្ខុសុ ទីបេសុ ចក្កវត្តិសិរឹ ទាតុំ សមត្ថា មាតាបិតរោ នាម** ឈ្មោះថា វីមាតានិងបិតាដែលអាច ដើម្បីឱ្យនូវចក្រពត្តិដ៏មានសិរី ក្នុងទ្វីបទ.៤ **បុត្តានំ** ដល់កូនទ. **នត្ថិ** មិនមាន, **ទិព្វសម្បត្តឹ វា បឋមជ្ឈា-នាទិសម្បត្តឹ វា ទាតុំ សមត្ថា មាតាបិតរោ នាម** ឈ្មោះថា វីមាតានិងបិតាដែលជាអ្នកអាចឱ្យនូវទិព្វសម្បត្តិឬ ឬថា នូវសម្បត្តិមានបឋមជ្ឈានជាដើម **បុត្តានំ** ដល់កូនទ. **នត្ថិ** រមែងមិនមាន **បគេវ** មុនពិតប្រាកដ ។

ឧ.ទី ៣

**យតោហំ ភន្តេ ជាតោ នាភិជានាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតា បគេវ ជាគរោ** (វិនយ.មហាវិភង្គ ទុដ្ឋទោសសិក្ខាបទ ២/២៥៣) ។ បពិត្រព្រះអង្គដ៏ចំរើន តាំងពីខ្ញុំព្រះអង្គកើតមក សូម្បីតែដេកយល់សប្តិសេពមេថុនធម្ម ក៏មិនដែលស្គាល់

សោះឡើយ ការរលឹក ក៏ក្រៃលែងមិនស្គាល់មុនតែម្តង ។ បានជាប្រែមុនតែម្តង ព្រោះអដ្ឋកថាខែថា **បឋមំយេវ** នៅក្នុងអដ្ឋកថា សមន្តប្បាសាទិកា ភាគទី ៣ ទំព័រ ១៣៣ ខែពន្យល់ថា **នាភិជានាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតាតិ សុបិនន្តេនបិ មេថុនំ ធម្មំ នាភិជានាមិ ។ ន បដិសេវិតា អហន្តិ វុត្តំ ហោតិ ។ អថ វា ។ បដិសេវិតា ហុត្វា សុបិនន្តេនបិ មេថុនំ ធម្មំ ន ជានាមីតិ វុត្តំ ហោតិ ។ យេ បន បដិសេវិត្វាតិ បឋន្តិ តេសំ ឧជុកមេវ ។ បគេវ ជាគរោតិ ជាគរន្តោ បន បឋមំយេវ ន ជានាមីតិ ។**

ឧ.ទី ៤

**បឋមជ្ឈានស្ស ឧបចារម្បិ ន សម្បជ្ជតិ បគេវ ឈានំ...** (នេត្តិប្បករណ៍ បដិនិទ្ទេសវារវណ្ណនា) ។ **បុគ្គលោ** រីបុគ្គល **ន សម្បជ្ជតិ** មិនបានសម្រេច **ឧបចារម្បិ** សូម្បីនូវឧបចារៈនៃបឋមជ្ឈាន **ន សម្បជ្ជតិ** តែងមិនបានសម្រេច **ឈានំ** នូវឈាន **បគេវ** ពិតប្រាកដ ។ **បគេវ** កិរិយាវិសេសនៈ ។

ឧ.ទី ៥

**មយញ្ច ទដ្ឋុម្បិ ន លភាម បគេវ ភិក្ខុំ វា ទាតុំ ...** (សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហាបទានសូត្រ

និង មនោរថបូរណី អដ្ឋកថា ឯកនិបាត ឯតទគ្គៈ) ។ **មយំ** វីយើងទ. **ន លភាម** មិនបាន **ទដ្ឋុម្បិ** សូម្បីការឃើញ **បគេវ** វីបាច់ពោលទៅថ្វី **មយំ** វីយើងទ. **លភាម** បាន **ទាតុំ** ដើម្បីឱ្យ **ភិក្ខំ វា** នូវភិក្ខាឬ...។ **បគេវ** លិង្គត្ថៈ ។

ឧ.ទី ៦

**តំ សុត្វា សុមេធបណ្ឌិតោ ពុទ្ធោតិ ខោ បនេស ឃោសោបិ ទុល្លភោ បគេវ ពុទ្ធុប្បាទោ...** (មធុរត្ថវិលាសិនី សុមេធបត្ថនកថាវណ្ណនា អដ្ឋកថា ពុទ្ធវំស ) ។ វីសុមេធបណ្ឌិត ឮនូវការប្រកាសនោះហើយ គិតថា ក៏សូម្បីវីការប្រកាសនោះថា **ពុទ្ធោ** ដូច្នេះឯង ជាពាក្យប្រកាសរកបានដោយកម្រ វីការកើតឡើងនៃព្រះពុទ្ធ មុននោះឯង (ប្រែយកន័យថា នឹងបាច់ពោលទៅថ្វី ដល់ការកើតឡើងនៃព្រះពុទ្ធ )។ បគេវ កិរិយាវិសេសនៈ ។ នៅក្នុងព្រះត្រៃបិដកក្រុមជំនុំប្រែដោយច្រើនយកសេចក្ដីដូច **កិមង្គំ បន** ដែរ ដូចជា៖

**មាតុគាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា អន្តមសោ តទហុជាតាបិ ទារិកា បគេវ មហន្តរី** (វិនយបិដក មហាវិភង្គ កាយសំសគ្គសិក្ខាបទ ២/៥៧) ។ មនុស្សស្រី ហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី សត្វតិរច្ឆានញី មិនហៅថា មាតុគ្រាមទេ (ក្នុងសិក្ខាបទនេះ) ដោយហោចទៅទោះក្មេងស្រីសូម្បី

កើតក្នុងថ្ងៃនោះ  ក៏ហៅថា មាតុគ្រាមដែរ  មិនបាច់ពោលដល់ស្ត្រីដែលធំជាងនោះទេ ។

សូមអ្នកសិក្សាពិចារណាមើលក្នុងប្រយោគដែលប្រែជួបនោះចុះ ប្រយោគណា **បគេវ** ជាកិរិយាវិសេសនៈ,ប្រយោគណា  **បគេវ** ជាលិង្គត្ថៈ ហើយប្រែតាមឧទាហរណ៍ដែលលើកមកជាសាធកៈនោះចុះ ។ ចំណែកពាក្យថា **បគេវ** មានសំដែងច្រើនក្នុង អដ្ឋកថា ដីកា និងគន្ថន្តរៈដទៃ ៗ ទៀតជាច្រើន  កាលបើកុលបុត្រប្រាថ្នាការសិក្សាឱ្យច្បាស់លាស់  សូមរៀនប្រយោគ  បគេវ  នេះឱ្យបានល្អដោយសង្កេតពិនិត្យយ៉ាងល្អិតល្អន់តាមពិធីពន្យល់និងឧទាហរណ៍ខ្លះៗ ដែលខ្ញុំបានលើកឡើងមកពោលទុកក្នុងសៀវភៅនេះនឹងស្ទាត់ជំនាញមិនខានទេ ។

**បគេវ**

**ចប់ដោយសង្ខេប**

## កិរិយាបទ

និបាតឬអព្យយកិរិយាគឺ សត្តា លព្ភា អលំ ជាកិរិយាបទពិសេស. សត្តា ប្រើក្នុងប្រយោគកម្មវាចកៈខ្លះ ភាវវាចកៈខ្លះ ។ លព្ភា ប្រើក្នុងប្រយោគកម្មវាចកៈជាផ្ទៃ ។ អលំ ក្នុងអត្ថវារណៈគឺហាមឃាត់ (កុំឡើយ) ជាដើមដោយច្រើន ប្រើក្នុងប្រយោគកម្មវាចកៈខ្លះ ភាវវាចកៈខ្លះ ។

អធិប្បាយ :កិរិយាបទនេះ ប្រើតែក្នុងប្រយោគកម្មវាចកៈនិងភាវវាចកៈហើយគង់រូបនៅតែម្យ៉ាងដូចអព្យយស័ព្ទ ទើបចាត់ជានិបាត ប្រើបានគ្រប់លិង្គ វចនៈទាំងអស់ ខ្ញុំនឹងពោលមួយបទៗដូចតទៅ ៖

### (១)សត្តា

សត្តា កាលបើពោលតាមគោលវេយ្យាករណ៍នោះ មិនគួរប្រើជាកម្មវាចកៈ ព្រោះជាអកម្មធាតុ តែតាមភាសានិយមក្នុងគម្ពីរទាំងឡាយ លោកប្រើជាកម្មវាចកៈផង ក៏ប្រាប់កម្មវាចកៈក្នុងប្រយោគដូច្នោះ ។ បើកាន់ថា ជាកម្មវាចកៈមិនបាន ព្រោះ សក្កា ជាអកម្មធាតុ ក៏គួរកាន់ថា ជាកត្តុវាចកៈបាន ព្រោះអកម្មធាតុរមែងជាកត្តុវាចកៈបាន តែភាសានិយមដែលប្រើទូទៅ មិនព្រមឱ្យកាន់ដូច្នោះ គឺមិនមែនជាកត្តុវាចកៈ ប្រើតែកម្មវាចកៈខ្លះ ភាវវាចកៈខ្លះ តាមរូបប្រយោគ , បើ

មានពាក្យសួរថា ដែលប្រើជាភាវវាចកៈចូរលើកទុក ចំណែកដែលប្រើបទកម្មវាចកៈនឹងបានបទកម្មពោលជាប្រធានមកពីណា ព្រោះ សក្កា មិនមានកម្ម ? តបថា បានបទកម្មរបស់បទកិរិយា តុំ បច្ច័យជំនួស ព្រោះក្នុងប្រយោគ សក្កា រមែងមានបទ កិរិយា តុំ បច្ច័យប្រកបជាមួយ រហូត គឺប្រើកម្មរបស់ តុំ បច្ច័យ នោះៗឯងជាប្រធាន,កាលប្រយោគភាវវាចកៈ បទកម្មនោះ ក៏ជាអវុត្តកម្មខ្លះ ការិតកម្មខ្លះ ក្នុងបទ តុំ បច្ច័យ នោះ ឧ. ៖

**កម្មវាចក:**

**ពុទ្ធា ច នាម ន សក្កា សឋេន អារាធេតុំ** (ធម្ម. ចក្ខុបាលត្ថេរវត្ថុ ១/១២) ។ **ពុទ្ធា ច នាម** ធម្មតាព្រះពុទ្ធទាំងឡាយ **សឋេន** គឺបុគ្គលអួតអាង **ន សក្កា** មិនអាច **អារាធេតុំ** ដើម្បីឱ្យព្រះអង្គទ្រង់ប្រោសប្រាណបានទេ ។ **ពុទ្ធា** វុត្តកម្ម ក្នុង **ន សក្កា** , **សក្កា** កិរិយាបទកម្មវាចកៈ ។

**ភាវវាចក:**

**ន ហិ អម្ហេសុ ឯកេន (ជនេន) អបព្វជិតុំ** (ទេវទត្តវត្ថុ ១/១៩៩) ។ **ហិ** ព្រោះថា **អម្ហេសុ** បណ្តាយើងទាំងឡាយ **ឯកេន ជនេន** គឺជនណាមួយ **ន សក្កា** មិនអាច **អបព្វជិតុំ** ដើម្បីមិនបួសបាន

ទេ ។ **ឯកេន** វិសេសនៈ របស់ **ជនេន** ៗ អនភិហិតកត្តា ក្នុង **ន សក្កា** , **ន** បដិសេធ ក្នុង **សក្កា** ៗ កិរិយាបទ ភាវវាចកៈ ។

ឧសង្កេត ៖ ក. វិធីរៀងប្រយោគ សក្កា សង្កេតតាមអាគតស្ថាន នោះដូច្នេះ ៖

(ក) សក្កាវៀងទុកមុខឬក្រោយបទ តុំ បច្ច័យ ជាមួយបទដែល ជាប់ទាក់ទងដោយ តុំ បច្ច័យ ឧ. ៖

សក្កា រៀងទុកមុខ តុំ បច្ច័យ

ឧ. ១ **ពុទ្ធោ ច នាម ន សក្កា សវេន អារាធេតុំ ។**

ឧ. ២ **ន ហិ សក្កា អម្ហេសុ ឯកេន អបដ្ឋិតុំ ។**

ឧ. ៣ **សក្កា គេហំ អជ្ឈាវសន្តេហិ បុញ្ញានិ កាតុំ ។**

ឧ. ៤ **គហិនា ហុត្វា សក្កា ទុក្ខា មុច្ចិតុំ** (២/២១៦)

សក្កា រៀងទុកក្រោយបទ តុំ បច្ច័យ

ឧ. ៥ **សោ តមស្ស សន្តិកេ ឧប្បាទេតុំ ន សក្កា ។**

(សញ្ញយ. ១/១២៩)

ឧ. ៦ **តយា គន្តុំ ន សក្កា** (កោសម្ពិកវត្ថុ ១/៨៤) ។

ឧ. ៧ **អនេនាតេន បវិសិតុំ ន សក្កា** (ធម្ម.បណ្ឌិត-សាមណេរវត្ថុ ៤/៤៦) ។

(ខ) បទអនភិហិតកត្តារៀងទុកខាងក្រោយ សក្កា ខ្លះ ដូច ឧ.

១ ,២, ៣, រៀងទុកមុខ សក្កា ខ្លះ ដូច ឧ. ៤,៦,៧, តែរៀងទុកមុខបទ តុំ បច្ច័យរហូត ។

(គ) បើជាប្រយោគកម្មវាចកៈ បទវុត្តកម្មៈរៀងទុកមុខ សក្កា ខ្លះ ឧ. ១,៥, រៀងទុកក្រោយ សក្កា ខ្លះ ឧ. **ន សក្កា សោ អគារមជ្ឈេ វសេន្តេន បូរេតុំ** (ចក្ខុបាលត្ថេរវត្ថុ ១/៨) ។

(ឃ) ជាប្រយោគពាក្យសួររៀង សក្កា ទុកមុខប្រយោគ ឧ. **ន សក្កា មយា តំ គហេតុំ ?** (សាមាវតី ២/ ៥៩)

ខ.កន្លែងខ្លះ សក្កា ចូលក្នុងកិរិយាថា មាន ថាជា( ជាវិកតិកត្តា ) កិរិយានោះដោយប្រក្រតី រៀងទុកក្រោយ សក្កា ឧ. **នោ ចេតំ ភិក្ខវេ សក្កា អភវិស្ស កុសលំ ភាវេតុំ** (បហានភាវនាសូត្រ) ។ ម្នាលភិក្ខុទ. បើកុសលនោះ ជាកិច្ចដែលបុគ្គលមិនអាចដើម្បីឱ្យមានបាន សោត ។

(គ) តែបើចូលកិរិយាថា**មាន** ថា **ជា** នោះមិនបាន ក៏ត្រូវជាកត្តាក្នុងកិរិយានោះខ្លះ ឧ. **តត្ថ នំ អាគតំ គហេតុំ សក្កា ភវិស្សតិ** (សមាវតី ២/ ៥៩-៦០) ។ **តត្ថ នំ អាគតំ គហេតុំ សក្កា** វីការដែលយើងអាចចាប់នូវស្ដេចឧទេនដែលមកក្នុងទីនោះ នឹងមាន ។ **សក្កា** សយកត្តា ក្នុង **ភវិស្សតិ** ។

មានគោលគួរសង្កេតគឺ កាលអាចលើកបទ កម្មរបស់បទ តុំ បច្ច័យជាប្រធាន គឺជាកត្តា ក្នុងកិរិយាថា មាន ថា ជា បាន សក្កា ក៏ជា វិកតិកត្តា ក្នុងកិរិយាថា មាន ថា ជានោះ , បើមិនអាច សក្កា ក៏ជា ប្រធាន គឺជាកត្តាដោយខ្លួនឯង ដូចក្នុង ឧ.ថា **តត្ថ នំ អាគតំ គហេតុំ សក្កា ភវិស្សតិ** នោះ ។

សាកប្រែប្រយោគនេះលមើល ៖

**-សាកិយា វិឌូឌភស្សាគមនំ ញត្វា វន្ទិតុំ ន សក្កា** (ធម្ម. វិឌូឌភវត្ថុ ៣/២២) ។

លព្ភា

**លព្ភា** នេះប្រហាក់ប្រហែលនឹង **សក្កា** ដែរ តែមានតិចជាង សក្កា ឧ. ៖

ឧ.ទី ១

**តំ កុតេត្ថ លព្ភា យំ មេ បរេ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេយ្យុំ** (និគ្គន្ធសូត្រ ) ។ ខដែលមនុស្សដទៃ គប្បី បន្ទោបង់ នូវសេចក្តីមិនត្រេកអរ ញុំាងសេចក្តីត្រេកអរឱ្យកើត ដល់ យើង នឹងបានកាលភាគៈនេះកើតឡើងហើយ អំពីទីណា ។

**តំ កុតេត្ថ លព្ភា** ប្រើក្នុងទីច្រើនបទ , កន្លែងខ្លះ **តំ** ប្រើជា

ហេតុ ( សុ.វិ. ២/២១៤ **ឥន្ទិ ឥស្នា** ) កន្លែងខ្លះសំដែងសេចក្តី លព្ភា ជា សក្កា លទ្ធុំ ខ្លះ ជា លទ្ធព្វ ខ្លះ ( សុ.វិ. ៣/២១០) ។

ឧ.ទី ២

**លព្ភា ហិ បុមុនា ឥទំ** ( វេស្សន្តរជាតក ) ។ ព្រោះ សេចក្តីទុក្ខនេះ ដែលបុរុស ( អ្នកត្រាច់ទៅក្នុងភព) គប្បីបាន ។ ជាតដ្ឋកថា ( ១០/៤៣០) ថា បុមុនាតិ ឥទំ ភវេ វិចរន្តេន បុរិសេន លភិតព្វំ ។ កែអត្ថ លព្ភា ជាលភិតព្វ ។

ឧ.ទី ៣ **ឥទំ (រជ្ជំ ) ន លព្ភា ឯវំ កាតុំ** ( ធម្ម.វិឌូឌភវត្ថុ ) ។ វិរាជសម្បត្តិនេះ គឺអ្នកមិនបាន ដើម្បីធ្វើយ៉ាងនេះ ។

ឧ.ទី ៤ **លព្ភា ...ភោគា ច ភុញ្ជិតុំ ,(លព្ភា ) បុញ្ញានិ ច កាតុំ** ( មហាវិភង្គ បឋមភាគ ) ។ វិទ្រព្យទ. គឺអ្នកបានដើម្បី បរិ-ភោគផង , វិបុណ្យទ.គឺអ្នកបានដើម្បីធ្វើផង ។

សមន្តប្បាសាទិកា ( ១/២៤២) កែសេចក្តី **លព្ភា** ជា**លភន្តិ** ។

**លព្ភា** នេះ ជាសកម្មធាតុ ផ្សេងពី សក្កា ទាំងវិធីប្រកបប្រយោគ ក៏មិនដូចគ្នា , គឺប្រយោគ លព្ភា ដែលបទ តុំ បច្ច័យ និងលើកបទ កម្ម របស់ តុំ បច្ច័យ ជាប្រធានក្នុងប្រយោគកម្មវាចកៈក៏មាន ដូចក្នុងឧ.ទី ៤ លើកបទកម្មរបស់ តុំ បច្ច័យ គឺ ភោគា និង បុញ្ញានិ ជាប្រធាន , ដែល មិនមែនបទ តុំ បច្ច័យក៏មាន ព្រោះក្នុងប្រយោគដែលមិនមាន តុំ បច្ច័យ

ដូចឧ.ទី ១-២ , ដែលផ្សេងពី សក្កា ដែលត្រូវមានបទ តុំ បច្ច័យរហូត ។ ប្រយោគ លព្ភា ដែលមិនមែនបទ កម្មរបស់បទ តុំ ជាប្រធានក៏មាន ឧ. **យេ សមណេសុ សក្យបុត្តិកេសុ បព្វជន្តិ ន តេ លព្ភា កិញ្ចិ កាតុំ ។** ជនពួកណាបួសក្នុងសមណៈទ.ដែលជាសក្យបុត្រ , ជនទាំងនោះដែលអ្នកណាៗ មិនបានដើម្បីធ្វើអ្វីតិចតួច ៗ ។ បើប្រយោគ លព្ភា ដែលប្រកបយ៉ាង សក្កា ភាវវាចកៈ ក៏គួរជាភាវវាចកៈបានផងដែរ ។

ភាវសាធនៈសម្រេចរូបមកពីភាវវាចកៈ ព្រោះជាភាវរូបតែម្យ៉ាង , ក៏ភាវសាធនៈនោះ ប្រើបានក្នុងធាតុទាំង ២ ,អកម្មធាតុចូរលើកទុក , ពោលចំពោះសកម្មធាតុ កាលតាំងវិគ្រោះក៏ត្រូវតាំងជាភាវ-វាចកៈ ។ ទើបឃើញថា សកម្មធាតុជាភាវវាចកៈបាន ក្នុងទីគួរមាន ។

**អលំ**

**អលំ** ប្រើកិរិយាបទបាន ដូច សក្កា ដែរ តែប្រើជានិបាតក្នុងអត្ថវារណៈគឺ ហាម (កុំឡើយ) ជាដើមដោយច្រើន ដូចឧ. ៖

ឧ.ទី ១ **<u>អលំ</u> មោគ្គល្លាន មា តេ រុច្ចិ បឋវឹ បរិវត្តេតុំ វិបល្លាសំបិ សត្តា បដិលភេយ្យុំ** (វិនយ. វេរញ្ជកណ្ឌ ១/២១) ។ ម្នាលមោគ្គល្លាន គឺអ្នកកុំពេញចិត្ត <u>មិនគួរ</u> ដើម្បីត្រឡប់ផែនដីនោះឡើយ សត្វទាំងឡាយ នឹងបាននូវសេចក្ដីជ្រួលជ្រើមរចល់ ។

សមន្តប្បាសាទិកា (១/៣៩៥) **តត្ថ អលន្តិ បដិក្ខេបវចនំ ។** បណ្ដាបទទាំងនោះ បទថា **អលំ** ជាពាក្យហាមឃាត់ ។

ឧ.ទី ២ **នវហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា នាលំ ឧបគន្តុំ ឧបគន្ត្វា វា នាលំ ឧបនិសីទិតុំ** (ធម្ម. វិឌូឌភវត្ថុ ៣/១៣ ) ។ ម្នាលភិក្ខុទ. វីត្រកូលប្រកបដោយអង្គ ទ. ៩ គឺភិក្ខុ នៅមិនចូលទៅ <u>មិនគួរ</u> ដើម្បីចូលទៅផង ចូលទៅហើយ <u>មិនគួរ</u> ដើម្បីអង្គុយផង ។

ឧ.ទី ៣ **អលំ ហិ វោ កាលាមា កង្ខិតុំ អលំ វិចិកិច្ឆិតុំ** (អង្គុត្ត. តិក. ៤១ ) ។ ម្នាលកាលាមៈទាំងឡាយ គឺអ្នកទ. គួរដើម្បីសង្ស័យគួរដើម្បីវិចិកិច្ឆា។ (អលំ=យុត្តំ មនោបូរណី ២/២៣៩) វោ អនភិហិតកត្តា ក្នុង អលំ ៗ កិរិយាបទ ភាវវាចកៈ ។

(២) សូម្បីបទនាមកិតកៈខ្លះក៏បទប្រើជាកិរិយា ឧ. ៖

លព្ភមេតំ វិជានតា ( សោនន្ទជាតក ) ។ ផល (ឥដ្ឋផល)នុ៎ះ គឺអ្នកដឹងច្បាស់គប្បីបាន ។ (លព្ភំ =លភ +ណ្យ មិនជានិបាតបទ ដូច លព្ភា , តែ លព្ភា ក្នុងកន្លែងខ្លះ អាចគិតថាជា នាមកិតកៈបាន ។

ឧ.ទី ២ **តេ ច ភិក្ខូ គារយ្ហា** (វិនយបិដក មហាវិភង្គ ។ ភិក្ខុទាំងឡាយនោះ ត្រូវតិះដៀលផង ។

ឧ.ទី ៣ **វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា** (អបរិហានិយ-សូត្រ) ។ ម្នាលភិក្ខុទាំងឡាយ វិសេចក្តីចំរើនតែម្យ៉ាង ដែលភិក្ខុទាំងឡាយ គប្បីសង្ឃឹមបាន ។ (បាដិកង្ខា = បដិ +កង្ខ+ណ ព្រោះអដ្ឋកថាកែអត្ថជា បាដិកង្ខិតព្វា ) ។

នាមកិតកៈដែលប្រើជាកិរិយានេះ អ្នករៀនខ្លះមិនហ៊ានប្រើជាកិរិយា តែសង្កេតមើលទៅលោកប្រាថ្នាឱ្យជាកិរិយា ព្រោះហេតុនោះហៅដូចកិរិយាក្នុងប្រយោគ ក៏សមគួរ ។

សូម្បីកិរិយាកិតកៈដែលប្រើជានាម ក៏ប្រាប់សម្ពន្ធជានាមបាន រឿងអីដែលនាមកិតកៈ ដែលប្រើជាកិរិយាប្រាប់កិរិយាមិនបាននោះ ។

សាកល្បងប្រែមួយប្រយោគមើល កើតមិនកើតមើលទៅ ៖

**អលំ តាត កឹ តត្ថ គន្ត្វា ករិស្សសិ ធម្ម. ៣/២១ )**

(៣) តទៅនឹងសំដែងស័ព្ទ សក្កា លព្ភា និង អលំ តាមស្វែងរកអំពីអភិធានស័ព្ទខ្លះ ប្រកបសន្និដ្ឋាន ៖

**សក្កា លព្ភា**

សក្កា លព្ភា ថាជានិបាតមកពីកិរិយាអាខ្យាតសត្តមីវិភត្តិ សំដែងរូបបែបសំស្ក្រឹតគឺ សក លភ ធាតុ ចុះសត្តមីវិភត្តិ សម្រេចរូបជា សក្យាត លភ្យាត ។

-សន្និដ្ឋានថា សក្យាត   លភ្យាត ក្នុងសំស្ក្រឹត កាលមកកាន់បាលី ត វិនាសបាត់ទៅ គង់នៅសល់តែ សក្កា លព្ភា ប្រៀបធៀបពាក្យ ស្យាត កុរ្យាត មកកាន់បាលីជា សិយា កយិរា តាមសន្និដ្ឋាន ដើមឡើយជាកត្តុវាចកៈ ។

ដូច្នេះ សក្កា លព្ភា ជាអព្យស័ព្ទឬនិបាតនិងមកប្រើជាកម្មវាចកៈ ភាវវាចកៈខ្លះ ។

ស័ព្ទទំនងនេះឯង គឺដើមជាកិរិយាអាខ្យាត ហើយមកជា និបាតអព្យយស័ព្ទ មានការប្រៀបធៀបគ្នាគឺ៖

មញ្ញេ មកពី មន+យ+អ វត្តមានវិភត្តិ អត្តនោបទ ។

ភណេ មកពី ភណ+អ+ឯ វត្តមានាវិភត្តិ អត្តនោបទ ។

អញ្ញទត្ថុ មកពី អញ្ញ +អត្ថុ ( អស +តុ បញ្ចមី វិភត្តិ ) ។

តែ លព្ភា ដោយអត្ថ លោកកែច្រើនយ៉ាងដូចពោលទុកហើយខាងដើមនោះឯង ។

## អលំ

អលំ ថាជានិបាត មាន ២ ប្រភេទ គឺ៖

ក. មកពី អល ធាតុ ប្រព្រឹត្តទៅក្នុងសេចក្ដីថា ស្ទាត់ អាច , ចុះនិគ្គហិត កាលសម្រេចរូបស័ព្ទ ។ អល នេះ ជាធាតុប្រឌិតឡើងដើម្បីអលំ ស័ព្ទ ។

ខ. សម្រេចរូបពី ឫ ធាតុ ក្នុងសំស្ក្រឹត ប្រព្រឹត្តទៅក្នុងសេចក្ដីថា រហ័ស សម្រេចរូបជា អរ ។ ហើយធ្វើឱ្យជាកម្មវាចកៈ កិរិយាវិសេសនៈ ជា អរំ កើតរូបថ្មីមួយទៀត ជា អលំ , មានសេចក្ដីថា គួរ , សម , អាច, ហើយក្លាយជានិបាតទៅ ។

ការប្រើ ៖ អលំ ប្រើក្នុងសេចក្ដីបានច្រើនយ៉ាង ,ក្នុងសេចក្ដីហាម ដូច អលំ មេ ពុទ្ធេន , ក្នុងសេចក្ដីថា គួរ ថា អាច ដូច អលំ កាតុំ អលំ សវិធាតុំ ជាដើម ។

**សរុបអធិប្បាយ** : កិរិយាបទ គឺ សក្កា លព្ភា អលំ ដែលប្រើ ជាបទកិរិយាក្នុងប្រយោគ កម្មវាចកៈខ្លះ ភាវវាចកៈខ្លះ ។

**ចប់កិរិយាបទ ដោយសង្ខេប**

ខ្ញុំបានរៀបរៀងសៀវភៅវាក្យសំសយទីបនីនេះ ដែលវិចិត្រទៅដោយប្រយោគនិងសម្ពន្ធពិសេស ៧ សម្រាប់ជំនួយដល់ការសិក្សាបាលី និងការប្រែគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា ជាដើមយ៉ាងល្អ ។ ខ្ញុំបានលើកឧទាហរណ៍មកដាក់ក្នុងទីនេះ សុទ្ធតែជាពាក្យដែលមានក្នុងគម្ពីរទាំងអស់មិនបានលើកគោលអាងមកដោយពាក្យខ្លួនឯង ឬ បញ្ចេញបញ្ចូលនោះទេ ។

សូមបានសម្រេចប្រយោជន៍ដល់ការសិក្សាវេយ្យាករណ៍ និងការប្រែគម្ពីររបស់កុលបុត្រក្នុងកម្ពុជរដ្ឋទាំងមូល ។

## វាក្យសំសយទីបនី
## ភាគទី ១
## ចប់ដោយបរិបូណ៌

ពុទ្ធសាសនបណ្ឌិត្យ

ថ្ងៃ ៥ កើត ខែ ពិសាខ ឆ្នាំ មមែ បញ្ចស័ក ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ៥ ខែ ឧសភា គ.ស. ២០០៣

**ហ៊ាន់ ចាន់សារ៉ែន**

ក្រុមជំនុំព្រះត្រៃបិដកនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

# និគមនគថា

យំ សិទ្ធំ ឥមិនា បុញ្ញំ យញ្ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន សីឃំ បប្បោមិ និព្វុតឹ
អប្បត្តោ យាវ និព្វានំ ភវេយ្យំ ជាតិជាតិយំ
មហាបញ្ញាយ សម្បន្នោ ជោតេយ្យំ ជិនសាសនំ
ឥមិនា រចនេន តុ សព្វេ សត្តា សុខី ហោន្តុ
កម្ពុជរដ្ឋវាសិនំ សន្តិភាវោ សទា ហោតុ

ដោយផលបុណ្យដែលសម្រេចពីការរចនានូវវាក្យសំសយទីបនីនេះក្តី ដោយបុញ្ញកម្ម ដែលខ្ញុំបានសន្សំមកហើយក្តី សូមឲ្យខ្ញុំបានសម្រេច នូវព្រះនិព្វានឆាប់ ៗ រហ័ស ។

ប្រសិនបើខ្ញុំមិនទាន់បានសម្រេចនូវព្រះនិព្វានដរាបណា ក៏សូមឲ្យខ្ញុំជាអ្នកដល់ព្រមដោយបញ្ញា អាចប្រកាសសាសនាព្រះជិនស្រីឲ្យរុងរឿងគ្រប់ៗជាតិ ។

ដោយការរចនាសៀវភៅនេះ សូមសព្វសត្វទាំងអស់ប្រកបតែសេចក្តីសុខ សូមសន្តិភាពកើតមានគ្រប់ ៗ កាលដល់ប្រជាជនអ្នករស់នៅក្នុងដែនកម្ពុជា ។ ៚

## ឯកសារពិគ្រោះ

**១.កច្ចាយនព្យាករណ៍** ភាសាបាលី

**២.សទ្ទនីតិ** ភាសាបាលី

**៣.មោគ្គល្លានព្យាករណ៍** ភាសាបាលី

**៤.សម្ពន្ធមាលា** អ៊ុត ជា ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសន-បណ្ឌិត្យ ភ្នំពេញ បោះពុម្ពលើកទី ៤ ឆ្នាំ ១៩៩៣

**៥.វិធីប្រែបាលី** ឃុនសុចក្តិទេវី យូរ អ៊ុន ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី ៥ ឆ្នាំ ១៩៩៣

**៦.បាលីវេយ្យាករណ៍** ព្រះពុទ្ធវង្ស សេខ នាង សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ បោះពុម្ពលើកទី ៨ ឆ្នាំ ២០០០

**៧.អធិប្បាយវាក្យសម្ពន្ធ** ក្បាល ២ សោភនគណាភរណ៍ សុ-វឌ្ឍនោ ប្រយោគ ៩ ច្បាប់មហាមកុដរាជវិទ្យាល័យ បោះពុម្ពលើកទី ៩ ព.ស.២៥៣៨ ក្រុងបាងកក ។

**១០.អភិធានវណ្ណនា** ព្រះមហាសមប៉ង មុទិតោ វត្តមហាធាតុ បោះពុម្ពលើកទី ១ ព.ស. ២៥៤២ រោងពុម្ព ធម្មសភា ក្រុងទេពមហានគរ ( បាងកក ) ។

យោ និរុត្តឹ ន សិក្ខេយ្យ សិក្ខន្តោ បិដកត្តយំ
បទេ បទេ វិកង្ខេយ្យ វនេ អន្ធគជោ យថា
បុគ្គលណាមិនសិក្សានូវនិរុត្តិ គឺវេយ្យាករណ៍បាលីទេ
ហើយទៅសិក្សានូវគម្ពីរព្រះត្រៃបិដក បុគ្គលនោះគប្បី
ជាអ្នកសង្ស័យគ្រប់ៗបទដូចជាដំរីខ្វាក់ត្រាច់ទៅក្នុងព្រៃ.

(មោគ្គល្លានប្បញ្ចិកាដីកា ទំព័រ ១៦)

## សៀវភៅនេះជំនួយដល់

-ការចេះដឹងនូវវិធីប្រយោគនិងសម្ពន្ធយ៉ាងងាយ

-ការប្រែធម្មបទដ្ឋកថា

-ប្រែមង្គលត្ថទីបនី

-ប្រែវិសុទ្ធិមគ្គ

-ប្រែកង្ខាវិតរណី

-ប្រែអដ្ឋកថា-ដីកា

-ប្រែព្រះត្រៃបិដក